កំណាព្យអប់រំកាយចិត្ត
និង
សីលធម៌សង្គម

និពន្ធ និង រៀបរៀងដោយ

ខ្ញុំព្រះករុណាអាត្មាភាព

ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**

ចៅអធិការ វត្តមហាលាភ ឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម

ព.ស ២៥៥៥ រក្សាសិទ្ធិ គ.ស ២០១២

ទទួលអំណោយពី លោក [illegible] library of Cambodia
កក្កដា 2016

កំណាព្យអប់រំកាយចិត្ត

និង

សីលធម៌សង្គម

និពន្ធ និង រៀបរៀងដោយ

ខ្ញុំព្រះករុណាអាត្មាភាព

ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**

ចៅអធិការ **វត្តមហាលាភ** ឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម

ព.ស.២៥៥៥ រក្សាសិទ្ធ គ.ស.២០១២

ពាក្យផ្ដើម

សៀវភៅ (***កំណាព្យអប់រំភោយចិត្ត***) នេះខ្ញុំព្រះករុណា អាត្មាភាព បានសរសេររៀប រៀង ឡើងដើម្បី ជួយអប់រំ និងជួយដាស់សតិដល់យុវវ័យព្រមទាំងមនុស្សគ្រប់ស្រទាប់ ជាន់ ថ្នាក់ទាំងអស់ ទោះជាបុរស ឬ ស្ត្រី ក៏ដោយ ។

ពីព្រោះសព្វថ្ងៃនេះសង្គមយើងកំពុងតែ មានការរីកចំរើនច្រើនគ្រប់វិស័យ មិនថាតាមទីក្រុងទីប្រជុំជន ឬ ជនបទទេដូច្នេះហើយបាន ជាខ្ញុំព្រះករុណា ខ្លាចក្រែងតែកុលបុត្រ កុលធីតា ខ្មែរយើងភ្លេចភ្លាំងស្មារតីមិនបាន ពិចារណានូវវ័យរបស់ខ្លួនបណ្ដាលឱ្យមានភាព ស្រវឹងនៅក្នុងវ័យក្នុងកាមកិលេស ស្រវឹងក្នុងវត្ថុកាម ផ្សេងៗនាំឱ្យមានគ្រោះថ្នាក់ក្នុងឆាកជីវិត ក្នុងសង្គម ។ កាលណោមានភាពស្រវឹងក្នុងវត្ថុទាំងនោះហើយ ធ្វើឱ្យអ្នកទាំងអស់នោះ ភ្លេចស្មារតី ភ្លេច ទំនៀមទម្លាប់ ប្រពៃណីដូនតាខ្មែរយើងជាពុំខាន ម្យ៉ាងទៀតសព្វថ្ងៃនេះ វប្បធម៌បរទេស កំពុងតែហូរចូលមក ក្នុងស្រុក ខ្មែរយើង ច្រើនណាស់ យ៉ាងនេះហើយត្រូវតែមានការទប់ ស្កាត់ខ្លះៗទើបល្អប្រសើរ សមដូច ពាក្យចាស់លោកពោលថា: (***ការពារជាជាងព្យាបាល***)។

-ខ្ញុំព្រះករុណាអាត្មាភាពសង្ឃឹមថា: អស់លោកអ្នកដែលកំពុងតែកាន់

សៀវភៅ នេះនៅ ជាប់នឹងដៃ ហើយបានអាន នឹងបានពិចារណានោះ ពិត ជាយល់ដល់ជំរៅចិត្ត នឹងគោលបំណង របស់ខ្ញុំព្រះករុណា អាត្មាភាពជា ពុំខានឡើយ ។

អាស្រ័យហេតុនេះបើសិនជា មានការខុសឆ្គងត្រង់ពាក្យពេចន៏ប្រយោគ ឃ្លា ឬអក្ខរា វិរុទ្ធត្រង់ កន្លែង ណោមួយពុំសមរម្យ សូមព្រះតេជគុណ ឧបាសក ឧបាសិកា លោកគ្រូ អ្នកគ្រូ នឹងរៀមច្បង អ្នកប្រាជ្ញ កវី បណ្ឌិត ទាំងអស់មេត្តាជួយកែសំរួលនឹងបំពេញបន្ថែម រាល់កំហុសខុសឆ្គង នឹង ខ្វះខាតដោយសេចក្តីអនុគ្រោះផង ។

សូមអរព្រះគុណ និង សូមអរគុណ!!!!

ឧទ្ទិសកថា

-ដោយអំណាចផលនៃធម្មទានដែលកើតឡើងអំពីសទ្ធាជ្រះថ្លា នឹងសេចក្តីព្យាយាមប្រឹងប្រែងរបស់ខ្ញុំព្រះករុណាអាត្មភាព និពន្ធរៀបរៀងសៀវភៅ

(កំណាព្យអប់រំកាយចិត្ត)

នេះសូមឧទ្ទិសជូនដល់ បុព្វការីជនទាំងអស់ របស់ខ្ញុំព្រះករុណាអាត្មាភាព ដែល អស់លោកបាន ធ្វើដំណើរកាលកិរិយាទៅកាន់ បរលោកខាងមុខ ហើយដូចមានរាយនាមប្រាកដ នៅខាង ក្រោមរនេះ :

លោកតា គីង ខាន់ យាយ ឧក ម៉ិច	-លោកតា កង យាយ ហៀក
ព្យោមប្រុស ខាន់ សឿន (ជាព្យោមបង្កើត)	-លោកតា សួស យាយ ចិន
លោកអ៊ុំ គីង ឆែម	-លោកតា កុយ យាយ ហាយ
លោក ពូ គីង ហឿន	-លោក ពូ ឈឹម វណ្ណា (ពូម៉ាន)
លោក ពូ គីង ព្រឿន	-អ្នកមីង សួស សារីន
ព្យោម ឌី នីត	-អ្នកមីង សួស លន

ព្រមទាំងញាតិការទាំងប្រាំពីរសន្តាន និងអស់លោកដែលមាន គុណមកលើខ្ញុំព្រះករុណា ទាំងអស់ ព្រមទាំងដួងវិញ្ញាណក្ខ័ន្ធនៃបុព្វ វីរៈបុរសទាំងអស់ដែលបានពលីកម្មដើម្បីការពារ ប្រទេស ជាតិមាតុភូមិ សូមឱ្យវិញ្ញាណក្ខ័ន្ធអស់លោកអញ្ជើញមក អនុមោទនាទទួលយកនូវ ផលនៃធម្មទានទាំងអស់ដោយ សេចក្តីរីករាយផងចុះ បើបានអនុមោទនារួចហើយសូ

មឱ្យរួចរំដោះ ចាកទុក្ខទោសទាំងពួងហើយធ្វើដំណើរទៅកាន់សុគតិភពជា

ទីដ៏ខ្ពង់ខ្ពស់ដែល មានចំរើនដោយ ភិយ្យោភាព កុំបីអាក់ខានឡើយ !!!

សូមអនុមោទនាផលនៃធម្មទាននេះគ្រប់ៗគ្នាទៅហោង !!!

ឥទំ វោ ញាតីនំ ហោតុ:

សូមទាននេះកើតមានដល់ញាតិទាំងឡាយគ្រប់ៗគ្នា ។

ពីបំណងល្អរបស់ខ្ញុំព្រះករុណា

ភិក្ខុ**កល្យាណរតោ ខាន់ ស៊ិនសេម**

ចៅអធិការ **វត្តមហាលាភ** ស្រុកកោះសូទិន ខេត្តកំពង់ចាម

បញ្ជីមាតិកា

ល.រ	ឈ្មោះគោលធម៌	ទំព័រ
១	បទលើកទង់ព្រះពុទ្ធសាសនា	៧
២	កំណាព្យក្មេងទំនើង (ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**)	៨
៣	កំណាព្យចាស់ទំនើង (ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**)	១២
៤	ដែលហៅថាមនុស្សពាល (ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**)	១៨
៥	កូនបីជំពូក (ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**)	២២
៦	សង្គហធម៌របស់មាតាបិតា ៥យ៉ាង (ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**)	២៧
៧	កូនអើយធម៌សាមគ្គី (ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**)	៣១
៨	នាទីស្វាមីសង្គ្រោះភរិយា ៥យ៉ាង (ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**)	៣៣
៩	នាទីភរិយាត្រូវប្រតិបត្តិស្វាមី ៥យ៉ាង (ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**)	៣៥
១០	ឃរាវាសធម៌ ៤យ៉ាង (ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**)	៣៧
១១	ត្រូវតែត្រដររស់ (ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**)	៤៧
១២	អាសូរចិត្តម៉ែ (ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**)	៥២
១៣	អាសូរចិត្តឪ (ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**)	៥៧
១៤	ទំនួញកូនកំព្រា (ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**)	៦១
១៥	កូលាបបាក់ទង (ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**)	៦៥
១៦	ទំនួញចាបមាសក្រមុំ (ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**)	៦៧
១៧	អណ្តាត (ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**)	៧០
១៨	អកតញ្ញូ (ស្នាព្រះហស្តសម្តេចព្រះសង្ឃរាជ **ជួន ណាត**)	៧២
១៩	សីល ៥ (ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**)	៧៤
២០	អានិសង្សបុណ្យ ៥យ៉ាង (ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**)	៧៥

២១	អានិសង្សកតញ្ញូ ៤ យ៉ាង	(ដោយ ភិក្ខុកល្យាណេរតោ **ខាន់ ស៊ិនសេម**)	៧៧
២២	នាមរបស់មាតា បិតា ៤ យ៉ាង	(ដោយ ភិក្ខុកល្យាណេរតោ **ខាន់ ស៊ិនសេម**)	៧៨
២៣	ព្រហ្មវិហារធម៌ ៤យ៉ាង	(ដោយ ភិក្ខុកល្យាណេរតោ **ខាន់ ស៊ិនសេម**)	៨០
២៤	ព្រះគុណម៉ែ	(ដោយ ភិក្ខុកល្យាណេរតោ **ខាន់ ស៊ិនសេម**)	៨១
២៥	ការបែងចែកទ្រព្យ ៤យ៉ាង	(ដោយ ភិក្ខុកល្យាណេរតោ **ខាន់ ស៊ិនសេម**)	៨៤
២៦	ទ្រព្យមានឈ្មោះ ៤យ៉ាង	(ដោយ ភិក្ខុកល្យាណេរតោ **ខាន់ ស៊ិនសេម**)	៨៥
២៧	ទុក្ខ ៤កង	(ដោយ ភិក្ខុកល្យាណេរតោ **ខាន់ ស៊ិនសេម**)	៨៦
២៨	សុខោបុញ្ញស្សឧច្ចយោ	(ដោយ ភិក្ខុកល្យាណេរតោ **ខាន់ ស៊ិនសេម**)	៨៨
២៩	គិតទៅ	(ដោយ ភិក្ខុកល្យាណេរតោ **ខាន់ ស៊ិនសេម**)	៨៩
៣០	សម្តីបុគ្គល ៤យ៉ាង	(ដោយ ភិក្ខុកល្យាណេរតោ **ខាន់ ស៊ិនសេម**)	៩២
៣១	ទុកស្រីប្តីប្រម៉ឹក	(ដោយ ភិក្ខុកល្យាណេរតោ **ខាន់ ស៊ិនសេម**)	៩៤
៣២	ទុក្ខប្តីសែនធូន់ប្រពន្ធលេងល្បែង	(ដោយ ភិក្ខុកល្យាណេរតោ **ខាន់ ស៊ិនសេម**)	៩៦
៣៣	ម៉ាំទោសបន្ថិចសិន	(ដោយ ភិក្ខុកល្យាណេរតោ **ខាន់ ស៊ិនសេម**)	៩៨
៣៤	ផ្កាល្បូក	(ដោយ ភិក្ខុកល្យាណេរតោ **ខាន់ ស៊ិនសេម**)	១០០
៣៥	ទឹកភ្នែកមេម៉ាយ	(ដោយ ភិក្ខុកល្យាណេរតោ **ខាន់ ស៊ិនសេម**)	១០២
៣៦	ទំនួញកូនមិនស្តាប់ឪម៉ែ	(ដោយ ភិក្ខុកល្យាណេរតោ **ខាន់ ស៊ិនសេម**)	១០៥
៣៧	ជីវិតពិត	(ដោយ ភិក្ខុរតនបញ្ញោ **ប៉ាក់ សំអាត**)	១០៦
៣៨	ជំនឿក្រៅព្រះពុទ្ធសាសនា		១០៨
៣៩	ជាតិជាចៅអធិការ	(ដោយ ធម្មបណ្ឌិត **ម៉ៅ គឹមម៉េង**)	១១០
៤០	កំហុសចៅអធិការ	(ដោយ ធម្មបណ្ឌិត **ម៉ៅ គឹមម៉េង**)	១១១
៤១	ពាវចនាផ្កាបិណ្ឌ	(ដោយ ធម្មបណ្ឌិត **ម៉ៅ គឹមម៉េង**)	១១២
៤២	ជាតិជាគណៈកម្មការ	(ដោយ ធម្មបណ្ឌិត **ម៉ៅ គឹមម៉េង**)	១១៥
៤៣	គុណសម្បត្តិគណៈកម្មការ	(ដោយ ធម្មបណ្ឌិត **ម៉ៅ គឹមម៉េង**)	១១៦
៤៤	បរាភវសូត្រ	(សៀវភៅប្រជុំភាណវារៈ កៅ ឈិន)	១១៧

១_បទលើកតម្កើងព្រះពុទ្ធសាសនា

សូមមើលទង់ជ័យ ឆព្វណ្ណរង្សី ដែលមានរស្មី ភ្លឺស្រស់ល្អ
ខៀវលឿងក្រហម ព្រមទាំងពណ៌ស ហង្សបាត និងពណ៌ ដ៏ភ្លឺផ្លេក ។
ប្រទេសតូចធំ បានស្ម័គ្រស្មោគម ជុំនុំគ្នាច្រើន អនេក
ព្រមយករស្មី ព្រះពុទ្ធតួរត្រេក ប្រសើរពន់ពេក ក្រៃកន្លង
ធ្វើជាសញ្ញា ទង់ជ័យសាសនា នៃសមុទ្ទធំ ចម្បង
ចូរយើងរាល់គ្នា យកចិត្តចាំចង ទឹកដល់ព្រះអង្គ ជាអម្ចាស់ ។
ទោះជាតិផ្សេងគ្នា ក៏ត្រូវដឹងថា សុទ្ធសឹងតែជា ពុទ្ធសាសនិ៍
ត្រូវសាមគ្គីគ្នា ទាំងក្មេងទាំងចាស់ ប្រឹងប្រែងឱ្យណាស់ គ្រប់ៗគ្នា ។
យើងសាសនាពុទ្ធ ថ្កុំថ្កើងខ្ពស់ផុត រុងរឿងវិសុទ្ធ ថ្លៃថ្លា
ហើយមានជ័យជោគ ផ្សាយពេញលោកា ដល់ជនជ្រះថ្លា ច្រើនរាប់សែនលាន ។
មានចិត្តស្មោះ គោរពបូជា ចំពោះព្រះធម៌ ដ៏កល្យាណ ទាំងមនុស្សទេវតា
ស្នេហាគ្រប់ប្រាណ ប្រាថ្នាចង់បាន សេចក្ដីសុខ ។
យើងខេមរៈជាតិ នាំគ្នាខ្មីឃ្មាត កាន់ធម៌នឹងបាន ផុតទុក្ខ រួបរួមសាមគ្គី
ពីនេះទៅមុខ ជាតិយើងបានសុខ ក្សេមក្សាន្តត្រាណ ។
ព្រមព្រៀងប្រព្រឹត្ត កាន់ធម៌សុចរិត ឆ្ពោះទៅកាន់ឋាន និព្វាន
ជាទីផុតទុក្ខ បានសុខក្សេមក្សាន្ត ជាតិយើងនឹងបាន សោយសុខា ។

២. កំណាព្យក្មេងទំនើង

-បវរមខ្ញុំកូណោ **ខាន់ ស៊ិនសេម** មុនចារពាក្យផ្ដើមសូមវន្ទា
ក្រាបថ្វាយបង្គំព្រះភគវា ព្រះពុទ្ធទ្រង់ជាសាស្ដាចារ្យ ។
-និងសូមបង្គំព្រះធម៌ថ្លៃ សែនល្អប្រពៃក្នុងលោកា
នាំសត្វឱ្យផុតវដ្ដសង្សារ រួចផុតទុក្ខាពីអបាយ ។
-សូមថ្វាយបង្គំដល់ព្រះសង្ឃ ប្រសើរសីលត្រង់ល្អឆើតឆាយ
គឺជាស្រែបុណ្យមនុស្សទាំងឡាយ ខ្ញុំសូមឱនកាយថ្វាយគារវៈ ។
-ម្យ៉ាងទៀតសូមក្រាបថ្វាយបង្គំ រៀមច្បងតូចធំដោយស្មោះស្ម័គ្រ
លោកជាបណ្ឌិតបញ្ញាជាក់ សូមឱ្យលោកអ្នកប្រោសប្រណី ។
-ព្រោះខ្ញុំពុំសូវមានបញ្ញា ចាំស្ទាត់អក្ខរាសព្វសេចក្ដី
ចារតែងពាក្យកាព្យបែបកវី ទោះខុសឆ្គងក្ដីសូមមេត្តា ។
-គ្រានេះសូមតែងថ្លែងសេចក្ដី ពីឈ្មោះយុវវ័យក្នុងលោកា
ទាំងគ្រប់សារជាតិគ្រប់សាសនា ឥឡូវឈ្មោះថាក្មេងទំនើង ។
-ពាក្យនេះពីដើមមិនមានទេ បច្ចុប្បន្នស្រាប់តែលេចធ្លោឡើង
សំភារៈទំនើបក្មេងទំនើង ករកើតជាភ្លើងឆេះសង្គម ។

-ព្រោះក្មេងទំនើងទំនើបណាស់ មិនស្តាប់ពាក្យចាស់ស្ដីអប់រំ
ធ្វើស្រាច់តែចិត្តឥតរមទម តាំងចិត្តគំនំគុំគួនគេ ។
-មួយថ្ងៃៗដើរសប្បាយ ផឹកស៊ីឡូយឆាយឥតទំនេរ
ស្រវឹងរើលងុលឥតយសកេរ្តិ៍ ឡូឡាស្រែកជេរពាសពេញផ្លូវ ។
-ការងារមិនធ្វើដើរតែខូច ធ្វើចោរដើរលួចឥតគិតគូរ
ទ្រព្យអ្នកដទៃឬទ្រព្យឪ យកវឹងចេញទៅលក់បញ្ចាំ ។
-បើបានប្រាក់មកលោកមើលចុះ ស្រាបៀរចំរះច្រុសមិនស្រាំ
ថែមបន្តគ្នាជាប្រចាំ ផឹកស៊ីសាំញ៉ាំមិនស្តាយប្រាក់ ។
-ស្រវឹងម្តងៗតាំងស្រែកហ៊ោរ វាជិះម៉ូតូហោះមិនដាក់
ឆ្វេឆ្វាពេញផ្លូវឥតសួរជាក់ ខ្លះប្រហែសធ្លាក់ក្នុងស្នាមភ្លោះ ។
-ពេលចេញឡើបាំហ្គោរីមូលគីប ផ្តាច់លេខជាន់ផ្លឺបរិបបង្ហួស
ហុយផ្សែងទ្រលោមគួរព្រឺជួស ព្រោះធ្វើនេះហួសពីការស្មាន ។
-ជិះហោះៗជោរពេញថ្នល់ មិនយូរនឹងដល់បាពុំខាន
ជិះជ្រែឆាបឆ្វៀងឆ្វៀងផ្គងប្រាណ វ៉ាមុខក្រោយបានឥតញញើត ។
-បើមានបុណ្យធំចាំមើលចុះ ទំនើងស្រីប្រុសច្រុសជ្រួសជ្រើស
ពូនផ្គុំប្រគុំមើលខនស៊ើត លិចត្បូងជើងកើតឥតទំនេរ ។

-បើគ្រាន់តែមើលវាមិនថ្វី ថែមទាំងតប់វាយឈ្លោះដៀលជេរ
ក្រញេងក្រញាងសាងឥតកើ្ត គ្មានហិរិទេភ្លេចក្តីល្អ ។
-ម៉ែឪនៅផ្ទះសែនព្រួយខ្លាច ព្រោះកូនកោងកាចឥតគុណធម៌
ឆេវឆាវឆាបឆេះឥតស្គាល់ល្អ ប្រព្រឹត្តបន្តរឿងអាស្រូវ ។
-មានភឿនពួកម៉ាកគ្រប់និគម មូលជួបប្រជុំតាមដងផ្លូវ
ជក់ម៉ាអាភៀនញៀនដល់ឪ មិនគិតខុសត្រូវខំសិក្សា ។
-ដល់ពេលស្រវឹងគ្មានដឹងគិត ប្រឹងតែប្រព្រឹត្តចិត្តឫស្យា
ភ្លេចម៉ែភ្លេចឪញាតិការ បាត់បង់បញ្ញាប្រៀបមនុស្សស្លាប់ ។
-រឿងម៉ាអាភៀនគ្រឿងញៀនក្តី ដូចជនប្រុសស្រីធ្លាប់ឃើញស្រាប់
វានឹងសំឡេះនឹងសម្លាប់ ឱ្យរូបយើងស្លាប់ទាំងអាសោចិ៍ ។
-បើមិនស្លាប់ខ្លួនក៏ស្លាប់យស ស្អុយកើ្តស្អុយឈ្មោះជាងស្អុយខ្មោច
ស្អុយខ្មោចស្អុយខ្ទីអស់ប្រយោជន៍ បញ្ជាស់ខ្យល់ល្មោចគ្រប់កន្លែង ។
-ម៉ែឪរកប្រាក់ទាំងត្រដរ សន្សំដល់ក ខំរអែង
សន្សំមាសប្រាក់គាត់គិតក្រែង ខ្លាចកូនរិងឯងក្រជាងគេ ។
-ម្លឹងហើយកូននៅមិនដឹងខ្លួន ថាពុកម្តាយស្ងួនឥតទំនេរ
ធ្វើការកាប់គាស់ឥតងាករេ មិនត្អូញត្អែរទេព្រោះតែកូន ។

-អាកូននោះវិញមិនអាណើតម៉ែ ទាមទារទាល់តែស្មើរតែសូន្យ
យកមកបំផ្លាញអស់ពីខ្លួន ធ្វេសប្រហែសជូនជួបគ្រោះថ្នាក់ ។
-សិក្សារៀនសូត្រមិនខំទេ ខំប្រឹងដៀលដេរឈ្លោះកាប់ចាក់
នាំរឿងមកតែភាពបែកបាក់ គ្មានសាមគ្គីជាក់គ្មានបញ្ញា ។
-ចាប់ពីថ្ងៃនេះតទៅមុខ សូមកូន១ពុកត្រូវឱស្សាហ៍
កុំខំប្រព្រឹត្តរឿងស្រីស្រា វាគ្មានបានការទេកល្យាណោ ។
-បញ្ញើតស្រីប្រុសមានច្រើនណាស់ ចូរខំប្រវាស់ចិត្តសន្តាន
ស្តាប់ពាក្យទូន្មានលោកឱ្យបាន នោះទើបបានក្សាន្តសុខមនោរម្យ ។
-ពាក្យពេចន៍ម៉ែឪត្រូវប្រឹងស្តាប់ វោហារសារស័ព្ទនាំសុខុម
នាំកូនឱ្យផុតទុក្ខសែនធំ ឆ្ពោះកាន់ទ្រនំក្តីសុខសាន្ត ។
-ចូរអ្នកបំរើពុកម្តាយខ្លួន គួរថេះថៃធួនលោកឱ្យបាន
ម្ហូបចំណើត្រីសាច់កុំឱ្យខាន ថ្នាក់ថ្នមសន្តានចិត្តម៉ែឪ ។

-គ្មានពាក្យសម្តីងណោល្អស្មើនឹងពាក្យទូន្មានរបស់ឪពុកម្តាយយើងឡើយ

-ឪពុកម្តាយគឺជាគ្រូដ៏ប្រសើរបំផុតរបស់កូនប្រុសស្រី

-ឪពុកម្តាយគឺជាបុព្វាចារ្យដ៏ឆ្នើមរបស់កូនប្រុសស្រី

-ឪពុកម្តាយគឺជាព្រះអរហន្តរបស់កូនប្រុសស្រី

-ឪពុកម្តាយគឺជាម្លប់ដ៏ត្រជាក់សម្រាប់ឱ្យកូន១ជ្រក

ដោយ ភិក្ខុកល្យាណរតោ ខាន់ សុិនសេម

កំណាព្យចាស់នាំនើង

-ពីដើមចាស់ៗ រមទមល្អហោស់ ព្រោះចាស់រចះគិត
ខុសពីឥឡូវ ចាស់ឆៅគំនិត ឈ្លក់វង្វេងពិត
និងល្បែងស្រីស្រា ។

-ទ្រព្យធនមានគ្រប់ មិនពិតសេពគប់ ស្វែងរកធម៌អារ្យ
ខំប្រឹងឡូយឆាយ សក់ល្បាយអាចម៍ខ្លា ចាយសុទ្ធដុល្លារ
ទាក់រកស្រីក្មេង ។

-អាងខ្លួនមានប្រាក់ ចូលពាញ់រញ៉ាក់ នឹងតន្ត្រីភ្លេង
ខារ៉ាអូខេ បំពេស្រីក្មេង វីវក់វង្វេង
ភ្លេចប្រពន្ធកូន ។

-ពេលខ្លួនស្រវឹង ចិត្តចូរភ្លេចតឹង ភ្ញុកស្លឹងស្មើរសូន្យ
រាំស្លូរាំញាក់ ចង្វាក់ម៉ាឌីហ្សុន ដៃកែវឡើងទន់
ភ្លេចអស់កេរ្តិ៍ខ្មាស ។

-ពេលផឹកម្តងៗ ច្រៀងផងបោករផង សាសងដេរដាស
ផឹកចូលនឹងក្មេង ភ្លេចខ្លួនឯងចាស់ ស៊ីជោរខ្លាំងហោស់
ធ្វើផ្តាសគ្រប់យ៉ាង ។

-ស្រា ស ស្រាថ្នាំ ផឹកជាប្រចាំ មិនខ្មាសញាតិខាង
តាមតៀមតាមតូប តាមបាឬបាង ផឹកគ្មានថ្ងៃស្វាង

ភ្នែកបើកមិនរួច ។

-ពេលផឹកអស់លុយ តក់ម៉ក់ទុយមុយ ប្រថុយចេះលួច
ខ្លួនចាស់កោងខ្នង ដើរមិនចង់រួច ឆ្វេសប្រហែសធ្វួច
លួចគោអ្នកស្រុក ។

-លក់បានប្រាក់ភ្លាម ដើងនៅមិនស្ងៀម រវាមតាត្រុក
ស្វែងរកដៃគូ ពួកម៉ាកក្លើក្លុក ផឹកពេញតែស្រុក
ឥតញ៊ីនថ្ងៃណា ។

-ពេលវិលមកផ្ទះ ភ្នែកបើកមិនច្បាស់ តេះតះស្រវ៉ា
ត្រេងត្រាងពេញផ្លូវ ង៉ែង៉ូវឡូឡា ជេរដាក់ផ្កាសា
នឹងកូនចៅឯង ។

-ប្រាសដេកនទៀល ហាលក្តៅហាលវាល ស្រែកយំក្តែងៗ
ក្អកក្អួតចង្អោរ សំពោរហូរឯង កូនចៅ ៣ សែង
យកដេកក្នុងផ្ទះ ។

-ព្រឹកមាន់រងាវ ពោះកូរកញ្ជ្រៀវ ស្រវារូតរះ
តម្រង់តៀមស្រា បាវដាស់ម្ចាស់ផ្ទះ ដកមេយ៉ាងចាស់
ធ្លាក់ភ្នែកទាំងព្រឹក ។

-នេះចាស់ស្រាថ្នាំ ធ្លាប់ឃើញប្រចាំ គួរជួយរំលឹក
ខុសចាស់ស្រាបៀរ ធៀបគ្នាគួរភ្លឹក ហួសចិត្តមិននឹក

ស្មានក៏មិនដល់ ។

-រីចាស់ស្រាបៀរ សែនពាលពាលា មើលស្មើរមិនយល់
ពាក់អាវហ្វាហៀរ ពាក់ខោទិមល លុចស៊ីសឆេះស៊ុល
ត្បុលចូលក្នុងបា ។

-សក់ក្បាលសព្រាត ថែមធ្មេញបាក់ទៀត នៅឆ្មៀតសង្ហារ
ចូលកាស៊ីណូ ហ៊ោរល្បែងស្រីស្រា ចំណោយដុល្លារ
ទិញទឹកចិត្តស្រី ។

-បើបានលេងឈ្នះ សប្បាយចិត្តណាស់ មុខស្រស់ប្រិមប្រិយ៍
ចេញពីហាងមួយ ចូលហាងពីរបី លុចស៊ីសម៉ូតថ្មី
សប្បាយភ្លេចខ្លួន ។

-អាងខ្លួនមានប្រាក់ ទិញស្រីមកដាក់ ពីរបីក្បែរខ្លួន
ឆ្វេងមួយស្តាំមួយ មុខក្រោយផ្ទួនៗ សប្បាយភ្លេចខ្លួន
កើតអេដស៍អាយវី ។

-ខ្លួនកើតអេដស៍ហើយ គ្មានគិតអ្វីឡើយ ចម្លងខ្ចេចខ្ចី
ទាំងក្មេងទាំងចាស់ ឆ្លងគ្រប់ទិសទី រោគអេដស៍អាយវី
សម្លាប់ស្មើរពាយ ។

-បើពេលចាញ់វិញ ចិត្តសែនទោម្នេញ គ្មានក្នាញ់ក្រហាយ

លក់សព្វពោរពាស មាសប្រាក់មិនស្តាយ លក់ដីទៅចាយ
លេងល្បែងបន្ត ។

-ប្រពន្ធខំហាមប្តី ថាកុំលក់អី អូនសូមអង្វរ
ខ្លាចកូនចៅយើង ថ្ងៃមុខវាក្រ បងអើយកុំត
លេងល្បែងទៀតអី ។

-ទោះហាមម្តេចម្តា បើគំនិតតា សាវ៉ាអប្រិយ៍
ចាក់បៀអាប៉ោង ចោងហោងម្តេចក្តី ចាក់រាល់តែថ្ងៃ
លះអស់សម្បត្តិ ។

-បើកូនចៅរៀន តាខំទូន្មាន កុំឱ្យធ្វើត្រាប់
ថាធ្វើតាមតា ជីវ៉ាអួរអ័ព្ទ ជៀសឱ្យប្រញាប់
កុំត្រាប់តាមតា ។

-កូនចៅធ្វើតាម តាខំប្រឹងហាម គំរាមស្តីថា
តែនៅមិនស្តាប់ ព្រោះត្រាប់តាមតា ទោះហាមយ៉ាងណា
ក៏នៅតែធ្វើ ។

-តាហាមកូនចៅ កុំឱ្យចេញក្រៅ ពីផ្ទះអំពើ
ថាស្តីឱ្យគេ តែខ្លួនឯងធ្វើ វ៉ាឥតអំពើ
ហាមគេម្តេចស្តាប់ ។

-ព្រោះចាស់ហ្នឹងហើយ លោកយាយតាអើយ គឺជាដើមច្បាប់
ព្រោះតាចាស់ហើយ មិនយូរឡើយនឹងស្លាប់ គួរតែប្រញាប់
ស្វែងរកធម៌អារ្យ ។

-យើងជាកូនខ្មែរ សម័យកាលសុទ្ធតែ ជឿព្រះពុទ្ធសាសនា
រាប់សិបសតវត្ស កន្លងមកហើយណា គួរតែយាយតា
ទឹកឃើញវត្តផង ។

-នៅពេលសព្វថ្ងៃ ខ្មែរ ចិន យួន ថៃ សុទ្ធមានបំណង
សិក្សារៀនសូត្រ គឺជាចម្បង ព្រោះអាចចម្លង
សត្វទៅនិព្វាន ។

-ការកើតជាមនុស្ស ទាំងស្រីទាំងប្រុស គួរតែសូត្ររៀន
ទាំងផ្នែកពុទ្ធចក្រ អាណាចក្រក៏មាន នោះគឺជាស្ពាន
ឆ្លងទៅសួគ៌ា ។

-ចាស់ក្តីក្មេងក្តី ទាំងប្រុសទាំងស្រី ត្រូវខំពះពារ
កុំធ្វេសប្រហែស ក្នុងកម្មនានា ព្រោះអាយុសង្ខារ
សុទ្ធតែមិនទៀង ។

-រាល់ការរស់នៅ ម្តងត្រជាក់ម្តងក្តៅ ម្តងរាំងម្តងភ្លៀង
ម្លោះហើយជីវិត មនុស្សសត្វមិនទៀង រស់គួរជៀសវាង

ពីកម្មអកុសល ។

-ពាក្យពេចន៍ទាំងនេះ អាត្មាភាពត្រិះរិះ ជ្រោងឱ្យបានផល
មិនមែនតិះដៀល ឆ្លឹះឆ្លៀលគួរយល់ ញ៉ាំងតាឱ្យដល់
សុខសួគ៌និព្វាន ។

-មិនមែនសើចយំ ចាស់ៗដែលខំ សន្សំសីលទាន
ព្រោះអាត្មាថានេះ ចាស់ឥឡូវខ្លះមាន ព្រោះអីអាត្មាបាន
ឃើញផ្ទាល់នឹងភ្នែក ។

-បើមានឆ្គាំឆ្គង ខុសពីទំនង សូមជួយបែងចែក
អាត្មាសរសេរនេះ អាត្មាចេះរំលែក ល្អទុកមួយប៉ែក
កុំអន់ចិត្តអី ។

-បើមានការខុស ញាតិញោមស្រីប្រុស សូមលោកអភ័យ
ដល់ខ្ញុំព្រះករុណា អាត្មាភាពនៅខ្ចី សូមតាប្រណី
ដោយក្ដីអនុគ្រោះ ។

ដោយ ភិក្ខុកល្យាណរតោ **ខាន់ សុិនសេម**

៤-ដែលហៅថាមនុស្សពាល

-ចំពោះមនុស្សពាល ពោពាសពេញវាល ពាលមានច្រើនណាស់
នៅតាមនិគម ស្រុកខេត្តមិនខ្វះ ពោពាសដេរដាស
សព្វគ្រប់តំបន់ ។

-ពាលក្មេងពាលចាស់ ពាលនៅក្នុងផ្ទះ ដេរដាសគ្រប់ធុន
ទាបខ្ពស់ខ្មៅ ស ចិត្តឆៅមិនទទន់ ឬហៅទុរជន
ដើរបោកប្រាសគេ ។

-ពាលខ្លះនៅក្មេង ប្រើស័ព្ទសម្លេង ពាក្យផ្អែមឥតទ្វេ
លួងលោមបញ្ឆោត ប្រើកល់ឥតកើ្ត គ្មានហិរិទេ
ឱ្យតែបានផល ។

-ពាក្យផ្អែមពាលពិត ចូរអ្នករិះគិត គំនិតឈ្វេងយល់
ព្រោះពាលនេះណោ សិក្សាឱ្យដល់ វាជាកង្វល់
ដល់សង្គមជាតិ ។

-ពាលមានក្មេងចាស់ ស្រីប្រុសមិនខ្វះ គ្រប់សាសន៍គ្រប់ជាតិ
អាស៊ីអ៊ឺរ៉ុប មានគ្រប់សារជាតិ ពាសពេញព្រោងព្រាត
នៅក្នុងលោកា ។

-ពាលខ្លះជាស្រី ប្រើពាក្យសម្ដី ពីរោះអស្ចារ្យ
ឬក្បរាងហានហំ រមទមហ៊ឺហា តែចិត្តមុសា
រកលេខដាក់គ្មាន ។

-ពាលខ្លះជាប្រុស ខ្លួននៅក្មេងសោះ មិនគិតខំរៀន
ដើរបោកប្រាសគេ ធ្វើឫក្សឯងហ៊ាន មិនយូរនិងមាន
ទោសធ្លាក់ដល់ខ្លួន ។

-ឯពាលជាចាស់ និយាយល្អណាស់ តាមគម្ពីរក្បួន
តាំងនាមអាចារ្យ ធម៌អារ្យពេញខ្លួន ធ្វេសប្រហែសជួន
លួចលុយវត្តចាយ ។

-ពាលចាស់បែបហ្នឹង បើក្មេងៗដឹង ប្រាកដជេរម្ដាយ
ថាខ្លួនចាស់ហើយ ម្ដេចឡើយធ្វើងាយ លួចលុយវត្តចាយ
មិនខ្លាចនរក ។

-អញ្ចឹងហើយពាល នាំក្ដៅរោលរាល ពាសវាលវីវក់
ក្រាស់ដោយតណ្ហា មោហាងោកងក់ ងប់វង្វេងឈ្លក់
នឹងកាមឆន្ទៈ ។

-ពាលមានគ្រប់យ៉ាង តាមបុគ្គលសាង មិនរើសវណ្ណៈ
ខ្ពស់ទាបខ្មៅ ស អាក្រក់ល្អមានជាក់ សូមឱ្យលោកអ្នក

កុំភ្លេចស្មារតី ។

-ចូរអ្នកខំលះ ទិដ្ឋិមានះ ចិត្តពាលអប្រិយ៍
ខំប្រព្រឹត្តល្អ ទើបមានសិរី កេរ្តិ៍ឈ្មោះល្បាញល្បី
រន្ទឺសព្វសាយ ។

-កូនប្រុសកូនស្រី កូននៅក្មេងខ្ចី ត្រូវហ៊ានបរិយាយ
ទង្វើខ្លួនឯង ប្រាប់ដល់ពុកម្តាយ ក្រែងធ្លាក់អបាយ
ដោយភ្លេចស្មារតី ។

-រួសរាន់ប្រញាប់ កែខ្លួនឱ្យឆាប់ បើជ្រុលអប្រិយ៍
សុចរិតធម៌ស បវរប្រពៃ ចូរកូនលកលៃ
ទាន់ខ្លួននៅក្មេង ។

-ដល់ពេលខ្លួនចាស់ ពិបាកកែណាស់ ព្រោះចាស់វង្វេង
រៀនមុខភ្លេចក្រោយ ញយៗលេងៗ តារៀនចាញ់ក្មេង
ព្រោះតែតាចាស់ ។

-បើខ្លួនចាស់ហើយ កុំបង្អង់ឡើយ តាមពុទ្ធតម្រាស់
ឱ្យចូលវត្តវ៉ា រៀនធម៌អារ្យខ្លះ ព្រោះខ្លួនជាចាស់
មានតែសុំសីល ។

-ខំប្រឹងប្រព្រឹត្ត សច្ចៈសុចរិត ចូរគិតកុំខ្ជិល

ញ៉ាំងចិត្តឱ្យមោះ ឱ្យអស់មន្ទិល ងោកងក់រិលរស់
ទើបផុតអបាយ ។
-ផ្លូវធម៌មានច្រើន នាំមនុស្សឱ្យកើន ចម្រើនស្រស់ស្រាយ
ញ៉ាំងឱ្យសត្វលោក ជ័យជោគសប្បាយ ផុតទុក្ខទាំងឡាយ
បានសុខក្សេមក្សាន្ត ។

● ពន្លឺអ្វីក៏មិនភ្លឺស្មើនឹងពន្លឺបញ្ញាឡើយ

● ក្លិនក្រអូបអ្វីក៏មិនក្រអូបស្មើនឹងក្លិននៃព្រះធម៌ឡើយ

● រសជាតិអ្វីឆ្ងាញ់
ក៏មិនឆ្ងាញ់ដល់រសជាតិនៃព្រះធម៌ឡើយ

● ស្អាតរបស់អ្វីៗក៏ដោយ ក៏មិនស្មើនឹងស្អាតចិត្តឡើយ

-ការសន្សំបុណ្យទាំងទាំងឡាយ គឺជាការប្រសើរបំផុតសម្រាប់មនុស្សយើងគ្រប់ៗរូប ។

ដោយ កល្យាណរតោ **ខាន់ ស៊ិនសេម**

៥-កូនបីជំពូក

-ព្រះពុទ្ធជិកា ទ្រង់ប្រោសទេសនា ប្រដៅសព្វសត្វ
ឱ្យមានបញ្ញា ភ្លឺថ្លាក្រៃក្លាត់ ឱ្យចេះចែកកាត់
តាមកម្មកុសល ។
-រឿងបុត្រធីតា ក្នុងលោកនេះណា មានច្រើនមិនខ្វល់
គ្រូខ្លះមានតិច គ្រូខ្លះមានដល់ ១០តាមកម្មផល
ដែលខ្លួនបានសាង ។
-ទោះច្រើនអនេក ព្រះពុទ្ធទ្រង់ចែក វែកតាមសំណោង
ថាមានបីពិត ព្រះពុទ្ធទ្រង់អាង តាមបុគ្គលសាង
មកពីបុព្វេ ។
-មួយ**អតិជាតបុត្រ** កូនល្អបំផុត ក្នុងសាសនេ
ក្នុងចិត្តបរិសុទ្ធ មោះមុតឥតទ្វេ សែនល្អដាច់គេ
រកមនុស្សប្រៀបគ្មាន ។
-ចេះសព្វចេះគ្រប់ ការងារថ្ងៃយប់ មិនហត់ទូន្មាន
ធ្វើបុណ្យដាក់បាត្រ សង្ឃាតសីលទាន ឧស្សាហ៍សូត្ររៀន

ឥតប្រហែសធ្វេស ។

-ស្គាល់ល្អអាក្រក់ មិនគិតឡេះឡោះ កុហក់ចចេស
រមទមរាបសា បញ្ញាស្វាងថែស ស្វែងរកតម្រិះ
ញ៉ាំងចិត្តឱ្យល្អ ។

-ស្គាល់ការស្មោកគ្រោក ចិត្តមិនងក់ងោក ក្នុងអកុសលធម៌
ជំរះសន្ដានចិត្ត សុចរិតស្មោះ ស មិនមានត្រេកអរ
ក្នុងកាមឆន្ទះ ។

-ចេះញ៉ាំងកុសល ឱ្យកើតមានដល់ ឪពុកម្ដាយអ្នក
ព្រមទាំងបងប្អូន ញាតិសន្ដានជាក់ មិនឱ្យភ្លាត់ធ្លាក់
ក្នុងជ្រោះអវិចី ។

-នេះកូនទីមួយ មិនដែលឱ្យព្រួយ ឪពុកម្ដាយអី
រក្សាត្រកូល កិត្តិស័ព្ទល្បាញល្បី ញាតិមិត្តប្រុសស្រី
ស្រឡាញ់បំផុត ។

-ឯកូនទីពីរ ក៏ល្អសោភី ឈ្មោះ**អនុជាតបុត្រ**
ឧស្សាហ៍គ្រាន់បើ មិនចេះរោលដុត ញ៉ាំងខ្លួនឱ្យផុត
ពីអបាយទុក្ខ ។

-ការងារក្នុងផ្ទះ ខំប្រឹងរូតរះ ធ្វើយ៉ាងសំរុក

ទោះធ្ងន់ស្រាលក្តី មិនខ្ជីដាក់ទុក ការងារគ្រប់មុខ

មិនហត់មាត់ម៉ែ ។

-ការងារឆ្ងាយជិត យប់ថ្ងៃភ្លឺល្ងិត ឥតមានត្អូញត្អែរ

កាប់គាស់រាស់កាយ ដីចំការស្រែ ជួសមុខឪម៉ែ

មិនឱ្យមានព្រួយ ។

-មិនថាការផ្ទះ ខំប្រឹងប្រែងណាស់ ទោះគ្មានគេជួយ

មិនមានមូទូ រអ៊ូរលួយ ចិត្តមានតែមួយ

គឺធ្វើឱ្យហើយ ។

-មិនត្រឹមការងារ សីលទានភាវនា ក៏មិនកន្តើយ

ផ្ចិតផ្ចង់ទន្ទេញ សូត្ររៀនឥតស្បើយ មិនប្រមាថឡើយ

ក្នុងកិច្ចទាំងពួង ។

-មិនយកបាណោ អទិន្នាទានា សុរាជាភ្លួង

គេចវេះតណ្ហា មុសាជាជួង នាំឱ្យកើតឃ្លួង

លង់ក្នុងអប្រិយ៍ ។

-អវជាតបុត្រ អាក្រក់បំផុត ឈ្មោះបុត្រទីបី

កូនគ្មានកំណើត ចិត្តឆើតអប្រិយ៍ តែងគំនិតខ្ជី

ដើរលេងសប្បាយ ។

-ការងារមិនធ្វើ មិនចេះអើពើ គិតតែស៊ីចាយ
ហ៊ឺហាហំហាន ហ៊ឺកហ៊ាក់ឡូយឆាយ ផឹកស៊ីសប្បាយ
នាំទុក្ខដល់ឪ ។

-ការងារតូចតាច គ្មានប្រិតគ្មានប្រាជ្ញ តបតមិនគួរ
រអ៊ូរទាំ ចិត្តមាំក្រម៉ូវ ក្បាលរឹងដល់ឪ
គ្មានស្តាប់អ្នកណា ។

-អបាយទាំងបួន យកមកដាក់ខ្លួន មិនសួនអាត្មា
ប្រព្រឹត្តទាំងអស់ គ្មានទាស់ត្រង់ណា គ្មានគិតវាសនា
អនាគតខ្លួន ។

-មួយថ្ងៃៗ ស៊ីគ្មានសំចៃ ធ្វើឬក្សងហួន
លក់កេរ្តិ៍ម៉ែចាយ ឥតស្តាយថៃធួន លក់ជាប់ផ្ទួនៗ
មិននឹកស្រណោះ ។

-មិនយូរប៉ុន្មាន អាកូនតិរច្ឆាន វាបំផ្លាញអស់
បំផ្លាញទាំងទ្រព្យ បំផ្លាញទាំងយស វាបំផ្លាញអស់
គ្មានសល់អ្វីឡើយ ។

-នេះកូនទីបី ហៅកូនចង្រៃ រាល់ថ្ងៃគ្មានស្បើយ
ចូរខំអប់រំ កុំនៅកន្តើយ ក្រែងបានល្ហែរល្ហើយ

រស់សុខនឹងគេ ។

-រីកូនទាំងបី ពីរល្អឥតបី សែនល្បីយសកេីរ្ត៍
ឪពុកម្តាយបានជួប នៃកូនទាំងទ្វេ ដកកូនមួយទេ
ពិតជាប្រសើរ ។

-អ្នកជាកុលបុត្រ ត្រូវជៀសឱ្យផុត បុត្របីកុំដើរ
វានាំឱ្យខ្ខូច អាសោចីដំណើរ មគ្គមិនប្រសើរ
កុំដើរល្អជាង ។

-យើងត្រូវត្រិះរិះ នៅលើលោកនេះ អ្វីសុទ្ធមិនទៀង
ត្រូវខំប្រព្រឹត្ត ចិត្តល្អឥតល្បៀង បាបកម្មត្រូវវាង
ស្វែងរកកុសល ។

-ចំណែកផ្លូវល្អ គឺផ្លូវព្រះធម៌ ខំដើរឱ្យដល់
នោះទើបនឹងបាន គ្រៀមក្សាន្តឱ្យផល ព្រះធម៌នាំដល់
បានសុខសួគ៌ា ។

កូនប្រុសកូនស្រី សូមកូនទាំងបី ត្រូវចេះសាមគ្គា
អាណិតពុកម៉ែ ថៃព្រះព្រហ្មា ទើបប្រាកដជា
ហៅថាកូនល្អ ។

ដោយ កល្យាណរតោ **ខាន់ ស៊ិនសេម**

៦.សង្គហធម៌របស់មាតាបិតា ៥យ៉ាង

(ជាធមិសម្រាប់សង្គ្រោះដល់កូនប្រុសកូនស្រីទាំងឡាយ)

-ប្រាំរោចឆ្នាំឆ្លូវឯកស័ក ភទ្របទខែងជាក់ចន្ទគតិ
កន្លងមកបានថ្កានជាអតិ ពីរពាន់ប្រាំរយហាសិបបី ។
ត្រូវជាថ្ងៃពុធទីប្រាំបួន ខែកញ្ញាជូនសកលថ្មី
ពីរពាន់ប្រាំបួនសាសន៍គ្រឹស្តនៃ ពួកជនប្រុសស្រីធ្លាប់ស្គាល់ស្រាប់ ។
-ខ្ញុំព្រះករុណា **ខាន់ ស៊ិនសេម** ចេញចារពាក្យផ្អែមនឹងថ្លែងប្រាប់
នូវសង្គហធមិដែលជាច្បាប់ តាមព្រះតម្រាប់ទ្រង់បានផ្តាំ ។
-សង្គហធមិមាតាបិតា កូនប្រុសស្រីរ៉ាត្រូវចងចាំ
ព្រះពុទ្ធទ្រង់ប្រោសសត្វរាប់ឆ្នាំ ច្បាស់ថាមានប្រាំចាំជាក្បួន ។

-ទី១ បាបានិវារេន្តិ កំចាត់អាស្វិមានះពីខ្លួន
វៀរចាកទុច្ចរិតទាំង១០ផ្ទួន អស់ពីក្នុងខ្លួនកុំប្រព្រឹត្ត ។
-ញ៉ាំងកូនឱ្យវៀរអកុសល ដែលមិនជាផលល្អក្នុងចិត្ត
ត្រូវជៀសឱ្យឆ្ងាយកុំនែបនឹត ទើបឈ្មោះកូនពិតមានសិរី ។

-ទី២ កល្យា ណេនិ វេសេន្តិ ឱ្យមានទិដ្ឋិល្អប្រពៃ
ញ៉ាំងកុសលធមិល្អថ្លាថ្លៃ ផ្ទុកក្នុងដួងចៃល្អម៉ត់ចត់ ។

-ម៉ែនាំឱ្យកូនចេះធ្វើបុណ្យ ស្គាល់ទោសស្គាល់គុណយ៉ាងប្រាកដ
មិនធ្វេសប្រហែសឱ្យកូនភ្លាត់ អកុសលសង្កត់បានឡើយណា ។
- ទី៣ សិប្បំ សិក្ខា បេន្តិ ម៉ែមានសតិល្អថ្លៃថ្លា
បង្ហាត់បង្រៀនសព្វវិការ សីលសាស្ត្រវិជ្ជាដល់កុលបុត្រ ។
-ម៉ែនាំឱ្យកូនទៅសាលា ដើម្បីសិក្សាឱ្យគត់មត់
ពីថ្នាក់បឋមដល់ឧត្តមផុត មិនឱ្យកូនស្រុតធ្លាក់អវិជ្ជា ។
-ទី៤ បដិរូបេនទា រេនសំយោជេន្តិ ម៉ែគ្មានអគតិក្នុងទ័យា
ពេលកូនមានវ័យវឌ្ឍនា ឪពុកម្តាយគ្រប់គ្នាតែងរៀបចំ ។
-ឱ្យកូនមានគូតាមប្រពៃ តាមស្ម័គ្រមេត្រីឥតបង្ខំ
ជ្រើសរើសពង្សផៅឥតច្រឡំ ផ្គួផ្គងផ្សំផ្គុំតាមទំនៀម ។
-ទី៥ សមយេ ទាយជ្ជំ នេយ្យោ ទេន្តិ ម៉ែមានហិរិចិត្តព្យាយាម
បង្ហាញទ្រព្យធនឥតលាក់លៀម ចែកតាមទំនៀមកាលសម័យ ។
-ទោះបីគ្រួសារក្របមាន ទឹកចិត្តម៉ែគ្មានសោកអាល័យ
បែងចែកឱ្យកូនគ្មានសង្ស័យ ដល់កូនប្រុសស្រីឥតរួញរា ។
-នេះហើយទឹកចិត្តឪពុកម្តាយ មិនឃ្លាតចាកឆ្ងាយពីកូនភ្ងា
អាក្រក់ល្អ ស ខ្មៅក៏គង់ជា អ្នកម្តាយការពារមិនឱ្យសូន្យ ។
-យប់ថ្ងៃល្ងាចព្រឹកនឹកជានិច្ច ម៉ែចាំមិនភ្លេចនឹកតែកូន

ព្រួយទៅថ្ងៃក្រោយរលាយខ្លួន　ឱស!ឱ រូបកូនទៅយ៉ាងណា　។

-ម៉ែចិញ្ចឹមកូនម៉ែថ្នាក់ថ្នម　បំពេបីបមដោយករុណា

ងូតទឹកដុសក្អែលសព្វកាយា　ចិត្តស្នេហ៍ប្រាថ្នាឱ្យកូនសុខ　។

-កាលកូននៅតូចមិនដឹងក្តី　សព្វនំចំណីម៉ែបញ្ចុក

ទោះរឹងឬទន់ទំពារបុក　យកមកបញ្ចុកឱ្យកូនញ៉ាំ　។

-ទោះក្រលំបាកឬយ៉ាងណា　ពុកម៉ែធ្វើការយ៉ាងសស្រាំ

សន្សំប្រាក់ទុករៀងរាល់ឆ្នាំ　ទម្រាំកូនធំចូលសាលា　។

-ពេលកូនចូលរៀនម៉ែអរណាស់　ព្រោះភ្នែកឃើញច្បាស់កូនសិក្សា

សង្ឃឹមថ្ងៃក្រោយបានធ្វើការ　បណ្ឌិតរាជការឬមន្ត្រី　។

-ឪម៉ែអរណាស់ឃើញកូនរៀន　មាសប្រាក់ធនធានមិនមានក្តី

ស៊ូស៊ីឈ្នួលគេទាំងយប់ថ្ងៃ　សន្សំកំរៃទុកឱ្យកូន　។

-មិនថាបឋមមធ្យមសិក្សា　វិទ្យាល័យបរិញ្ញាប្រឹងលុះសូន្យ

តស៊ូរកប្រាក់លុះខ្លួនសូន្យ　ឱ្យតែរូបកូនមានក្តីសុខ　។

-នេះទឹកចិត្តម្តាយឪពុកយើង　កូនភ្ញាក់ខ្លួនឡើងកុំស្មាញស្មុគ្រ

ត្រូវគិតដល់ម្តាយនិងឪពុក　ទើបកូនបានសុខតរៀងទៅ　។

ដោយ កល្យាណរតោ **ខាន់ ស៊ិនសេម**

ចំពោះទឹកចិត្តម្តាយឪពុកគ្រប់ៗរូប សូម្បីតែបន្តិច ក៏មិនចង់ឱ្យ កូនៗ មានក្តីលំបាកឡើយ សុខចិត្តពិបាកខ្លួនឯងវេទនាខ្លួនឯង ឱ្យ តែកូនមាន សេចក្តីសុខ ។ ម្លោះហើយ សូម សាធុជន សប្បុរស ស្រី ប្រុស ទាំងអស់ ដែលមាន នាទី ជា កូនប្រុស កូនស្រី ចៅប្រុស ចៅ ស្រី ក្មួយប្រុស ក្មួយស្រី គួរ តែចំណាយពេលវេលាឱ្យបានច្រើនបន្តិច ដើម្បីគោរព ប្រតិបត្តិ មាតា បិតា ជីដូន ជីតា របស់យើងពីព្រោះ កើតមកជា មនុស្ស វាកម្រក្រៃពេកណាស់ ដូច្នេះហើយគួរតែយើងរាល់គ្នាខំប្រឹងបំពេញតួនាទីក្នុងនាម ជាកូនប្រុសកូនស្រី ឱ្យបាន ច្រើនទើប ល្អប្រសើរ ។ ម្យ៉ាងវិញទៀតការបំរើ មាតា បិតា ដោយ ប្រពៃ នោះ

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងថា:

(ជាអ្នកប្រកបនូវបុណ្យរឿយៗគ្មានទំនេរឡើយ ហើយបើបែកកាយទំលាយខ័ន្ធ និង បានទៅកើតនៅឯទេវលោកជា ពុំខាន ។

ដូច្នេះហើយសូមកូនប្រុសកូនស្រីទាំងឡាយគួរតែខំធ្វើនូវគារវកិច្ចចំពោះអ្នកមានគុណឱ្យបានច្រើនទើបល្អប្រពៃ ហើយសមជាកូនខ្មែរពិតៗ!!!

ដោយ ព្រះភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**

៧-កូនអើយធម៌សាមគ្គី

-កូនអើយធម៌សាមគ្គី គឺមូលមីរញ្ញាតិមិត្តភ័ក្រ
រួមគ្នាច្រើនអនេក នោះពិតជាក់ខ្លាំងកន្លង ។
-ប្រៀបចង្កឹះមួយបាច់ គេមិនកាច់បាក់បានផង
បើមួយកាច់តែម្តង ដូចបំណងបាក់បានងាយ ។
-ដូច្នេះកូនជាមនុស្ស ទាំងស្រីប្រុសកុំរាយមាយ
ខំរួមមិត្តវេចស្លាយ កុំរាយមាយនាំបែកបាក់ ។
-យើងមើលប្រាង្គប្រាសាទ សែនល្អស្អាតមានចម្លាក់
រៀបថ្មបន្ទុបដាក់ ច្រើនឡើងជាក់កើតអង្គរ ។
-នេះគឺមកពីផ្សំ ពីមួយដុំទៅដាក់គរ
រៀបផ្តេកឬបញ្ឈរ កើតអង្គរយ៉ាងស្រស់ទៀត ។
-មិនត្រឹមតែស្អាតទេ ថែមកើតកេរ្តិ៍នៃសាសន៍ជាតិ
បរទេសច្រើនព្រោងព្រាត មិនចង់ឃ្លាតស្ញើចសរសើរ ។
-នេះហើយគឺសាមគ្គី ច្រើនមូលមីរជាដំណើរ
ឱ្យកូនឈានជើងដើរ តាមដំណើរមគ្គសុខសាន្ត ។

-ដូច្នេះយើងរាល់គ្នា ត្រូវសាមគ្គាគ្រប់ៗប្រាណ
ទាំងស្រីទាំងប្រុសប្រាណ នោះទើបក្សាន្តសុខប្រចាំ ។
-បើគ្មានភាពសាមគ្គា ទាស់ទែងគ្នារាល់ខែឆ្នាំ
ទុក្ខសោកកើតប្រចាំ រាល់ខែឆ្នាំពុំមានស្បើយ ។
-នាំឱ្យកើតសង្គ្រាម បង្ហូរឈាមមិនផុតឡើយ
ចូរជៀសចេញកូនអើយ កុំកន្តើយភ្លេចស្មារតី ។
-ត្រូវសំអាតកាយចិត្ត សាងសុចរិតពិតប្រពៃ
សាមគ្គីរាល់យប់ថ្ងៃ ទើបសិរីកើតមានបាន ។
-ត្រូវប្រឹងប្រែងសិក្សា ក្បួនតម្រាណោកល្យាណ
គម្ពីរបិដកមាន បង្ហាញស្ថានទៅសួគ៌ា ។
-មានតែព្រះពុទ្ធថ្លៃ ព្រះធម៌បីព្រះសង្ឃា
សូមកូនៗគ្រប់គ្នា ជួយការពារថែរក្សា ។
-ផ្លូវល្អមានច្រើនណាស់ ព្រះអង្គត្រាស់ប្រោសទេសនា
កូនខំផ្ទៀងសោតា ទើបបញ្ញាកើតឡើងមាន ។
-គ្មានអ្វីស្មើព្រះធម៌ ឆើតស្រស់ល្អជាធនធាន
ញ៉ាំងសត្វឱ្យកើតមាន សុខក្សេមក្សាន្តដរាបអើយ ។

ដោយ ភិក្ខុកល្យាណោរតោ **ខាន់ សុិនសេម**

៨_នាទីស្វាមីសង្គ្រោះភរិយា ៥យ៉ាង

(បទពាក្យប្រាំពីរ)

-នាមជាស្វាមីត្រូវមានចិត្ត សច្ចៈសុចរិតពិតសោភា
ត្រូវមានចិត្តស្មោះនឹងភរិយា ទើបឱ្យឈ្មោះជាស្វាមីល្អ ។

-ព្រះពុទ្ធទ្រង់ត្រាស់ប្រទានថា មានប្រាំប្រការសង្គហធម៌
សង្គ្រោះដល់ភរិយាដោយស្មោះស ទើបកើតឈ្មោះល្អគ្រប់ៗគ្នា ។

-ទី១ សមាននាយៈ មានចិត្តស្មោះស្ម័គ្រល្អសោភា
ស្រឡាញ់រាប់អានថាភរិយា ឧត្តមថ្លៃថ្លាក្នុងសង្គម ។

ទី២ អវិមាននាយៈ ពោលពាក្យរាក់ទាក់ល្អសមរម្យ
មិនត្រូវមើលងាយវាយបង្ខំ ត្រូវចេះអប់រំដោយខន្តី ។

-ទី៣ អនតិចរិយាយៈ ចងចាំឱ្យជាក់ខ្លួនជាប្ដី
មិនត្រូវប្រព្រឹត្តក្បត់ចិត្តស្រី ត្រូវមានមេត្រីស្មោះជានិច្ច ។

-ទី៤ ឥស្សរិយ វោស្សគេនៈ ដួងចិត្តចាំជាក់កុំឱ្យភ្លេច
ខ្លួនជាស្វាមីកុំបែរគេច ផ្ដល់សិទ្ធិធំស្រេចជូនភរិយាស្រី ។

-ទី៥ អលង្ការានុប្បទានេនៈ ក្នុងនាមភារៈជាស្វាមី
ត្រូវចេះតុបតែងយកចិត្តស្រី ចិញ្ចៀនខ្សែដៃពេជ្រកែវកង ។

-ក្នុងនាមជាប្តីត្រូវប្រយ័ត្ន ត្រូវចេះអារកាត់ការពារផង
រឿងហេតុតូចតាចដែលកន្លង គួរចេះឃុំគ្រងឱ្យប្រសើរ ។
-ការងារឆ្ងាយៗ ធំៗក្តី យើងជាស្វាមីត្រូវចេញដើរ
ទទួលរាប់រងសព្វអន្លើ ទោះ ខ្លា ក្រពើ ក៏ត្រូវហ៊ាន

ដោយ កល្យាណរតោ **ខាន់ ស៊ិនសេម**

៩-នាទីភរិយាត្រូវប្រតិបត្តិស្វាមី ៥យ៉ាង

(បទពាក្យ ៧)

-ព្រះពុទ្ធទ្រង់ត្រាស់ប្រោសទេសនា ដល់មនុស្សទេព្តាសព្វសារពើ
ឱ្យចេះប្រព្រឹត្តសព្វអន្លើ រកការងារធ្វើដោយសុចរិត ។

-ប្រោសប្រាប់ស្ត្រីជាភរិយា ឱ្យមានមុខងារល្អប្រណីត
ឱ្យចេះសង្គ្រោះស្វាមីពិត តាមពុទ្ធដីកាពិតមានប្រាំយ៉ាង ។

-ទី១ សុសង្គហិត កម្មន្តា ភរិយាចាត់ការល្អស្អិតស្អាង
រៀបចំម្ហូបចំណីផ្ទះឬហាង ឱ្យស្វាមីម្ចាងយ៉ាងឆ្អិតឆ្ងង់ ។

-ទី២ សុសង្គហិ តបរិជនា សង្គ្រោះញាតិកាប្តីឱ្យត្រង់
ទោះមានឬក្រកុំបោះបង់ មានចិត្តស្មោះត្រង់ស្មើញាតិខ្លួន ។

-ទី៣ សម្ភតញ្ច អនុរក្ខតិ ត្រូវមានគតិចេះថៃធួន
រក្សាសម្បត្តិដែលប្តីខ្លួន ទុកឱ្យខ្ជាប់ខ្ជួនល្អប្រពៃ ។

ទី៤ អនតិ ចារិនី រមទមសោភីស្មោះនឹងប្តី
មិនត្រូវមានចិត្តចើកអប្រិយ៍ ក្បត់ពីស្វាមីភ្លេចកូនចៅ ។

-ទី៥ ទក្ខាចហោតិ អនលសា សព្វកិច្ចេសុ រៀបចំវត្ថុចបពូថៅ
កិច្ចការក្នុងផ្ទះឬខាងក្រៅ ទុកដាក់ឱ្យនៅសមកន្លែង ។

● គប្បីឆ្លៀវឆ្លាសក្នុងការងារ នាមជាភរិយាត្រូវចាត់ចែង
កុំខ្ជិលច្រអូសត្រូវរំអែង សព្វទីកន្លែងក្នុងគេហា ។

● បោកគក់លក់ដូរចូរព្យាយាម ព្រោះជាទំនៀមត្រូវឧស្សាហ៍
ទើបមានឈ្មោះល្អដ៏ថ្លៃថ្លា ឧត្តមភរិយានៃស្វាមី ។

● បើប្ដីបានឃើញចិត្តស្មោះស ចរិយាបវរល្អប្រិមប្រិយ៍
មានចិត្តរីករាយមានសិរី មានឈ្មោះល្បាញល្បីក្នុងសង្គម ។

* បុគ្គលប្រព្រឹត្តនូវកម្មអ្វីឯណាមួយហើយ ហើយបែរទៅជាមាន សភាព ក្ដៅ រោលរាលជាខាងក្រោយ កម្មនោះពិតជាមិនល្អប្រសើរឡើយ ។

* តែបើបុគ្គលប្រព្រឹត្តនូវកម្មឯណាមួយហើយ ហើយមិនមានសភាព ក្ដៅរោលរាលជាខាងក្រោយទេនោះ កម្មនោះពិតជាល្អប្រសើរ ។

ដោយ កល្យាណោរតោ **ខាន់ សុិនសេម**

យរាវាសធម៌ ៤យ៉ាង

(បទកាកគតិ)

-វិនាមបញ្ញត្តិ ឧបជ្ឈាលោកចាត់ កល្យាណរតោ
ភិក្ខុ ខាន់ ស៊ិនសេម ថ្ងៃច័ន្ទថែងម៉ោ សម្មតិសង្ឃោ
ឧបសម្បទា ។

-នេះនឹងថ្វាថ្លែង ស៊ិនសេមចារតែង ឃរាវាសធម្មា
បែបបទពាក្យកាព្យ កំណាព្យកាព្យា ប្រព្រឹត្តត្រៃ (១) ទ្វា
តកូនចៅរៀន ។

-ឃរាវាសធម៌ ភារៈសែនល្អ គ្រហស្ថត្រូវមាន
ប្រែថាជាធម៌ សម្រាប់គេហដ្ឋាន ប្រុសស្រីគ្រប់ប្រាណ
ចងចាំឱ្យជាក់ ។

-ឃរាវាសធម៌ ព្រះពុទ្ធបវរ ព្រះអង្គទ្រង់ត្រាស់
ថាមានបួនយ៉ាង ពិតប្រាកដណាស់ ទាំងក្មេងទាំងចាស់
ត្រូវមានគ្រប់គ្នា ។

-ទី១សច្ចៈ ប្រែជាខេមរៈ ពិតត្រង់សោភា
មិនមានងាករេ បែកបែរពីគ្នា គឺពាក្យត្រង់ជា

ប្រៀបដូចបន្ទាត់ ។

១-ត្រៃទ្វា.ឬ ត្រ័យទ្វា -ប្រែថា: ទ្វាទាំងបី (កាយទ្វា ១. វចីទ្វា ១ . មនោទ្វា ១) . ឬហៅថា (កាយ . វាចា ចិត្ត) ។

-ទោះក្មេងចាស់ក្តី ទាំងប្រុសទាំងស្រី ត្រូវចេះចាំស្ទាត់
យកមកប្រព្រឹត្ត កុំស្តីឱ្យភ្លាត់ ពោលឱ្យប្រាកដ
កុំមានមុសា ។

-សច្ចៈគឺពិត វចីសុចរិត បណ្ឌិតលោកថា
ញុំាងសត្វឱ្យផុត វាលវដ្តសង្សារ អនិច្ចំ ទុក្ខា
អនត្តាជាហេតុ ។

-ទាំងតូចទាំងធំ ទោះទាំងភូមិឃុំ និគមឬខេត្ត
ធ្វើអ្នកដឹកនាំ ចូរកុំបណ្តែត ព្រោះអាចនាំហេតុ
ឱ្យកើតរឿងឈ្លោះ ។

-ពិសេសយុវវ័យ ទាំងប្រុសទាំងស្រី ស្តីឱ្យពីរោះ
ស្មោះត្រង់នឹងគ្នា សាមគ្គាទើបរស់ បានលោកឱ្យឈ្មោះ
ថាជាក្មេងល្អ ។

-ចំណែកចាស់ៗ ពិតប្រាកដណាស់ ត្រូវច្បាស់នឹងធម៌
មិនត្រូវបណ្តោយ ឱ្យធ្លោយចាកធម៌ ធ្វើកុសលល្អ
ជាគំរូក្មេង ។

យុវវ័យស្តាប់ណាស់ ពុំនោលចាស់ៗ ពោលពិតពោលលេង
និយាយលែបខាយ ផ្សព្វផ្សាយក្មេងៗ នាំឱ្យវង្វេង
ឈ្លក់នឹងតណ្ហា ។

បើតាមការពិត ចាស់ៗគួរគិត ឱ្យក្រិត្យតម្រា
ពន្យល់ក្មេងៗ កុំក្លែងវាចា ឱ្យមានខ្លឹមសារ
មើលតាមគម្ពីរ ។

ពីព្រោះរឿងព្រេង អ្នកប្រាជ្ញខ្លះតែង កំប្លែងឥន្ទ្រីយ៍
ពន្យល់ឱ្យមនុស្ស បំផុសសំភី ស្វែងរកវិធី
កេងចំណេញប្រាក់ ។

លោភនិងលាភពេក ភ្លេចគិតបែងចែក ពីការបែកបាក់
ជ្រុលពោលពាក្យហួស ជួសលើសអក្ខរៈ ភ្លេចពាក្យសច្ចៈ
នាំឱ្យចង្រៃ ។

ក្បួនតម្រាខ្លះ អ្នកតែងមិនច្បាស់ នាំឱ្យសង្ស័យ
ធាតុដើមពាក្យសាប កែទៅជាប្រែ កើតហេតុបច្ច័យ
ជជែកបែកផ្សេង ។

ពោលអ្វីក៏ដោយ ចូរកុំបណ្តោយ នាំឱ្យវង្វេង

ត្រូវកាន់សច្ចៈ ឱតប្បៈចេះក្រែង កុំអួតខ្លួនឯង
ហួសពីការមាន ។

ទី២ ទមៈ បាលីពិតជាក់ ប្រែថាទូន្មាន
អប់រំស្រីប្រុស ឱ្យចេះធ្វើទាន ទោះបីក្រមាន
ឱ្យចេះសង្គ្រោះ ។

បើឃើញគ្នាខុស ទោះបីស្រីប្រុស កុំពោលត្រគោះ
ត្រូវជួយរំលឹក សាមគ្គីទើបរស់ បើគ្នាជ្រុលជ្រួស
ត្រូវចេះកែខៃ ។

ព្រះពុទ្ធដីកា ព្រះធម៌ចែងថា ព្រះសង្ឃឱ្យន័យ
ទេសនាប្រោសសព្វ ទោះមនុស្សសត្វក្តី នៅលើលោកិយ៍
មិនរើសវណ្ណៈ ។

ម្តងគេម្តងយើង កំហុសកើតឡើង ពិតប្រាកដជាក់
ទោះមានឬក្រ ក៏គង់មានវាក់ ញ៉ាំងចិត្តឱ្យធ្លាក់
ក្នុងមោហៈម្តង ។

ឃើញយ៉ាងនោះហើយ អ្នកកុំកន្តើយ ត្រូវចេះត្រកង
ពន្យល់ប្រាប់ហេតុ រឿងដែលកន្លង ទោះប្អូនឬបង

ឱ្យចេះខន្តី ។

កុំអាងខ្លួនចាស់ ក្មេងប្រាប់ខ្ជិលណាស់ មានៈស្មារតី
តិះដៀលក្មេងថា ឯងនាំក្មេងខ្ចី ម្ដេចមកស្រដី
ប្រៀនប្រដៅអញ ។

មានចាស់ខ្លះខ្លៅ ក្មេងៗប្រដៅ ចិត្តឆៅមិនចាញ់
គ្រហឹមគំហ៊ក សៀតសឹកបណ្ដេញ ឱ្យក្មេងៗចេញ
អាងខ្លួនផឹកស្រា ។

ទូន្មានទមៈ បណ្ដិតថែងដាក់ ឆ្លាក់ក្នុងតម្រា
ជាធម៌ប្រសើរ ដំណើរថ្លៃថ្លា មនុស្សក្នុងលោកា
គួរប្រតិបត្តិ ។

ទាំងចាស់ទាំងក្មេង ចូរកុំរង្វេង ថ្លែងឱ្យប្រយ័ត្ន
ចេះទូន្មានគ្នា ឱ្យជាមធ្យ័ត ត្រូវឱនចិត្តកាត់
ដាក់ខ្លួនឱ្យកែ ។

ទមៈទូន្មាន ក្មេងចាស់ត្រូវបាន កុំអៀននឹងថៃ
ឃើញខុសត្រូវថា ចាប់ផ្ចារបង្វែរ អប់រំទាល់តែ
ក្លាយជាមនុស្សល្អ ។

ទូន្មានទៅមក គឺជាជម្រក ជ្រកយ៉ាងបវរ
សម្រាប់គ្រហស្ថ ឱ្យស្មោះចិត្តល្អ ផ្តល់សាមគ្គីធម៌
ឱ្យល្អគ្រប់ធុន ។

ទី៣ ខន្តី ជាពាក្យបាលី ប្រែថាអត់ធន់
ចូរប្រឹងប្រយ័ត្ន សង្កត់ចិត្តធ្ងន់ កុំឱ្យស៊័យស៊ន់
ធ្លាក់ក្នុងអបាយ ។

ខន្តីមានច្រើន នាំមនុស្សឱ្យកើន បញ្ញាស្រស់ស្រាយ
អាចនាំឱ្យសត្វ ឆ្លងផុតអបាយ ផុតទុក្ខទាំងឡាយ
រសាយបាត់អស់ ។

ខន្តីអំពោត់ អ្នកប្រាជ្ញាកត់ ជាទ្រព្យរបស់
ធ្វើឱ្យសត្វលោក មានជោគចិត្តស្មោះ នឹងលះចោលអស់
នូវបាបធម៌ ។

បើគ្មានខន្តី មនុស្សលោកសព្វថ្ងៃ គ្មានន័យបវរ
ករកើតរឿងឈ្លោះ ជម្លោះបន្ត កើតអកុសលធម៌
ពាសពេញនិគម ។

ចូរអ្នកប្រយ័ត្ន បើប្រហែសបាត់ ពិតជាស៊័យធំ

អត់ធ្មត់នេះឯង កន្លែងសុខុម អ្នកត្រូវសន្សំ
ទើបល្អប្រពៃ ។

អត់ធន់នេះពិត អ្នកប្រាជ្ញបណ្ឌិត លោកថាមានបី
ទីមួយថ្នាក់ខ្ពស់ ពីរកណ្តាលន័យ ចំណែកទីបី
អត់ធន់ថ្នាក់ទាប ។

អត់ធន់ថ្នាក់ខ្ពស់ បណ្ឌិតឱ្យឈ្មោះ កុំឈ្លោះនឹងលាភ
បើមានលោភៈ ឥស្សរៈ (១) ធ្លាក់ទាប នាំកើតសភាព
អន្តរាយមិនខាន ។

ពីរកណ្តាលន័យ ទោសៈនោះអី កុំខ្ជីបៀតប្រាណ
ត្រូវគេចឱ្យផុត ពន្លត់ឱ្យបាន ទើបអ្នកក្សេមក្សាន្ត
ដល់ឋានផុតទុក្ខ ។

ចំណែកទីបី ព្រះពុទ្ធជិនស្រី ស្តីជាប្រមុខ
មោហៈនោះឯង វង្វេងគ្មានសុខ ចូរអ្នកចាំទុក
កុំធ្វេសប្រហែស ។

លោភៈទោសៈ ហើយនឹងមោហៈ អ្នកកុំចចេស
លះចែកឱ្យត្រូវ តាមផ្លូវកុំធ្វេស បើអ្នកប្រហែស
ច្បាស់ជាខូចការ ។

បុណ្យនិងកុសល ប្រុសស្រីត្រូវយល់ ឱ្យស្គាល់ច្បាស់ថា
ញ៉ាំងសន្តានចិត្ត ល្អល្អិតជ្រះថ្លា នោះទើបឈ្មោះថា
ជ្រះថ្លាល្អល្អះ ។

ទី៤ចាគះ បាលីពិតជាក់ ប្រែថាការលះ
កំហោញ់គ្រប់យ៉ាង ក្នុងចិត្តឱ្យជ្រះ ព្រមទាំងមានះ
ពីខ័ន្ធសន្តាន ។

បើចង់ធ្វើបុណ្យ អ្នកកុំទំរន់ ត្រូវលះឱ្យបាន
កាត់ផ្តាច់លោភៈ ទោសៈបាំងប្រាណ លះចោលកុំខាន
ច្រានមោហៈទៀត ។

អកុសលបើ អស់ពីហឫទ័យ ប្រុសស្រីត្រូវឆ្លៀត
បំពេញកុសល ដល់ថ្ងៃមុខទៀត កាយយើងបែកឃ្លាត
មានទ្រព្យជាស្រេច ។

កើតមនុស្សក្រោយ ចូរចាំឱ្យច្បាស់ ត្រៀមខ្លួនចាំបាច់
ធ្វើបុណ្យដាក់ទាន ទើបមានញាតិសាច់ ទោះសង្ខារផ្តាច់
ក៏មិនជាថ្វី ។

(១) ឥស្សរៈ ឬ -(អិសសៈរ៉ៈ) គុ. ន (ដំណើរស្រេចនិងចិត្ត) បុគ្គលជាឥស្សរៈ (ឥស្សរៈជន (បុគ្គលជាធំ) ភាពនៃអ្នកធំ)

ចាគៈលៈហើយ អ្នកកុំកន្តើយ បំពេញបារមី

សុំសីលនមស្សការ ព្រះរតនត្រៃ ជារៀងរាល់ថ្ងៃ
ទើបល្អប្រសើរ ។

ចាគៈលៈដល់ ចូរអ្នកឈ្វេងយល់ ធម៌ជាដំណើរ
អដ្ឋង្គិកមគ្គ នាំអ្នកឱ្យដើរ គឺជាដំណើរ
ឆ្ពោះទៅនិព្វាន ។

កាត់ផ្តាច់តណ្ហា ធ្វើបុញ្ញកិរិយា រក្សាសីលទាន
តាមព្រះតម្រាស់ នៃព្រះទ្រង់ញាណ ថាគឺជាស្ពាន
ទៅស្ថានសួគ៌ា ។

សច្ចៈ ទមៈ ខន្តី ចាគៈ ចូរអ្នករាល់គ្នា
សិក្សាប្រតិបត្តិ អនុវត្តន៏គ្រប់គ្នា ដាក់ក្នុងត្រៃទ្វារ
កុំបីកន្លង ។

ធម៌ទាំងបួននេះ ជាយានជំនិះ ជិះកាត់ចម្លង
ឱ្យរួចចាកទុក្ខ ទាំង១២កង បានដូចបំណង
ដល់ត្រើយក្សេមក្សាន្ត ។

-មនុស្សគេយកសម្តីដំរីគេយកភ្លុក ចាស់ចារជាទំនុកទុកប្រដៅ
នាងនួនខ្លឹមក្នុងឫស្សីខ្លឹមក្រៅ ខ្លឹមមនុស្សសំដៅនូវពាក្យសច្ចៈ ។
-ននោងខ្ពស់បានដោយសារទ្រើង ចំណែកមនុស្សយើងខុសគ្នាស្រឡះ
បើមិនធ្វើល្អក្រពេកមានយស ទ្រើងមនុស្សបានខ្ពស់ព្រោះតែបញ្ញា ។

ដោយ ភិក្ខុកល្យាណោរតោ **ខាន់ សុិនសេម**

១១- ត្រូវតែត្រដររស់

(បទកាកគតិ)

ថ្ងៃអាទិត្យ២៨ សូរិយាគងព្រៃ នៃខែកញ្ញា
៩កើតខែអស្សុជ ឯកស័កនេះណា កកើតបញ្ញា
ចារបទកវី ។

ពាក្យពេចន៍ថ្លាថ្លែង បែបបទចារតែង ចែងពីអត្ថន័យ
ត្រូវតែត្រដររស់ ឈ្មោះប្រធានបទថ្មី ដែលលោកប្រុសស្រី
ធ្លាប់ឃើញរាល់ថ្ងៃ ។

ព្រោះមនុស្សក្នុងលោក មានច្រើនគគោក ទាំងប្រុសទាំងស្រី
ខ្លះមានខ្លះក្រ អាក្រក់ល្អម្ដេចក្ដី ក៏គង់មានភ័យ
ក្នុងវដ្ដសង្សារ ។

នៅក្នុងទីនេះ អាត្មាត្រិះរិះ យកមករៀបរាប់
ចំពោះអាក្រក់ នៅក្នុងលោកា ទុកជាតម្រា
គ្រាន់វិនិច្ឆ័យ ។

មានច្រើនសន្ទាប់ បើសិនរៀបរាប់ ឃើញជាប់រាល់ថ្ងៃ
ក្នុងផ្សារក្នុងភូមិ និគម [១] ខេត្តក្ដី ឬនៅតាមព្រៃ
ពោរពាសមិនខ្វះ ។

(១) និគម ឬ និគំ៖ (ភូមិដែលចាស់) ឬ ភូមិដែលមានមនុស្សនៅសព្វថ្ងៃ ឬពីមុន)

មិនថាមានក្រ សុទ្ធតែត្រដរ តស៊ូខ្លាំងណាស់
គឺដើម្បីរស់ ពិតប្រាកដច្បាស់ ទាំងក្មេងទាំងចាស់
ខ្លាចហោស់ការស្លាប់ ។

ឃើញទេអស់លោក ក្រគ្មានទ្រព្យភោគ ផ្ទះជ្រកសែនយ៉ាប់
បាំងមុខបាំងក្រោយ ភ្លៀងរោយសាចសាប់ រងារស្ទើរស្លាប់
ទទឹកគ្មានសល់ ។

ទោះក្រម្តេចម្តារ ធ្វើស្រែចំការ ប្រាថ្នាយកផល
មកចិញ្ចឹមខ្លួន តាមកម្មកុសល រស់ត្រដរខ្យល់
តាមព្រេងវាសនា ។

ខ្លះស៊ីឈ្នួលគេ គ្មានថ្ងៃទំនេរ ស្វែងរកអាហារ
ចិញ្ចឹមក្រពះ រួតរះគ្រប់គ្រា បើខ្ជិលខ្ជីខ្ជា
ពិតជាស្លាប់ខ្លួន ។

ទោះជាពិបាក រខោករខាក ក៏ខំមិនខាន
ព្រោះអីខ្លួនក្រ ត្រដរឱ្យបាន ទោះបីស្លាប់ប្រាណ
ក៏ខំតស៊ូ ។

ទាំងថ្ងៃទាំងយប់ គេងមិនបានស៊ប់ ចិត្តងប់មួទូ
ប្រឹងប្រែងធ្វើការ ឧស្សាហ៍គ្មានគូ ទ្រាំមិនរអ៊ូរ

ខ្លាចដាច់ក្រពះ ។

អញ្ជឹងហើយក្រ ទាល់តែត្រដរ ប្រញាប់រូតរះ
ប្រឹងស៊ីឈ្នួលគេ កាប់ឆ្ការជម្រះ បានពេញក្រពះ
ទាំងក្តីលំបាក ។

ពេលឈឺម្តងៗ សព្វសសៃយ៉ង ស្គមឱ្យរខាក
គ្មានថ្នាំព្យាបាល រាំរៃតោកយ៉ាក ជម្ងឺគ្មានស្រាក
ស្ទើរដាច់ខ្យល់ស្លាប់ ។

សុភមង្គល មិនដែលមានដល់ ស្រពោនអួរអាប់
រស់ទាំងត្រដរ ក្រីក្រសព្វស័ព្ទ លំបាកជាងស្លាប់
រស់នៅគ្មានន័យ ។

នេះហើយកម្មផល នឹងកើតមានដល់ បុគ្គលប្រុសស្រី
ជាតិមុនអ្នកមាន ធនធានសេដ្ឋី មានចិត្តអប្រិយ៍
ដើរធ្វើបាបគេ ។

អាងមានសក្តិយស បង្ករឿងឈ្លោះ ដើរបោកប្រាសគេ
មិនដែលធ្វើបុណ្យ សុន្ទរីទាននឹងគេ គិតកល់ឥតគេ
នឹងល្បែងស្រាស្រី ។

ពេលមានជីវិត មិនខំរិះគិត សេពគប់កវី

សប្បុរសគគោក មិនយកត្រាប់អី ខំតែគិតខ្ចី
ប្រឹងឆីតាមឃ្លាន ។
រឿងមានប្រយោជន៍ មិនខំស្រង់ស្រោច ឧស្សាហ៍ធ្វើទាន
ប៉ៃឡៃប៉ោឡោ អាងខ្លួនឯងមាន ធ្វើឫក្សឯងហ៊ាន
មិនខ្លាចនរក ។
ពេលខ្លួនស្លាប់ទៅ អកុសលជាប់នៅ ចុតិ (១) ងោកងក់
ទៅបដិសន្ធិ នាឋាននរក វិលវល់វិវក់
ក្នុងភពអបាយ ។
ដល់មកជាតិនេះ កម្មតាមឈ្នានីស ឱ្យអ្នកអន្តរាយ
ព្រោះពៀរតាមចង ចំណងពីនាយ ឱ្យក្ដៅក្រហាយ
គ្មានក្ដីសុខសាន្ត ។
ហើយចះទ្រាំទៅ ស៊ូទ្រាំរស់នៅ តាមមានតាមបាន
ព្រោះកម្មហុចផល មិនផ្ដល់ឱ្យក្សាន្ត ស៊ូលំបាកប្រាណ
ឱ្យតែខ្លួនរស់ ។
ក្រលំបាកក្ដី សូមអ្នកលកលៃ ដើម្បីកេរ្ដិ៍ឈ្មោះ
ធ្វើបុណ្យដាក់ទាន ទាន់មានជីវិតរស់ កសាងកិត្តិយស

(១) ចុតិ -ចុ- តិ =រលត់ (បើចំពោះមនុស្ស ចុតិសង្ខារ គឺរលត់នូវសង្ខារ) ការរលត់ទៅ ។

ឱ្យបានស្រស់ថ្លា ។

តិចច្រើនក៏ដោយ បើធ្វើញយៗ ឱ្យតែឧស្សាហ៍

ព្យាយាមតាំងចិត្ត សុចរិតត្រៃទ្វា នោះអ្នកពិតជា

បានរួចចាកទុក្ខ ។

ចូរកុំប្រហែស ថ្ងៃនៅភ្លឺថែស កុំធ្វេសជ្រប់មុខ

ធ្វើបុណ្យដាក់បាត្រ សង្ឃាតសុំសុខ តទៅជាតិមុខ

បានសុខសាន្តអើយ ។

-កិច្ចជាកុសលគួរខំធ្វើ

-វិជ្ជាចេះស្ទើរគួរបំពេញ

-អកុសលមាននៅគួរលះចេញ

-ជួញបានចំណេញគួរខំជួញ ។

ដោយ **ភិក្ខុកល្យាណរតោ ខាន់ ស៊ិនសេម**

១២_អាសូរចិត្តម៉ែ

ម៉ែអើយអើយម៉ែ ពីរោះម្ល៉េះទេ ពាក្យម៉ែនេះណា
កូនខំស្រែកហៅ ម៉ែនៅទីណា កូនសែនខ្លោចផ្សា
អាសូរចិត្តម៉ែ ។

ស្រណោះណាស់ម៉ែ អស់ប្រាំបួនខែ អ្នកម៉ែ ពផ្ទៃ
ម៉ែទ្រាំចាញ់គភ៌ ទាំងញ៉ូរល្វីតល្វៃ នេះព្រោះអាស្រ័យ
កូនផ្ញើជីវិត ។

លំបាកប៉ុណ្ណឹងហើយ ម៉ែមិនកន្តើយ ឥតស្បើយតែងគិត
ព្រោះភ័យខ្លាចកូន សោះសូន្យជីវិត ម៉ែគេងព្រួយចិត្ត
ចង់ឃើញមុខកូន ។

ប្រាំបួនខែដប់ថ្ងៃ កូននៅក្នុងផ្ទៃ ម៉ែភ័យស្ទើរសូន្យ
ពេលញ៉ាំពេលគេង ម៉ែតែងថ្នមខ្លួន ញ៉ាំចំណើស្ងួន
ព្រោះខ្លាចកូនឈឺ ។

ម៉ែផ្ញើដំណើរ ម៉ែឈានជើងដើរ ម៉ែព្រួយសែនព្រី
ចុះទឹកឡើងទួល ខ្លាចដួលខ្លាចឈឺ ទោះយប់ល្ងិតភ្លឺ
ម៉ែថ្នមកូនណាស់ ។

ពេលឆ្លងទន្លេ លំបាកម្ល៉េះទេ ឈឺពោះក្រៃក្រាស់

ស្ទើរក្ស័យជីវិត ចោលបុត្រពេកណាស់ នឹកដល់គុណព្រះ
សូមជួយរក្សា ។
ពេលឆ្លងទុក្ខធំ ម៉ែព្នកូនយំ ខំបើកនេត្រា
សម្លឹងមើលកូន ទាំងខ្លួនមិនជា ម៉ែអរក្រៃណា
សើចទាំងទឹកភ្នែក ។
ម៉ែសែនត្រេកអរ ឃើញបុត្របវរ លក្ខណៈល្អឯក
លូកដៃស្ទាបកូន ទាំងខ្លួនស្លាំងស្លេក ព្រោះម៉ែអរពេក
ដោយឃើញកូនភ្ងា ។
ម៉ែចិញ្ចឹមកូន មិនខ្លាចខ្លួនសូន្យ ជីវិតការពារ
ទោះក្តៅត្រជាក់ ភ្លៀងធ្លាក់រងារ ម៉ែខំពះពារ
មិនឱ្យមានហ្មង ។
ពេលយំម្តេចក្តី ម៉ែស្លុះម៉ែភ័យ មកបីត្រកង
ច្រៀងបំពេកូន បំពៅដោះផង ម៉ែគ្មានមួរហ្មង
ធុញទ្រាន់ឡើយណា ។
ទោះយប់ថ្មើរណោ ម៉ែផ្ទៀងសោតា នេត្រាសែនវៃ
ក្រីក្រលំបាក តោកយ៉ាកម្តេចក្តី ការពារកូនថ្លៃ
មិនឱ្យព្រួយឡើយ ។

កូនយំម្តងៗ ស្ទុះមកត្រកង បំពេឱ្យស្ងៀម
ឱ្យកូនគេងលក់ ផុតទុក្ខល្ហែល្ហើយ ឱ អ្នកម្តាយអើយ
លំបាកយ៉ាងណា ។

ទឹកមាត់ទឹកមូត្រ ម៉ែគក់រហូត ញើសជោកភក្ត្រា
ព្រមលាមកផង ទាំងសងហត្ថា ម៉ែលាងពេលណា
ក៏មិនត្អូញត្អែរ ។

ដៃឆ្វេងពកូន មុខមិនស្រពោន ស្តាំបេះបន្លែ
យកមកដាំស្ល បបរបាយដែរ បញ្ចុកមាសមេ
ឱ្យកូនបានឆ្អែត ។

គ្រួក្រក្រៃពេក ម៉ែឥតបានដេក ភ្នែកបើកក្រឡេត
ម៉ែសែនព្រួយភ័យ ខ្លាចឈឺមិនឆ្អែត ម៉ែមិនបណ្តែត
ឱ្យកូនកំព្រា ។

ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**

អាសូរចិត្តម៉ែ

(បទពាក្យប្រាំពីរ)

-ម៉ែអើយម៉ែខ្ញុំលំបាកណាស់ ពីក្មេងទល់ចាស់សែនវេទនា
ប្រឹងចញ្ចឹមកូនឥតរួញរា ទោះក្តៅរងារក៏មិនស្តី ។
-ឥតបាយឥតទឹកឥតអាហារ ម៉ែគាស់ម៉ែឆ្ការដីឡូងព្រៃ
ជីកក្តួច ចៀស ក្តាម ឱ្យកូនធំ ដោយចិត្តមេត្រីឥតត្អូញត្អែរ ។
-ម៉ែទ្រាំលំបាកចិញ្ចឹមកូន ស្ទើរជីវិតសូន្យច្រើនឆ្នាំខែ
ថ្នាក់ថ្នមបីបមច្រៀងបំពេ ដោយហត្ថទាំងទ្វេឥតហ្មងសៅ ។
-ឥឡូវម៉ែចាស់ម៉ែជរា ចិញ្ចឹមបុត្រភ្នា រហូតចៅ
ម៉ែខ្ញុំហត់ណាស់មុខឡើងខ្មៅ ប្រឹងជួយពចៅខ្លាចកូនក្រ ។
-ម៉ែចាស់ម្លឹងហើយខំធ្វើការ ទាំងក្តីខ្លោចផ្សាប្រឹងត្រដរ
ខំប្រឹងជួយកូនដោយស្មោះស ដួងចិត្តបវររកប្រៀបគ្មាន ។
-ម៉ែអើយ អើយម៉ែ ម៉ែតែមួយ ហឫទ័យកូនព្រួយខ្លាចម៉ែឃ្លាន
ព្រោះកូននៅឆ្ងាយកាយអ្នកមាន គុណលើសប្រមាណសែនក្រៃពេក ។
-បើកូនឃ្លាតកាយឆ្ងាយពីម៉ែ ទុក្ខព្រួយឥតល្ហែម៉ែសង្វេគ
នឹកកូនរាល់ថ្ងៃទ្រូងស្ទើរបែក របេះរហែកបែកឱរ៉ា ។
-ទោះកូនខ្វាក់ថ្លង់ខ្វិនងងឹត ដួងចិត្តម៉ែពិតឥតមានថា

ស្រឡាញ់រូបកូនស្មើជីវ៉ា ប្រុសស្រីក្តីណាឥតមានល្មៀង ។

-ម្តាយមានគុណធ្ងន់លើសគិរី កូនសូមអញ្ជលីដោយចិត្តផ្ទៀង

ក្រាបថ្វាយបង្គំដោយប្រិតប្រៀង យប់ថ្ងៃរាល់រៀងដោយក្តីស្មោះ ។

-កូនសូមជូនពរដល់អ្នកម្តាយ សូមសុខសប្បាយគ្មានចន្លោះ

គ្រប់វិនាទីម៉ោងទាំងអស់ ឱ្យម៉ែស្រស់បស់អាយុយឺនយូរហោង!! ។

ដោយ ភិក្ខុកល្យាណេរតោ **ខាន់ សុិនសេម**

១៣-អាសូរចិត្តឪពុក

-ពាក្យពុកនេះណា ដក់ជាប់ចិន្តា ក្នុងឱរ៉ាកូន
នឹកគ្រប់នាទី មិនដែលភ្លេចសូន្យ ជាប់ចិន្តាស្ងួន
ពុំដែលភ្លេចឡើយ ។

-កូននៅទារក ពុកវិលវីវក់ ពុំដែលកន្តើយ
ពុសឧសរែកទឹក ថៃម៉ែឱ្យស្បើយ ឱស ឱពុកអើយ
លំបាកយ៉ាងណា ។

-ដាំបាយដងទឹក ពុកមមាញឹក រុកសព្វព្រឹក្សា
កាប់ឫសមើមឈើ ធ្វើថ្នាំរក្សា ថៃទាំមាតា
រក្សាដល់បុត្រ ។

-ពេលម៉ែពពោះ ធ្វើការជំនួស ម៉ែគ្មានតក់ស្លុត
ហាលថ្ងៃហាលភ្លៀង ដង្ហើមស្ទើរផុត ពុកមិនស្រយុត
ឃុំគ្រងរក្សា ។

-ជួនកាលពុកឈឺ ពុកថ្ងូរន្ទឺ ឈឺសព្វសាច់សារ
ក៏នៅត្រដរ តស៊ូធ្វើការ ចិញ្ចឹមបុត្រភ្ជា
ឱ្យមានជីវិត ។

-ពុកអើយពុកខ្ញុំ ពុកកើតទុក្ខធំ ព្រោះព្រាត់ម៉ែពិត

ព្រាត់កូនប្រុសស្រី ថ្លៃស្មើជីវិត នៅក្នុងដួងចិត្ត
ពុកសែនលំបាក ។

-ពុកឃ្លាតពីម៉ែ រាប់រយថ្ងៃខែ ខ្លាចកូនតោកយាក
ទៅបំរើជាតិ ការងារគ្មានស្រាក ពុកសែនលំបាក
នឹកកូននិងម៉ែ ។

-ពុកខំតស៊ូ ប្រយុទ្ធផ្ដាច់ប្ដូរ ការពារជាតិខ្មែរ
ការពារទឹកដី ពលរដ្ឋផងដែរ ពុកគ្មានទំនេរ
ព្រាត់ទាំងគ្រួសារ ។

-មួយថ្ងៃ១ ពុកជួបតែក្ដី ទុក្ខសោកមរណា
រស់ក្នុងសង្គ្រាម ឈាមដាបពុសធា ពុកឥតរួញរា
តេចការងារឡើយ ។

-ពុកខំខ្មីឃ្មាត ខំការពារជាតិ ឥតបីកន្ដើយ
ប្រយុទ្ធតស៊ូ ប្ដូរផ្ដាច់ឥតស្បើយ ពុកមិនខ្លាចឡើយ
ពីក្ដីមរណៈ ។

-ម្យ៉ាងពុកគិតជាតិ ម្យ៉ាងគិតដល់ញាតិ ពុំដែលមានអាក់
ខានម្ដងណោះសោះ ស្រណោះដល់ម៉ាក់ ព្រមទាំងកូនជាក់
ឥតមានរំលង ។

-លំបាកម្ការម្តេច ពុកចាំពុំភ្លេច កូនប្រុសស្រីផង
នឹកកូនប្រចាំ ឱវ៉ាមួរហ្មង នឹកពេកកន្លង
កូនប្រុសស្រីឱ ។

-ពុកនៅឆ្ងាយកូន ជីវ៉ាស្ទើរសូន្យ ចិត្តកួចនឹកទៅ
រកកូនប្រុសថ្លៃ ស្រមៃជាប់នៅ នឹកកូនស្រីពៅ
ពុំដឹងយ៉ាងណា ។

-យូរៗជួបម្តង ពុកស្ទះត្រកង កូនជាប់ហត្ថា
ពុកនឹកកូនពេក ស្ទើរបែកឱរ៉ា បានជួបបុត្រា
ឱរ៉ាធូរស្បើយ ។

-ជួបកូននិងម៉ែ ទ្រូងពុកបានល្ហែ ហាក់គ្មានខ្វល់ឡើយ
ញញឹមរីករាយ វាចាឆ្លងឆ្លើយ ជួបជុំគ្នាហើយ
សប្បាយពេកក្រៃ ។

-ពុកទូន្មានកូន ព្រមទាំងប្អូនៗ ឱ្យស្គាល់តម្លៃ
ជីវិតរស់នៅ រកស៊ីរាល់ថ្ងៃ ឱ្យល្អប្រពៃ
នៅក្នុងសង្គម ។

-ពុកប្រឹងប្រែងណាស់ ពីក្មេងដល់ចាស់ ព្រោះកូនតូចធំ
ប្រឹងប្រែងរកប្រាក់ ឧបសគ្គក៏ខំ ដើម្បីឧបត្ថម្ភ

ឱ្យកូនសិក្សា ។

-ទោះបីភ្លៀងផ្គរ ពុកមិនត្អូញថ្ងូរ ខំប្រាំងវស្សា
ពុកប្រឹងធ្វើស្រែ ពុកថែចំការ ប្រមូលផល្លា
ទុកចិញ្ចឹមកូន ។

-ពេលស្រុកសាន្តត្រាន្ត គ្រួសារយើងបាន មូលមិត្តបងប្អូន
បាត់តែរូបប៉ា ទៅណាស្ងាត់សូន្យ ម៉ាក់និងរូបកូន
រកសព្វកន្លែង ។

-ពេលបាត់ពុកភ្លាម ម៉ែមិនទៅស្ងៀម ដើររកខ្វាត់ខ្វែង
ឆ្លងខេត្តឆ្លងស្រុក តត្រុកតតក្រែង ម៉ែកូនចំបែង
ព្រោះបាត់រូបឪ ។

-ពុកបានផ្តាំថា ម៉ែកូននេះណា ប្រឹងរកស៊ីទៅ
ថែទាំចំការ ផល្លាមាននៅ ទុកកើ្តកូនទៅ
តាមកាលសម័យ ។

-ម៉ែសែនខ្លោចផ្សា ស្មើរប្រេះឱរ៉ា ចុកចាប់រាល់ថ្ងៃ
ព្រោះបាត់រូបប៉ា ជីវ៉ាស្មើរក្ស័យ ម៉ែស្ដមរ៉ុងរៃ
ស្បែកដណ្ដប់ឆ្អឹង ។

ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**

១៤_ទំនួញកូនកំព្រា

កម្មអកុសល តែងកើតមានដល់ មនុស្សសត្វគ្រប់គ្នា
មានជួបមានព្រាត់ សុខទុក្ខវេទនា ទៅតាមធម្មា
បច្ច័យតាក់តែង ។

មានខ្មៅមានស មានអាក្រក់មានល្អ ព្រះពុទ្ធសម្ដែង
មានជួបមានព្រាត់ មានក្សត់កំណ្ដែង រស់នៅម្នាក់ឯង
ព្រាត់ប្រាសឪម៉ែ ។

គ្មានបងគ្មានប្អូន ញាតិសាច់ជីដូន សោះសូន្យថ្ងៃខែ
រស់នៅម្នាក់ឯង ចំបែងម្លេះទេ រស់ជាមួយគេ
ទាំងក្ដីសោកា ។

ដាំបាយដងទឹក រាល់ថ្ងៃល្ងាចព្រឹក បោកគក់សព្វសារ
គ្មានពេលទំនេរ គេជេរស្ដីថា ឱស! ឱ! អនិច្ចា!
ហេតុខ្លួនកំព្រា ។

ឱកម្មអើយកម្ម តាមជាប់ប្រចាំ ឱ្យខ្ញុំព្រាត់គ្នា
ព្រាត់ពុកព្រាត់ម៉ែ បងប្អូនមីងមា ឱ្យខ្ញុំវេទនា
រស់ដូចជាស្លាប់ ។

រស់នៅសព្វថ្ងៃ មិនមានសិរី ឱរ៉ាចុកចាប់
កើតទុក្ខម្នាក់ឯង ចំរៀងស្មើរស្លាប់ ជីវិតអួរអព្ទ
លើភពផែនដី ។

ខំបំរើគេ ឥតពេលទំនេរ សិក្សាសូត្រអី
ខ្លួនចង់រៀនណាស់ ខ្លាចម្ចាស់គេស្តី គេតប់គេវាយ
ឱ្យខ្ញុំខ្លោចផ្សា ។

មួយថ្ងៃៗ រស់ដូចគ្មានន័យ នៅក្នុងលោកា
គេស្អប់គេខ្ពើម រអើមស្តីថា អាកូនឥតប៉ា
ឥតម៉ែ ឥតញាតិ ។

ពេលឮគេស្តី ក្នុងដួងហរទ័យ ចិត្តសែនចង្អៀត
ក្តុកក្តួលក្នុងចិត្ត អាណិតកាយទៀត មិនគួរបែកឃ្លាត
ម៉ែ ឪ បងប្អូន ។

ពេលញាំពេលគេង ទ្រូងសែនចំបែង ជីវិតស្មើរសូន្យ
គេងស្រក់ទឹកភ្នែក ព្រោះបែកជីដូន ញាតិមិត្តបងប្អូន
រស់នៅម្នាក់ឯង ។

ឱកាយអើយកាយ កើតគុណពុកម្តាយ បន្សល់តាក់តែង
ឱ្យកូនបានរស់ ដូចគេដូចឯង តែគ្រាន់ចំបែង

គ្មានញាតិសន្ដាន ។

រស់នៅនឹងគេ កើតទុក្ខសែនទ្វេ មិនដែលខកខាន
ធ្វើការរាល់ថ្ងៃ ឥតបីស្រាកស្រាន្ត ទោះយប់ស្មើម៉ាន
ដាស់ប្រើឥតក្រែង ។

ធ្វើខ្ញុំគេហើយ ឥតបីកន្ដើយ ត្រូវតែរអែង
មិនហ៊ានតបត ត្រដររចិត្តក្រែង សុខចិត្តចំបែង
ឱ្យតែខ្លួនរស់ ។

ធ្វើម្ដេចកម្មព្រេង ឱ្យខ្ញុំវង្វេង កំណើតឥតយស
ថោកទាបពេញទី វក់វីឥតយស ឱ្យរូបខ្ញុំរស់
ទាំងក្ដីសោកា ។

ពុកអើយម៉ែអើយ តើពេលនេះហើយ អ្នកនៅទីណា ?
កូនស្រែករកម៉ែ! ទាំងក្ដីខ្លោចផ្សា អ្នកនៅទីណា?
កូននឹកអ្នកណាស់ ។

ឱ !ទេវតាអើយ ចះហេតុម្ដេចឡើយ ឱ្យខ្ញុំកម្មក្រាស់
តើខ្ញុំសាងអ្វី ពីជាតិមុនខ្លះ បានជាកម្មក្រាស់
ឱ្យព្រាត់ពុកម៉ែ ។

កូនសែននឹកពុក ទ្រូងសែនកើតទុក្ខ ពុំដែលមានល្ហែ

ចិត្តសែនខ្វាយខ្វល់ រៀងរាល់ថ្ងៃខែ ឱស!ឱ!ពុកម៉ែ
អ្នកនៅទីណា ? ។
រៀងរាល់យប់យន់ កូនតេងបន់ស្រន់ សំពះទេព្តា
និងព្រះរតនត្រៃ មានជ័យខ្លាំងក្លា ផ្សងជួបភក្រ្តា
នឹងអ្នកមានគុណ ។
កូនខំតាំងចិត្ត សាងកម្មសុចរិត ឥតមានទំរន់
ក្រែងបានជួបភក្រ្ត លោកអ្នកមានគុណ ទោះបីឈឺគ្រុន
ក៏មិនត្អូញត្អែរ ។

ដោយ ភិក្ខុកល្យាណេរតោ **ខាន់ ស៊ិនសេម**

ឧឧឧឧឧឧឧឧ ឧឧឧឧឧឧឧឧ

១៥_កូលាបបាក់ទង

(បទពាក្យ ៧)

កូលាបគឺផ្កាល្អសែនស្រស់ ឆើតឆាយអស់ទាស់គួរគយគន់
រីកត្រប់រដូវយ៉ាងល្វិតល្វន់ សម្រស់ស្រទន់ល្អគ្មានប្រៀប ។
ពេលកូលាបរីកស្រស់ម្តង១ ញាតិមិត្តអ្នកផងតែងកាច់រៀប
យកទៅថ្វាយព្រះឬតម្រៀប ចាក់ក្រងរបៀបធ្វើមង្គល ។
គេស្រឡាញ់ណាស់ពេលរីកស្រស់ ដល់ពេលផ្កាអស់ពពើមិនយល់
គេបោះបង់ចោលឥតខ្វាយខ្វល់ នោះកម្មមកដល់នៃកូលាប ។
នោះប្រៀបដូចមនុស្សធ្លាប់មានយស ឋានៈខ្ពង់ខ្ពស់ភ្លេចគិតបាប
ឈ្លក់នឹងតណ្ហាស្រានិងលាភ ជាន់អ្នកតូចទាបអាងអំណាច ។
គំរាមកំហែងអ្នកក្រីក្រ ពួកជនស្មោះសឱ្យខ្លបខ្លាច
រឹបអូសសម្បត្តិទាំងកោងកាច ធ្វើចិត្តអង់អាចថាខ្លួនល្អ ។
ញើសឈាមគេសោះថាផន់ឯង ខំស្រែកក្តែង១ទាំងត្រដរ
លាពាក់ស្បែកខ្លាសង្ហារដល់ក ភ្លើតភ្លើនភ្លេចល្អភ្លេចជាតិខ្លួន ។
ពេលខ្លួនអស់សិទ្ធិអស់អំណាច អស់ភាពអង់អាចភ័យផ្ទួន១
គេសើរើរកកម្មដែលខ្លួន កន្លងមកផ្ទួន១សែនរលួយ ។

គេវាយគេចាប់ដាក់ខ្នោះឃ្នាង ភ្នែកនៅចាំហៀងសែនទុក្ខព្រួយ
ស្រែកទ្រហោយំឱ្យគេជួយ គ្មានអ្នកណាព្រួយអើពើសោះ ។
នេះហើយគឺកម្មអកុសល នឹងធ្លាក់មកដល់ឥតមានផ្លោះ
ធ្វើបាបប៉ុន្មានបានទាំងអស់ អ្នកទទួលចោះកុំត្អូញអី ។
កាលដែលមានយសភ្លេចធ្វើល្អ គ្មានចិត្តមនុស្សធម៌គិតអប្រិយ៍
មិនជួយឧបត្ថម្ភអ្នកក្រក្រី ពេលខ្លួនជួបភ័យទើបស្ដាយក្រោយ ។

ដោយ **ភិក្ខុកល្យាណរតោ ខាន់ សុិនសេម**

១៦_ទំនួញចាបមាសក្រមុំ

(បទពាក្យប្រាំពីរ)

កើតមកជាចាបមាសដ៏ល្អ　　　　រូបស្រស់បវរគ្មានគូរផ្ទឹម
ស្បែករោមចំពុះស្រស់ប៉ប្រិម　　　　ល្អគ្មានគូរផ្ទឹមប្រដូចបាន ។
កាលខ្លួននៅតូចក្នុងសំបុក　　　　មេបាបញ្ចុកពុំដែលខាន
ចំណីឆ្ងាញ់ៗឱ្យកូនបាន　　　　លូតលាស់ខ្លួនប្រាណបានដូចគេ ។
ពេលខ្លួនបានស្រស់ដុះរោមពេញ　　　　ចិត្តធំហើរចេញឥតទំនេរ
ចាកចោលសំបុកមិនស្តាប់មេ　　　　ថែមទាំងដៀលជេរដល់ត្រកូល ។
ហិចហើរចុះឡើងឥតបានគិត　　　　ចៃដន្យជួបមិត្តនាំឱ្យចូល
រកស៊ីចំណើទំដិបូល　　　　ផ្ទះដែលមានឈ្មោលថៃរក្សា ។
ទំចុះទំឡើងមិនបានមើល　　　　អាឈ្មោលវាព្រើលទាក់ស្រវារ
ឆក់យកចាបមាសដោយរើរហា　　　　ចាបទន់ចិន្តាលង់សំដី ។
ដំបូងអាឈ្មោលស្រឡាញ់ណាស់　　　　ខំប្រឹងរូតរះថ្នមចាបស្រី
ដល់វារស៊ីឆ្អែតកើតអប្រិយ៍　　　　នាំយកចាបស្រីប្តូរយកប្រាក់ ។
ចាបស្រីជាប់ទ្រុងលង់លដុល្ហារ　　　　ចាញ់ប្រាជ្ញអាបាចិត្តអប្បលក្ខណ៍
លង់កាយលង់ចិត្តជាប់អន្ទាក់　　　　ទើបនឹកដល់អ្នកឱ្យចំណើ ។

រស់ក្នុងទ្រុងកម្មចាំបំរើ ភេទតាមដំណើរទាំងយប់ថ្ងៃ
ភ្ញៀវក្មេងភ្ញៀវចាស់ឥតរើសអី ពុំហ៊ានហារស្តីតបតគេ ។
មិនយូរប៉ុន្មានកើតជំងឺ ចាបធ្លាក់ខ្លួនឈឺទុក្ខឥតទ្វេ
បម្រើភ្ញៀវមិនកើតម្ចាស់ស្តីជេរ ទឹកភ្នែកឥតល្ហែនឹកពុកម្តាយ ។
ឈឺមើលមិនជានឹកភ័យភ្លែត មិនដឹងកើតអេដស៍ឬកើតស្វាយ
កើតទុក្ខទោម្នេញឥតរសាយ សម្រស់ឆោមឆាយក៏ស្រអាប់ ។
ឈឺព្រឹកឈឺល្ងាចឈឺរាល់ថ្ងៃ កើតរោគរុំារៃស្ទើរតែស្លាប់
ភ័យរត់រកពេទ្យយ៉ាងប្រញាប់ ស្រាប់តែពេទ្យប្រាប់ថាកើតអេដស៍ ។
ពេលដឹងថាខ្លួនកើតអេដស៍ហើយ កើតទុក្ខឥតស្បើយធ្វើតេត១
ខំសួរបញ្ជាក់ដល់បងពេទ្យ ថាខ្ញុំកើតអេដស៍ពិតមែនឬ ? ។
ពេទ្យប្រាប់ម្តងទៀតថាកើតមែន ក្នុងចិត្តនាងសែនព្រួយសែនព្រឺ
ងងឹតមុខដួលទាំងខ្លួនឈឺ ព្រោះកើតជម្ងឺមើលមិនជា ។
ដេកយំបោកខ្លួនសែននឹកស្តាយ ពាក្យពេចន៍ពុកម្តាយប្រាប់គ្រប់គ្រា
ប្រដៅទូន្មានកូនស្រីភ្ញា ឱ្យល្អសោភាបែរមិនស្តាប់ ។
ឥឡូវកូនខុសហើយពុកម៉ែ នេះក៏ព្រោះតែកូនមិនស្តាប់
តាមពាក្យទូន្មានដែលលោកប្រាប់ ពេលនេះជិតស្លាប់ទើបកូនដឹង ។
ខ្ញុំសូមផ្តែផ្តាំអស់ស្ត្រី នៅលើលោកីយ៍ជាដំណឹង

កុំត្រាប់តាមខ្ញុំធ្វើបែបហ្នឹង ចូរអ្នកខំប្រឹងស្តាប់ពុកម្តាយ ។
ពាក្យម៉ែល្អណាស់ទូន្មានកូន សូមអស់បងប្អូនកុំឃ្លាតឆ្ងាយ
ប្រឹងប្រែងត្រង់ត្រាប់ស្តាប់ពាក្យម្តាយ ប្រយ័ត្នអន្តរាយខ្លួនដូចខ្ញុំ ។
កុំល្ងង់ល្ងើចងនឹងសម្រស់ បងប្អូនស្រីប្រុសត្រូវរមទម
ខ្លួនស្រីកុំដើរឆ្ងាយទ្រនំ ប្រយ័ត្នជាប់ឃុំអន្ទាក់កាម ។
ពេលនេះខ្ញុំតឹងទ្រូងខ្លាំងណាស់ មើលអ្វីមិនច្បាស់ជលនេត្ររហាម
ខ្លាចហើយរាងហើយចិត្តជាប់កាម សូមកុំដើរតាមគន្លងខ្ញុំ ។
កូនសូមលាហើយពុកម្តាយថ្លៃ បងប្អូនប្រុសស្រីចូរសុខុម
នៅឱ្យសុខចះកុំបារម្ភ ពេលនេះរូបខ្ញុំសូមលាហើយ ។

-កូនប្រុសស្រីណាដែលមិនស្តាប់ដំបូន្មានឪពុកម្តាយ រមែងអន្តរាយខ្លួនដូចជា នាងចាបមាសក្រមុំនេះពុំខានឡើយ

-សូមជនានុជន ជនរួមជាតិ រួមសាសនា ស្រីប្រុសទាំងអស់ មេត្តាខំប្រឹងប្រែងប្រតិបត្តិ ឱ្យបានល្អប្រសើរ ទើបបានក្លាយខ្លួនទៅជាកូនល្អ ពលរដ្ឋល្អ ពុទ្ធបរិស័ទល្អ និងជាទំពាំងស្នងឫស្សី របស់ប្រទេសជាតិយើង !!!!!!!

ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**

ꕥꕥꕥꕥꕥꕥꕥꕥꕥꕥ

១៧_អណ្ដាត (បទព្រហ្មគតិ)

អណ្ដាតជាសិរី **រះប្រពៃក្នុងអង្គប្រាណ**
មានមុខងារចំពោះ និយាយបានសព្វអន្លើ ។
ទោះច្រៀងឬស្រែកហៅ ជួយបន្ទរសព្វសារពើ
អណ្ដាតខំប្រឹងធ្វើ ឥតស្ទាក់ស្ទើរគ្រប់នាទី ។
អណ្ដាតខ្ចីក្រញ៉ឹង ឥតមានឆ្អឹងទន់សោភី
ធ្វើការបានពេញទី ញាតិមូលមីរមកជួបជុំ ។
បើអ្នកចង់ហារស្ដី ហូបចំណីឬប្រឹងផ្លុំ
ត្រូវពឹងអណ្ដាតខ្ញុំ នោះទើបផ្ដុំឮសម្លេង ។
និយាយកិច្ចកុសល ត្រូវពឹងដល់អណ្ដាតឈ្វេង
យល់បញ្ចេញសម្លេង ទើបថ្លាថ្លែងដឹងហេតុការណ៍ ។
ទោះ ស្ដី ឬក៏ស្មូត ការច្រៀង សូត្រ ឬទេសនា
ពឹងអណ្ដាតហើយណា ធ្វើកើតការកិច្ចកុសល ។
អណ្ដាតសំខាន់ណាស់ ទោះក្មេងចាស់ត្រូវឱ្យយល់
ចូរកុំមើលងាយដល់ ត្រូវខ្វាយខ្វល់ថែរក្សា ។

អញ្ញោតជាប្រមុខ នាំក្ដីសុខឬទុក្ខា
បើពោលកុសលា នាំសត្វាឱ្យបានសុខ ។
បើពោលពាក្យខុសវិញ នាំទោសម្នេញពេញតែស្រុក
កើតរឿងរ៉ាវមិនសុខ មានក្ដីទុក្ខព្រោះអញ្ញោត ។
ពាក្យស្ដីពិតមិនពិត ពាក្យប្រឌិតចំអៀញខាត
សុទ្ធចេញពីអញ្ញោត ចូរសង្វាតគិតមុនហារ ។
ទោះបីចាស់ឬក្មេង ពោលពាក្យលេងថ្លែងវាចា
កុំពោលឥតបានការ ក្រែងមរណាស្លាប់ជីវិត ។
អញ្ញោតឥតដឹងអី ទាំងប្រុសស្រីត្រូវចេះគិត
កុំពោលពាក្យមិនពិត ឬទុច្ចរិតប្រាសចាកធម៌ ។
ព្រោះវានាំឱ្យគ្រោះ កើតរឿងឈ្លោះឈ្មោះមិនល្អ
ខូចពូជវង្សបន្ត ព្រោះត្រដរពោលមិនត្រូវ ។
ជួនធ្វើឱ្យខូចឈ្មោះ បាត់កិត្តិយសឈ្មោះអាស្រូវ
ឱ្យអ្នកធ្លាក់រណ្ដៅ ឈានជើងទៅក្នុងអបាយ ។
សូមផ្ដាំជនប្រុសស្រី លើលោកីយ៍ជៀសឱ្យឆ្ងាយ
ប្រយ័ត្នធ្លាក់អបាយ នាំអន្តរាយព្រោះអញ្ញោត ។

ចូរអ្នកខំប្រព្រឹត្ត ពោលសុចរិតពាក្យល្អស្អាត
នោះហៅពោលមានខ្នាត ទើបអណ្តាតឱ្យអ្នកសុខ ។

ដោយ ភិក្ខុកល្យាណរតោ **ខាន់ សុិនសេម**

១៨-អកតញ្ញូ

-អកតញ្ញូ ពុំដឹងគុណគ្រូ មាតាបិតា
និងអ្នកមានគុណ ឯទៀតណា។ ចិត្តវាហានក្លា
រករឿងចាប់ទោស ។
-ទោះអ្នកមានគុណ មានចិត្តជាបុណ្យ អត់ឱនសន្តោស
សង្គ្រោះឱ្យវា រួចចាកទុក្ខទោស វានៅតែកោស
សួររករឿងទៀត ។
-ទោះលើកផែនដី ទាំងមូលឱ្យក្តី វានៅតែឆ្លៀត
រករឿងរ៉ាវិញ ដោយការជ្រែកជ្រៀត នាំជនឯទៀត
ឱ្យចូលដៃផង ។
នោះគឺជនពាល គំនិតរោលរាល អាក្រក់កន្លង

ទោះព្រះសមុទ្ទ វិសុទ្ធឥតម៉ង ក៏អាចចម្លង

វាពុំបានឡើយ ។

(កំណាព្យនេះគឺជាស្នាព្រះហស្ថចុងក្រោយបង្អស់របស់ សម្តេចព្រះសង្ឃរាជ

ជ.ណ. ជួន ណាត)

ಋಋಋಋಋಋಋಋಋಋಋ

១៩. សីល៥

-ចំពោះសីល៥ ព្រះពុទ្ធទ្រង់ផ្តាំ ផ្សាំចិត្តឱ្យស្អាត

ទី១ហៅថា បាណាតិបាត ហាមឃាត់ដាច់ខាត

កុំសម្លាប់សត្វ ។

-ទី២អទិន្នា ប្រុសស្រីគ្រប់គ្នា ត្រូវកាន់ចិត្តកាត់

កុំលួចទ្រព្យគេ ឱ្យចេះប្រយ័ត្ន ក្រែងកើតវិបត្តិ

ធ្លាក់លើអាត្មា ។

-ទី៣កាមេ សូមកុំរិះរេ ឈ្លក់នឹងតណ្ហា

សេពមេថុនធម្ម ខុសក្រុមគ្រួសារ ដែលពុំមែនជា

របស់ខ្លួនឯង ។

-ទី៤មុសា កុំកុហក់គេណា ប្រយ័ត្នចំបែង

មុនពោលមុនស្តី ត្រូវចេះគិតក្រែង បើឆ្លោយនឹងតែង

កើតទោសដល់ខ្លួន ។

-ទី៥សុរា កុំប្រព្រឹត្តណា នាំទុក្ខផ្ទួនៗ

អស់ទ្រព្យសម្បត្តិ កើតរោគក្នុងខ្លួន ធ្វេសប្រហែសជួន

នាំស្លាប់ទាំងរស់ ។

-ទាំងប្រាំនេះណា ចូរអ្នករាល់គ្នា កុំ ល ជ្រលោះ

ត្រូវជៀសឱ្យផុត ទើបខ្លួនយើងរស់ ហើយមានកេរ្តិ៍ឈ្មោះ
ល្បីសាយរន្ទឺ ។

ដោយភិក្ខុកល្យាណោរតោ **ខាន់ ស៊ិនសេម**

២០.អានិសង្សរបស់បុណ្យ ៥យ៉ាង

(បទពាក្យ ៨)

-ព្រះពុទ្ធសម្តែងថ្លែងប្រោសទេសនា ថាបុណ្យនេះណាមានអានិសង្សប្រាំ
ចូរអ្នកទន្ទេញសូត្រឱ្យបានចាំ ក្នុងចិត្តចំណាំចាំជាតម្រា ។
-ទី១ ភិក្ខុបញ្ញា វិសារទោ ស្មារតីហៅហូរសំបូរបញ្ញា
អង់អាចក្លាហានដួងចិត្តក្លៀវក្លា សែនស្រស់សង្ហាររុងរឿងបវរ ។
-ទី២ នោះគឺសុរូបតា មានរូបអស្ចារ្យល្អអើយសែនល្អ
កើតដល់អ្នកធ្វើដែលចិត្តស្មោះស ដោយកុសលធម៌នៃផលសុចរិត ។
-ទី៣ នោះគឺសុវណ្ណតា មានពណ៌ថ្លៃថ្លាយ៉ាងល្អប្រណីត
មនុស្សផងគយគន់មិនឆ្អែតក្នុងចិត្ត ពណ៌ល្អស្រស់ពិតចិត្តគន់មិនណាយ ។

-រឿងទី៤ សុសណ្ឋានា មានទ្រង់ទ្រាយអស្ចារ្យល្អឆើតឆាយ
មិនខ្ពស់មិនទាបមិនរៀចវេរកាយ សមនឹងទ្រង់ទ្រាយសមមុខសមមាត់ ។

-ទី៥ ចក្កវត្តិរាជាហោតិ ជាតិមុខអតិក្លាយជាស្តេចចក្រពត្តិ
គ្រប់គ្រងសកលទ្វីបសែនចេះស្ទាត់ រុងរឿងប្រាកដលើភពផែនដី ។

-នេះគឺអានិសង្សដែលអ្នកធ្វើ ព្រោះជាអំពើយ៉ាងល្អប្រពៃ
សូមខំប្រព្រឹត្តទាំងប្រុសទាំងស្រី ព្រោះជាតម្លៃនៃកុសលធម៌ ។

-អ្នកប្រាជ្ញបណ្ឌិតពិតជ្រះជ្រែងពេរាស់ ឱ្យមនុស្សគ្រប់សាសន៍ចេះធ្វើតែល្អ
ព្រោះខ្លាចជ្រុលខ្លួនធ្លាក់អកុសលធម៌ នាំរឿងរីកវរកើតជាជម្លោះ ។

ដោយ ភិក្ខុកល្យាណោរតោ **ខាន់ សុិនសេម**

២១-អានិសង្សកតញ្ញូ ៤យ៉ាង

-ម្នាលលោកស្រីប្រុស **ចូរលោកចាំចុះ** **អានិសង្សកតញ្ញូ**
ចារទុកក្នុងក្បួន សុត្តន្តបិដកគ្រូ ចូរអ្នកគន់គូរ
ចងចាំជាដួង ។

-១កុសលមូលតា ប្រែយ៉ាងច្បាស់ថា ឫសកុសលទាំងពួង
ព្រោះជាកំណើត ឱ្យកើតទម្រង់ បុណ្យយ៉ាងថ្លាយង់
ដល់ជនប្រុសស្រី ។

-២បធានតា ជាដួងកុសលា ឱ្យកើតបារមី
ពីបារមីមួយ ដល់សាមសិបនៃ ដែលពោធិសត្វថ្វៃ
បដិបត្តិជាផល ។

-៣ បុញ្ញាភិវឌ្ឍនោ កើតបុណ្យហែហូរ ចម្រើនមង្គល
កើតគ្រប់វេលា ជាស្ពានទាំដល់ ព្រះនិព្វានផល
បរលោកយ៉ាងច្បាស់ ។

-៤សម្បត្តិសមច្ឆន្ទា ភោគផលនានា មានកើតមិនខ្វះ
សម្បត្តិគ្រប់ធុន ជោរជន់ដេរដាស់ សំបូរក្រៃក្រាស់
ឥតមានអ្នកផ្លូ ។

-នោះគឺជាផល ដែលកើតមានដល់ បុគ្គលកតញ្ញូ

ស្គាល់គុណមាតា បិតានិងគ្រូ នាំអ្នកឱ្យធូរ
ឆ្លងផុតអបាយ ។

ដោយ **ភិក្ខុកល្យាណរតោ ខាន់ ស៊ិនសេម**

២២-នាមរបស់មាតា បិតា ៤យ៉ាង

-ព្រះសព្វញ្ញុពុទ្ធទ្រង់សំដែង តាក់តែងនាមមាតាបិតា
ប្រោសដល់សព្វសត្វយ៉ាងច្បាស់ថា មានបួនប្រការក្នុងគម្ពីរ ។

-ព្រោះអីមាតាបិតាយើង ស័ក្តិសមថ្កុំថ្កើងនឹងនាទី
ព្រោះគុណធម៌លោកល្អសោភី តែមួយគ្មានពីរក្នុងលោកា ។

-ទី១ឱ្យឈ្មោះថាជាព្រហ្ម ចិត្តល្អរមទមនៃធីតា
ជាអ្នកអប់រំសព្វសត្វា ឱ្យល្អថ្លៃថ្លាពេកកន្លង ។

-ទី២ឱ្យឈ្មោះបុព្វាចារ្យ ប្ញក្សពារចរិយាល្អឥតហ្មង
ទូន្មានកូនស្រីកូនប្រុសផង មិនឱ្យមានឆ្គងសព្វសម្តី ។

-ទី៣ឱ្យឈ្មោះបុព្វទេវា ដាក់ក្នុងទ័យាកូនប្រុសស្រី
គោរពប្រតិបត្តិប្រចាំថ្ងៃ កើតសុខសិរីគ្រប់ប្រការ ។

-ទី៤ អាហុនេយ្យបុគ្គល ជាស្រែកុសលនៃធីតា
បូជារាល់ថ្ងៃកើនបុញ្ញា ដល់កូនគ្រប់គ្នាដែលប្រតិបត្តិ ។
-ចូរកូនប្រុសស្រីខំគោរព ញ៉ាំងចិត្តឱ្យស៊ប់ហើយប្រយ័ត្ន
បើធ្វើឱ្យភ្លាត់កើតវិបត្តិ ត្រូវលះចិត្តកាត់ប្រឹងរក្សា ។
-ឈ្មោះទាំងបួននេះគឺជាព្រះ គង់នៅក្នុងផ្ទះគ្រប់វេលា
យើងជាកូនចៅខំបូជា គ្រប់ទិនទិវាកុំបីខាន ។

ដោយ **ភិក្ខុកល្យាណរតោ ខាន់ សុិនសេម**

២៣-ព្រហ្មវិហារធម៌ ៤យ៉ាង·

-១មេត្តាចិត្ត ស្រឡាញ់ស្មាលស្និទ្ធ "មានសត្វជាអារម្មណ៍"
កាលលោកទាំងពីរ នាក់បានផ្សំផ្គុំ ប្រាថ្នាសុខុម
តពូជពង្សផៅ ។
-២គឺករុណា អាសូរបុត្រភ្ញា ដក់ជាប់ក្រឹឌី
"សម្លេងជាអារម្មណ៍" លោកខំបំពៅ ឱ្យបាត់សោកសៅ
ដល់កូនប្រុសស្រី ។
-៣មុទិតា លោកមានចិន្តា ទោរទន់ទៅស្មោះ
"មានចិត្តជាអរម្មណ៍" លោកខំសន្ដោស ដល់កូនស្រីប្រុស
ទាំងក្ដីឈើផ្អាល ។
-៤ឧបេក្ខា មាតាបិតា តាំងចិត្តកណ្ដាល
"មានកម្មជាអារម្មណ៍" ចិត្តផ្សំត្រកាល ឱ្យកូនអំបាល
មានគូស្រករ ។
-ចែកទ្រព្យសម្បត្តិ លោកមានចិត្តកាត់ មិនថាមានក្រ
ចែកតាមសមត្ថភាព ឥតអគតិធម៌ ដល់កូនបវរ
គ្មានស្ដាយស្រណោះ ។

ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**

២៤. ព្រះគុណម៉ែ

-គុណម៉ែតាំងតែគភ៌ចាប់ផ្ដើម ទ្រាំពពោះផើមទ្រាំលំបាក
ដើរដេកដូចរោគតាមឥតស្រាក ទម្រាំកូនចាកចេញពីផ្ទៃ ។

-ពេលឆ្លងទន្លេម៉ែឈឺខ្លាំង ចិត្តតាំងកាយប្រឹងព្រមដោយភ័យ
មិនដឹងយ៉ាងណាចិត្តម្ដាយ នឹកភ័យក្រែងកូនសូន្យសង្ខារ ។

-លុះកូនបានកើតជាទារក ម៉ែថើបជញ្ជក់សព្វកាយា
បីបមថ្នមថ្នាក់ពេញហត្ថា មេត្តាប្រែឈាមជាទឹកដោះ ។

-នៅពេលកូនឈឺម៉ែរក្សា បីផ្ទប់ឱរាដោយចិត្តស្មោះ
កូនឈឺម៉ែភ័យមុខស្លាំងអស់ មិនសម្រាន្តសោះរាល់ៗព្រឹក ។

-នៅពេលកូនជាម៉ែសប្បាយ ចិត្តម៉ែមិនណាយមានតែនឹក
ឃ្លាតឆ្ងាយបន្ដិចចិត្តវរវឹក រលឹករកកូនវិលវិញភ្លាម ។

-អង្គុយកកិលក្រោកឈរដើរ ទៅតាមដំណើរម៉ែព្យាយាម
ខំបង្ហាត់កូនដោយមិនទាម ក្នុងនាមជាគ្រូឧត្ដមក្រៃ ។

-ជុះនោមហូបចុកស្លៀកដណ្ដប់ ចំណេះចេះសព្វប្រចាំថ្ងៃ
សម្ដីភាសាមាយាទថ្លៃ កូនកុំសង្ស័យក្រែងឥតគ្រូ ។

-កូនចេះមួយមុខម៉ែអរម្ដង អួតប្រាប់អ្នកផងមិនចាំយូរ
ម៉ែនឿយយ៉ាងណាមិនគិតគូរ បន្ទូរកង្វល់ដោយថ្កាល់កូន ។

-កូនធំបន្តិចបែបរាងរឹង　　កូនខ្លះទទឹងអាងជីដូន
ម៉ែខឹងអន់ចិត្តមុខស្រពោន　　វាយកូនរួចគិតអាណិតក្រោយ ។

-កូនល្អម៉ែខុសក្រៃកន្លង　　បានដូចម៉ែផ្សងសូមអំណោយ
ដូចបានកែវទិព្វទេវតាឱ្យ　　ឬដូចបានសោយសុខសួគ៌ា ។

-ពេលកូនបានសុខម៉ែសុខផង　　ពេលកូនមានហ្មងម៉ែពុំជា
កូនក្រលំបាកម៉ែរងារ　　គ្រប់គ្រាម៉ែគិតកូនប្រុសស្រី ។

-កូនខូចអាក្រក់ក្នុងភូមិឃុំ　　គេគុំគេស្អប់សព្វសាយនៃ
ម៉ែដឹងប្រាកដថាខុស ក្តី　　តែម៉ែមិនភ័យប្រោសប្រណី ។

-ពេលមានរឿងហេតុកើតដល់កូន　　ម៉ែព្រួយស្ទើរសូន្យទ្រូងសែនភ័យ
ស្ទុះមកឈរបាំងពាំងកូនថ្លៃ　　ខ្លាចគេតប់វាយដល់កូនខ្លួន ។

-ម៉ែខំដោះស្រាយក្រែងបានស្រាក　　រឿងដែលពិបាកកើតផ្ទួនៗ
កំហុសប៉ុន្មានធ្លាក់លើខ្លួន　　ម៉ែស៊ូរែកពុនជំនួសកូន ។

-ទោះទោសស្រាលធ្ងន់ម៉ែមិនខ្លាច　　ចិត្តម៉ែអង់អាចស៊ូលះសូន្យ
ដោះស្រាយបញ្ហាដល់កូនៗ　　មិនខ្លាចខ្លួនសូន្យសោះឡើយនៃ ។

-ម៉ែគឺជាព្រះរបស់កូន　　ពិតគឺជាក្បួនកូនប្រុសស្រី
ម៉ែមានគុណធ្ងន់លើសផែនដី　　គ្មានអ្វីមកប្រៀបគុណម៉ែឪ ។

-ទោះទឹកសមុទ្រទាំងបួនធំ (១) យកមកលាយផ្សំធ្វើទឹកខ្មៅ
លើកភ្នំព្រះសុមេរុទាំងមូលទៅ ធ្វើបាកាខ្មៅសរសេរក្តី ។
-សរសេរឱ្យរីលទាំងតួភ្នំ រីងទឹកសមុទ្រធំអស់ទាំងផែនដី
នៅរាប់មិនអស់គុណពុកម្តាយថ្លៃ ចូរកូនប្រុសស្រីកុំប្រមាថ ។
-សូមកូនរាល់គ្នាខំគោរព ប្រតិបត្តិថ្ងៃយប់ឱ្យល្អស្អាត
ពាក្យលោកទូន្មានខំសង្វាត ត្រង់ត្រាប់តាមបាទអ្នកមានគុណ ។

(១) សមុទ្រទាំង៤ធំ =(គឺទឹកនៃមហាសមុទ្រធំទាំង៤ដែលទ្រទ្រង់ចក្កវាឡទាំងមូលនៃផែនជម្ពូទ្វីប

-លោកឪពុកអ្នកម្តាយពិតជាមានគុណច្រើនលើសលប់ពេក ក្រៃ គ្មានអ្នកណាម្នាក់ដែលមានគុណស្មើនឹងលោកបានឡើយ
-លោកឪពុកអ្នកម្តាយ មានគុណមកលើកូនប្រុសកូនស្រី ជាអនន្តគុណ ជាអនេកប្បគុណ ជាវិសុទ្ធិគុណ គឺមានគុណធ្ងន់ជាង អ្វីៗទាំងអស់នៅលើលោក ។ ទោះបីលើកផែនដីទាំងមូលរួមទាំងទឹកមហាសមុទ្រធំទាំងបួនមកប្រៀបធៀបជាមួយទម្ងន់នឹងគុណលោកឪពុកអ្នកម្តាយ ក៏ពុំស្មើឡើយ ។

ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**

២៥_ការបែងចែកទ្រព្យ ៤យ៉ាង

-ការបែងចែកទ្រព្យ អ្នកប្រាជ្ញបង្គាប់ ថាមានបួនយ៉ាង
ឱ្យមនុស្សគ្រប់រូប ចេះកិច្ចកសាង រៀបឱ្យស្ថិតស្ថាង
ឱ្យល្អត្រឹមត្រូវ ។

-១ ដោះបំណុលចាស់ ជំពាក់ច្រើនហោស់ សងគុណម៉ែឪ
ចិញ្ចឹមយើងពីតូច មកទល់ឥឡូវ ម្លោះហើយកូនត្រូវ
តបស្នងគាត់វិញ ។

-២ បុលបំណុលថ្មី ចិញ្ចឹមកូនប្រុសស្រី ទាំងទុកទោម្ទេញ
កូនតិចកូនច្រើន កើតកើនហិរញ្ញ ឥតមានចំណេញ
ហូរប្រាក់ចូលផ្ទះ ។

-៣បោះក្នុងជ្រោះ ជ្រៅទ៌ះជ្រៅហួស ឈ្មោះជ្រោះក្រពះ
ចិញ្ចឹមខ្លួនឯង ខ្ទះខ្មែងរួតរះ ដើម្បីក្រពះ
ទើបមានជីវ៉ា ។

-៤ កំណប់ព្រេង កប់ទុកខ្លួនឯង ក្នុងព្រះពុទ្ធសាសនា
ធ្វើបុណ្យដាក់បាត្រ សន្សំសីលា សម្រាប់ប្រើការ
ទៅបរលោក ។

-ចូរអ្នកធ្វើចុះ ពិតជាមិនខុស ការបែងទ្រព្យភោគ
ឱ្យត្រូវតាមក្បួន ទាំងបួនពិតជោគ សូមអ្នកលៃលក
ឱ្យល្អទើបគួរ ។

ដោយ **ភិក្ខុកល្យាណរតោ ខាន់ ស៊ិនសេម**

២៦- ទ្រព្យមានឈ្មោះ ៤យ៉ាង

-ទ្រព្យនៅក្នុងលោកមានច្រើនណាស់ សព្វគ្រប់មិនខ្វះសព្វសារធាតុ
លើដីក្រោមដីច្រើនព្រោងព្រាត ទាំងក្នុងទឹកទៀតច្រើនអន្លើ ។

-ទ្រព្យមានប្រភេទតាមការកើត អាក្រក់ខ្លះល្អឆើតតាមអំពើ
ឬតាមជំនាងជាងអ្នកធ្វើ កែឆ្នៃសារពើកើតជាទ្រព្យ ។

-ទោះទ្រព្យមានច្រើនយ៉ាងណាក្តី ព្រះពុទ្ធជិនស្រីទ្រង់រៀបរាប់
ថាមានបួនយ៉ាងតាមការគាប់ ដូចបានរៀបរាប់ខាងក្រោមនេះ ។

-ទី១ ឈ្មោះថា ថាវរៈនិធិ ជាទ្រព្យឥតវិ ញ្ញាណចូររិះ
គិតពិចារណាជាតម្រិះ ឱ្យបានចាំចេះកើតបញ្ញា ។

-ទី២ ជង្គមនិធិ ជាយានជំនិះគឺសត្វដើរបាន
នាមគោក្របីនឹងសត្វតិរច្ឆាន អាចប្រើប្រាស់បានជំនួសកម្លាំង ។

-ទី៣ គឺអង្គនិធិ នោះគឺទ្រព្យវិ ជ្ជាកម្លាំង
សិក្សារៀនសូត្រទុកក្នុងឃ្លាំង គ្មានចោរណាឃ្លាំងដណ្តើមបាន ។

-ជាទ្រព្យវិជ្ជានៅក្នុងខ្លួន រៀនចាំជាក្បួនទុកក្នុងប្រាណ
ឥតមានអ្នកណាឆក់យកបាន ទោះយប់ស្មើម៉ានក៏ឥតភ័យ ។

-ទី៤ អនុគាមិកនិធិ ជាបុញ្ញកិរិក្នុងហារទ័យ
គឺធ្វើកុសលផលថ្លាថ្លៃ បើជីវិតក្ស័យយកតាមបាន ។

ដោយ ភិក្ខុកល្យាណរតោ **ខាន់ សុិនសេម**

២៧_ទុក្ខ ៤គង

-មនុស្សសត្វគ្រប់រូបតែងខ្វល់ខ្វាយ   ព្រោះទុក្ខទាំងឡាយបួននេះណា
ដក់ជាប់ក្នុងចិត្តគ្រប់អាត្មា   រៀងរាល់រូបាក្នុងលោកីយ៍ ។
-មិនថាអ្នកក្រឬអ្នកមាន   អាក្រក់ល្អខ្ជិនខ្នៀនប្រុសឬស្រី
សុទ្ធតែកើតទុក្ខជាប់រាល់ថ្ងៃ   ព្រោះតែអាស្រ័យត្រៃលក្ខណៈ[១] ។
-ឯទុក្ខតែងកើតពិតជាមាន   ព្រះពុទ្ធទ្រង់បានចែងចារជាក់
ថាមានបួនយ៉ាងឥតមានវាក់   សូមអស់លោកអ្នកចាំឱ្យច្បាស់ ។
-ទី១ ឱ្យឈ្មោះ ជាតិទុក្ខ   ការកើតសព្វមុខគ្រប់ជាតិសាសន៍
មនុស្សសត្វទេព្តាតយ្ហោក្រាស់   ពិតប្រាកដណាស់មានក្តីព្រួយ ។
-ទុក្ខព្រោះកើតនេះជាកង្វល់   នឹងធ្លាក់ទៅដល់សត្វណាមួយ
វិលវល់ក្នុងភពបីកើតត្រួយ   ឱ្យមានទុក្ខព្រួយព្រោះការកើត ។
-ការកើតនេះមកពីអវិជ្ជា   ដក់ជាប់ត្រៃទ្វារជនប្រុសស្រី
បាំងភ្នែកមនុស្សសត្វទាំងយប់ថ្ងៃ   ធ្វើអកុសលបីនាំកម្មក្រាស់ ។
-ទី២ ឱ្យឈ្មោះ ជរាទុក្ខ   ប្រែថាជាទុក្ខព្រោះតែចាស់
ដូចបានឃើញស្រាប់នឹងភ្នែកច្បាស់   មិនយូរពិតណាស់កើតជរា ។

-មនុស្សសត្វសម្បត្តិទ្រព្យវត្ថុក្ដី	យូរឆ្នាំ ខែ ថ្ងៃ គង់ពុំជា
ប្រើយូរៗទៅចាស់ដូចគ្នា	សូមអ្នករាល់គ្នាកុំវង្វេង ។
-ទី៣ ឱ្យឈ្មោះ ព្យាធិទុក្ខ	ប្រែថាជាទុក្ខព្រោះតែឈឺ
មានរោគក្នុងកាយកើតជម្ងឺ	សព្វសត្វតែងឈឺជៀសពុំរួច ។
-មានក្រស្រីប្រុសក្មេងចាស់ក្ដី	ទូទាំងលោកីយ៍ច្បាស់ជាធ្លួច
គង់តែមានឈឺជៀសពុំរួច	ជីវិតនិងខូចបាត់រាងកាយ ។
-ទី៤ ឱ្យឈ្មោះ មរណទុក្ខ	នេះជាប្រមុខសត្វទាំងឡាយ
មនុស្សសត្វទេវលោកទាំងអបាយ	គង់តែបែកធ្លាយខ័ន្ធទាំងប្រាំ(២) ។
-ការស្លាប់នេះពិតជាទុក្ខធំ	កើតគ្រប់និគមជាប្រចាំ
រៀងរាល់ថ្ងៃ ខែ នាទី ឆ្នាំ	មានជាប់ប្រចាំឥតស្រាកស្រាន្ត ។
-ដើម្បីឱ្យរួចពីក្ដីទុក្ខ	ដូចទាំងបួនមុខចូរផ្ដាំប្រាណ
កាន់សីលភាវនាសមាធិក៏បាន	នោះទើបឃ្លាតប្រាណពីក្ដីស្លាប់ ។
-ព្រះពុទ្ធសម្ដែងប្រោសទេសនា	សព្វមនុស្សទេវតាឱ្យបានស្ដាប់
ថា កើត ជរា ព្យាធិ ស្លាប់	នាំមនុស្សអួរអ័ព្ទក្នុងវដ្ដៈ ។
-ដើម្បីកុំឱ្យមានការស្លាប់	ចូរអ្នកប្រញាប់កាន់សីលជាក់
សិក្សាប្រតិបត្តិតាមសាវ័ក	ព្រះពុទ្ធនោះជាក់បាននិព្វាន ។

-បើបាននិព្វានគ្មានកើតស្លាប់ គ្មានភាពអួរអ័ព្អអន្តរធាន
ព្រោះនោះជាឋានល្អរកគ្មាន មនុស្សសត្វទៅបានដោយកម្រ ។

---

(១) -ត្រៃលក្ខណ៍-ត្រ័យលក្ខណ៍ (ត្រៃលោក) សំដៅយកលក្ខណៈទាំង៣ប្រការគឺ: (អនិច្ចលក្ខណៈ = លក្ខណៈមិនទៀង១) (ទុក្ខលក្ខណៈ =លក្ខណៈ ជាទុក្ខ១)(អនត្តលក្ខណៈ=លក្ខណៈមិនមែន ជារបស់ ខ្លួន១)

(២) -ខ័ន្ធទាំងប្រាំ=ឬ ហៅថា =(បញ្ចក្ខ័ន្ធ) "បានដល់ " រូបក្ខ័ន្ធ១, វេទនាខ័ន្ធ១ , សញ្ញាខ័ន្ធ១ ,សង្ខារក្ខ័ន្ធ១ ,វិញ្ញាណក្ខ័ន្ធ១

ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**

២៨-(សុខោបុញ្ញស្ស ឧច្ចយោ)

ប្រែថា: (ការសន្សំបុណ្យជារឿយៗ នាំមកនូវសេចក្តីសុខ) ។

១-មនុស្សក្នុងលោក មានច្រើនគគោក គួរស្វែងរកបុណ្យ
ធ្វើតិចធ្វើច្រើន ចូរកុំទម្រន់ ព្រោះការធ្វើបុណ្យ
នាំមកក្តីសុខ ។

២-សុខតិចសុខច្រើន នាំមនុស្សឱ្យកើន ចំរើនផ្កាលសុខ
ញ៉ាំងឱ្យសព្វសត្វ បានជោគគ្រប់មុខ កាត់ក្តីស្មាញស្មុគ្រ
ស្វែងរកក្តីល្អ ។

៣-ក្តីល្អនេះហើយ ពុទ្ធបរិស័ទអើយ គឺជាព្រះធម៌

នាំសត្វឆ្លងផុត អបាយភូមិនោះហ្ន៎ គួរធ្វើបន្ត
ទើបល្អរកគ្មាន ។

៤-បើមានសុខហើយ សូមកុំកន្តើយ ខំធ្វើសីលទាន
ចំរើនភាវនា ទើបបញ្ញាមាន នាំអ្នកឱ្យបាន
មានសុខសិរី ។

ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**

២៩_គិតទៅ

-គិតទៅមនុស្សសត្វ មានច្រើនពេកក្កាត់ រស់ក្នុងលោកា
ទាំងក្មេងទាំងចាស់ ប្រុសស្រីគ្រប់គ្នា សុទ្ធមានកម្មពៀរ
តាមកម្មឱ្យផល ។

-គិតទៅកម្មព្រេង បច្ច័យតាក់តែង នាំមនុស្សឱ្យដល់
រសាត់ដូចចក បក់បោកតាមខ្យល់ វិវក់វិលវល់
ក្នុងជលសា ។

-គិតទៅសត្វលោក ខ្លះមានទ្រព្យភោគ មានជោគវាសនា
មានសព្វមានគ្រប់ ទាសីទាសា សព្វស្រែចំការ

ក៏មិនមានខ្វះ ។

-គិតទៅអ្នកមាន សំបូរធនធាន មានសព្វដេរដាស
តែត្រូវប្រយ័ត្ន ការពារឱ្យណាស់ ក្រែងជួបកម្មក្រាស់
ទៅអនាគត ។

-គិតទៅមានទ្រព្យ តែងកើតទុក្ខជាប់ មិនដែលរលត់
មិនថាពេលថ្ងៃ ឬក៏ពេលយប់ កើតឡើងសព្វគ្រប់
ព្រោះតែសម្បត្តិ ។

-គិតទៅសព្វថ្ងៃ មនុស្សមានតម្លៃ ត្រូវមានចិត្តកាត់
លះបង់តណ្ហា ស្រីស្រាល្បែងល្បាត់ នោះទើបឱ្យសត្វ
មានក្តីសុខសាន្ត ។

-គិតទៅមនុស្សយើង ដល់ពេលធំឡើង ចង់មានចង់បាន
ធនធានសម្បត្តិ ផ្ទះម៉ូតូឡាន មាសពេជ្រកល្យាណ
ថែមទាំងយសសក្តិ ។

-គិតទៅមានយស មានកេរ្តិ៍មានឈ្មោះ រស់ទាំងគ្រោះថ្នាក់
បើខំធ្វើល្អ បវរឥតដាក់ កាន់ឡើងបុណ្យសក្តិ
មានយសសិរី ។

-គិតទៅអ្នកក្រ រស់ទាំងត្រដរ ជាប់ប្រចាំថ្ងៃ

បានល្ងាចខ្វះព្រឹក សែនទឹកព្រួយភ័យ កើតទុក្ខរឹងរៃ
ព្រោះតែចង់រស់ ។
-បើបានរស់ហើយ កុំនៅកន្តើយ ត្រូវសាងកិត្តិយស
ជួយជាតិសង្គម ទើបសមមានឈ្មោះ អ្នកមានកិត្តិយស
ឧត្តមថ្លៃថ្លា ។

ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**

៣០-សម្តីបុគ្គល ៤យ៉ាង (បទពាក្យប្រាំពីរ)

-សម្តីបុគ្គលមានច្រើនគគោក រស់នៅក្នុងលោកយើងសព្វថ្ងៃ
មិនថាក្មេងចាស់ប្រុសឬស្រី មានក្រសេដ្ឋីមានដូចគ្នា ។
-សម្តីបុគ្គលមានច្រើនយ៉ាង តាមបុគ្គលសាងផ្លូវវាចា
បើគិតឱ្យខ្លីផ្លូវធម្មា មានបីប្រការក្នុងគម្ពីរ ។
-មួយឱ្យឈ្មោះថាសម្តីលាមក ពោលពាក្យកុហកអាក្រក់ពេញទី
ប៉ុនខាងលែបខាយយ៉ាងសំភី គម្រង់ពេញទីពេញនិគម ។
-សម្តីរុះរោយឥតប្រយោជន៍ ចាក់ដោតនាំល្មោចខ្លោចសង្គម
ឃើញគេធ្វើល្អប្រឹងសើចយំ គ្រួសាររលំមិនដឹងខ្លួន ។
-ពីរឱ្យឈ្មោះថាសម្តីទឹកឃ្មុំ អាចកើតទុក្ខធំមកជូនៗ
និយាយពាក្យផ្អែមក្លែមមាំមួន ឯទង្វើខ្លួនខុសស្រឡះ ។
-ព្យកែលលួងលោមដោយពាក្យល្អ ផ្អែមជាងមេស្អពេកពិតហោស់
លែបខាយវោហាថាដូចច្បាស់ តែផ្ទុយក្រឡាស់ពីទង្វើ ។
-ចចារចេញចូលរាល់សារស័ព្ទ និយាយរ៉ាយរ៉ាប់ប្រាប់គ្មានស្មើរ
បើមនុស្សល្ងង់ខ្លៅឬភ្លីភ្លើ ពិតជាសើរើព្រោះពាក្យផ្អែម ។
-សម្តីទឹកឃ្មុំចូរចាំថា ប្រយ័ត្នសោកាត្រូតបន្ថែម
ព្រោះថ្នាក់ខ្លាំងហោសសម្តីផ្អែម ចូរអ្នកគិតថែមមុននឹងគួរ ។

-សម្ដីទឹកឃ្មុំផ្អែំវាចា ញ៉ាំងសព្វសត្វាឱ្យមូទូ
មុនអ្នកនឹងជឿចូរគិតគូរ កុំឱ្យទុកយូរកើតអន្តរាយ ។
-បីនោះឱ្យឈ្មោះសម្ដីក្រអូប ជាធម្មស្ដួបចិត្តស្រស់ស្រាយ
ពោលពាក្យបែបណាព្រមទាំងកាយ ឱ្យល្បីខ្ចរខ្ចាយលើសកល ។
-សម្ដីបែបនេះចូរជឿចុះ ញាតិញោមស្រីប្រុសចូរគិតដល់
ធ្វើឱ្យលោកអ្នកនឹងបានផល យោងអ្នកឱ្យយល់ផលថ្លៃថ្លា។
-សម្ដីពីរោះព្រោះពាក្យពិត សម្ដីមានរិទ្ធិព្រោះវាចា
អ្នកប្រាជ្ញបណ្ឌិតតែងពោលថា ផ្លូវនាំសត្វាឆ្ពោះនិព្វាន ។

ដោយ **ភិក្ខុកល្យាណរតោ ខាន់ ស៊ិនសេម**

៣១-ទុក្ខស្ត្រីប្ដីប្រមឹក (បទពាក្យ ៧)

-ឱស ឱ..លោកអើយមើលប្ដីខ្ញុំ អ្នកស្រុកអ្នកភូមិតែងសរសើរ
ធ្លាប់តែធ្វើការសព្វសារពើ ឥឡូវល្ងីល្ងើភ្លេចស្មារតី ។
-ភ្លេចទាំងប្រពន្ធការងារអស់ ភ្លេចទាំងកូនប្រុសទាំងកូនស្រី
គិតតែដើរផឹកទាំងយប់ថ្ងៃ គ្មានគិតតម្លៃក្រុមគ្រួសារ ។
-មួយថ្ងៃៗបើកភ្នែកមិនរួច ធ្វេសប្រហែសលួចលុយផឹកស្រា
ចាប់ទាំងមាន់ទាទាំងឆ្កែ ឆ្មា យកទៅប្រហារក្លែមគ្មានសល់ ។
-ស្រវឹងម្ដងៗចាំមើលចុះ មុខមាត់ច្រមុះមើលមិនយល់
ស្រវឹងត្រេងត្រោងរេពេញថ្នល់ ក្រហាយក្រហល់ស្រែកដូចគោ ។
-មិនត្រឹមស្រវឹងប៉ុណ្ណឹងទេ ថែមទាំងជៀលជេរច្រើនហែរហូរ
ឈ្លោះប្រពន្ធកូនធ្វើឫក្សជោរ ប្រព្រឹត្តបន្តរឿងចង្រៃ ។
-ពេលផឹកស្រវឹងដឹងតែបើកឆ្នាំង បញ្ចោរតួងតាំង ទះតប់វៃ
ប្រពន្ធកូនឯងរាល់តែថ្ងៃ គ្មានគិតកែឆ្នៃសាងគ្រួសារ ។
-ព្រលឹមស្រាងៗតាំងរវាម ដើងនៅមិនស្ងៀមតម្រង់តៀមស្រា
ដកមេទាំងព្រឹកឥតគិតការ ស្រវឹងឡូឡាជេរប្រពន្ធកូន ។
-ប្រពន្ធខំហាមប្ដីថាប្រុសបង កូនយើងទាំងសងប៉ុន៑ៗខ្លួន
ហេតុអ្វីលោកប្ដីមិនគិតកូន មិនគិតដល់រូនដែលវេទនា ។

-ញុំាល្ងាចខ្វះព្រឹកនឹកតែបង កូនប្រុសស្រីច្បងកូនពៅភ្ញា
រស់នៅលំបាកសែនវេទនា ព្រោះប្រុសពុំងារជាអ្នកផឹក ។
-យប់ផឹកភ្លាមទៅប្រុសពៅបង អាហេិតអូនផងតែងព្រួយនឹក
មកបាយជុំគ្នាទាំងល្ងាចព្រឹក ញុំាបាយញុំាទឹកជុំគ្រួសារ ។
-កែខ្លួនឱ្យឆាប់ទៅលោកប្តី កូនប្រុសកូនស្រីសែនខ្លោចផ្សា
រស់នៅសព្វថ្ងៃដូចឥតប៉ា ខ្មាសញាតិកាសព្វកន្លែង ។
-ខ្មាសសព្វខ្មាសគ្រប់ទាំងយប់ថ្ងៃ ខ្មាសញាតិប្រុសស្រីព្រោះបងអែង
អ្វីដែលបងធ្វើឥតមានក្រែង ផ្ទុយពីកន្លែងច្បាប់ស្វាមី ។

ដោយ **ភិក្ខុកល្យាណរតោ ខាន់ ស៊ិនសេម**

---

៣២. ទុក្ខប្តីសែនធ្ងន់ប្រពន្ធលេងល្បែង (បទពាក្យប្រាំពីរ)

-ញាតិអើយមើលចុះប្រពន្ធខ្ញុំ ពេលព្រឹករៀបចំចរយាត្រា
ស្លៀកពាក់ស្អាតបាតយ៉ាងសង្ហារ ដូចអ្នកធ្វើការរកស៊ីធំ ។
-លាបក្រែមថែមម្សៅដៅចិញ្ចើម បបូរមាត់សើមសមណាស់ម៉ុម
ធ្វើឯងសមសួនឬក្សរមទម តែចិត្តស្រីម៉ុមដូចផ្លែល្វា ។
-ការងារមិនធ្វើគិតតែដើរ ឈានជើងហិចហើររកគ្នីគ្នា
អង្គុយបត់ភ្នែនប្រឹងលេងបៀ តុងទីន តូលា តាមផ្ទះគេ ។
-ចេញតាំងពីព្រឹកមុនថ្ងៃរះ ចាកផុតពីផ្ទះមិនគិតទេ
ពេលចាញ់ម្តងៗគោងស្រែកជេរ ឡូឡាឥតទ្វេដាក់កូនចៅ ។
-ម៉ោងប្រាំបួនម៉ោងដប់យប់រាត្រី ស្រាប់តែឃើញស្រីចិត្តមួរម៉ៅ
ស្រែកជេរបញ្ចោរតាំងពីក្រៅ ជេរប្តីកូនចៅដាក់ផ្កាសា ។
-ចាញ់ប្រាក់អស់ខ្លាំងតាំងស្រែកយំ លក់អស់ដីភ្នំស្រែចំការ
ខ្សែកមាសពេជ្រចិញ្ចៀនត្រា លក់ហើយឆាប់រ៉ាទៅលេងទៀត ។
-អូសយ៉ិត ស៊ីគូរ ភ្លូ បារាំង កាតេ វៃ តាំងខ្លាំងបញ្ចេញស្នៀត
ចាក់ហ៊ោៗ ឥតមាយាទ ចេញហើយចេញទៀតចេញទាំងប្រាក់ ។
-ពេលវិលមកផ្ទះរករឿងប្តី ជេរតប់ហើយវាយកូនបណ្តោក់
គ្មានគិតដល់ប្តីខំសស្រាក់ រកស៊ីរកប្រាក់ចិញ្ចឹមកូន ។

-ប្តីខំកាប់គាស់រាស់កកាយ ទីជិតទីឆ្ងាយស្មើរតែសូន្យ
ដើម្បីរកប្រាក់មកចិញ្ចឹមកូន ទោះជីវិតសូន្យក៏មិនស្តាយ ។
-ចំណែកប្រពន្ធគ្មានគិតសោះ មិនគិតទាំងអស់ចិត្តរាយមាយ
ស៊ីចុកក្នុងផ្ទះសែនខ្ជះខ្ជាយ មិនគិតសំពាយញើសឈាមប្តី ។
-ល្មមហើយស្រីល្អចូរកែគិត ទាន់មានជីវិតនៅក្មេងខ្ចី
ខំប្រឹងថែកូនហើយនិងប្តី ទើបមានសិរីក្នុងគ្រួសារ ។
-តស៊ូលក់ដូរចូរព្យាយាម ព្រោះជាទំនៀមត្រូវឧស្សាហ៍
កុំខំប្រព្រឹត្តល្បែងពាលា ទើបរស់ល្អជាក្នុងសង្គម ។
-ចំណែករូបខ្ញុំគឺជាប្តី កើតទុក្ខរីងរៃរស្មើរស្រែកយំ
ពេលឃើញប្រពន្ធសម្លាញ់ខ្ញុំ ធ្វើឥតស័ក្តិសមភ្នែកញាតិខាង ។
-ល្ហើយទ្រាំចុះតាមកម្មពៀរ ព្រោះអីវេរាខ្ញុំបានសាង
មកពីអតីតគ្មានសំណោង ទើបបានជួបនាងទាំងហេងស៊យ ។

ដោយ **ភិក្ខុកល្យាណរតោ ខាន់ សុិនសេម**

៣៣_ចាំចាស់បន្តិចសិន បទពាក្យប្រាំបី

-មនុស្សសត្វលោកកើតមកមិនទៀង ជួនរាំងជួនភ្លៀងជួនថ្ងៃហើយយប់
ជួនក្តៅជួនត្រជាក់មានសព្វគ្រប់ មិនថាថ្ងៃយប់ព្រោះអនិច្ចតា ។
-មនុស្សកើតមកទាំងប្រុសស្រី លើភពផែនដីនៃនាលោកា
សុទ្ធជៀសមិនរួចពីក្តីមរណា អនិច្ចំ ទុក្ខា អនត្តា ជាហេតុ ។
-កើតចាស់ឈឺស្លាប់នោះមានមែនពិត ជរាភ្លឺល្ងិតឃើញច្បាស់ក្រឡែត
ឯអ្នកសេពកាមក៏មិនចេះឆ្អែត ឯមនុស្សចិត្តប្រែតក៏សំបូរ ។
-វត្តវាអារាមអាស្រមនានា បរិស័ទគ្រប់គ្នាច្រើនហែរហូរ
ធ្វើបុណ្យដាក់បាត្រសែនស្អាតផង់ផូរ នមស្សការបន្ទូរល្អប្រពៃ ។
-គ្រប់គ្នាទៅវត្តឱ្យច្រើនសន្ធឹក ទាំងថ្ងៃទាំងព្រឹកទាំងប្រុសទាំងស្រី
ទាំងក្មេងទាំងចាស់ទាំងប្រពន្ធប្តី គេចេះលកលៃស្វែងរកកុសល ។
-ស្តាប់ធម៌ទេសនាប្រាថ្នាចង់ចេះ ឱ្យកើនតម្រិះក្រែងលោបានផល
មួយថ្ងៃបន្តិចយូរៗបានដល់ និព្វានជាផលឆ្លងផុតអវិចី ។
-បុណ្យតូចបុណ្យធំមានច្រើនគគ្រឹក ខ្លួនឯងមិនទឹកអើពើបន្តិចអី
ខ្លួនកាន់តែចាស់ជារៀងរាល់ថ្ងៃ មិនរវាសរវៃទៅវត្តទៅវ៉ា ។
-ញាតិខំស្រែកហៅថាមកទៅបុណ្យ ឈប់ចាំបន្តិចសិនទៅមុនចុះតា
រវល់តែជាប់ធ្វើកិច្ចធ្វើការ ទៅមុនចុះតាចាំចាស់បន្តិច ។

-មួយក៏បបួលពីរក៏បបួល ថាជាប់រវល់ទៅបានដូចម្ដេច
បើទៅខាងកើតជាប់នៅខាងលិច ឱ្យទៅដូចម្ដេចបើកូនអត់ស៊ី ។
-បើរវល់ទៅវត្តអ្នកណាមើលកូន ប្រពន្ធផងបងប្អូនកូននៅមូលមីរ
បើទៅតែវត្តកូនបានអីស៊ី ហ្អើយម៉ាក់មីចាំចាស់បន្តិចសិន ។
-មិនទាន់ចាស់ផងរោគឆ្លងមកដល់ តាកើតរោគខ្យល់ដួលស្លាប់ថ្មើមក្រិន
គេបបួលទៅវត្តថាចាំបន្តិចសិន ឥឡូវតាមិនបានទៅសោះឡើយ ។
-រឿងធ្វើបុណ្យទានកុំចាំដល់ចាស់ គេបបួលខ្លាំងណាស់កុំកន្តើយ
ព្រោះការធ្វើបុណ្យនាំឆ្លងដល់ត្រើយ ពុទ្ធបរិស័ទអើយឆ្លងផុតអបាយ ។
-ធ្វើបុណ្យដាក់បាត្រសន្សំកុសល ញ៉ាំងសត្វបានដល់បញ្ញាស្រស់ស្រាយ
គឺជាកំណើតសត្វផងទាំងឡាយ តែងបានរសាយផុតអស់កង្វល់ ។
-បើធ្វើបុណ្យម្ដងឆ្លងបានបន្តិច បើកធ្វេចៗបន្តិចនឹងដល់
សម្បត្តិប្រពៃផុតទុក្ខខ្វាយខ្វល់ ឋានដែលទៅដល់គឺព្រះនិព្វានហោង ។

ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**

៣៤_ផ្កាឈូក បទកាកគតិ

-ឈ្មោះវារីជាតិ មានច្រើនព្រោងព្រាត តាមបឹងស្ទឹងអូ
គ្រប់ទីតំបន់ ច្រើនគន់ហែរហួរ យោលតាមជំនោរ
វាយោបក់បោក ។

-អាច្រោតត្រជាក់ សន្សើមក៏ធ្លាក់ ជំនោរបក់មក
ត្រូវឈូករវាំ លំនាំយោលយោក រវាំទៅមក
តាមបែបធម្មជាតិ ។

-រីផ្កាឈូកបឹង រីកស្រស់ម្លឹងៗ សម្លឹងមិនឃ្លាត
ដុះចេញពីភក់ អាក្រក់ជួរជាតិ ភក់នោះស្អុយទៀត
ពុំគួរបេតី ។

-ទោះជាយ៉ាងណា សម្រស់ឈូកផ្កា រីកស្រស់ប្រិមប្រិយ៍
កាច់មកបូជា ព្រះរតនត្រៃយ៍ នាំមកសិរី
ដល់មនុស្សគ្រប់គ្នា ។

-ភក់នោះស្អុយមែន បើគិតមែនទែន គួរឱ្យរាំទា
ចំណែកឈូកផ្កា ស្រស់ល្អសោភា មិនស្អុយដូចជា
ភក់នោះសោះឡើយ ។

-ឈូកផ្កាប្រៀបមនុស្ស ខ្លួនក្រក្រៀមក្រោះ តែមិនកន្តើយ

ចេះបន្ទន់ចិត្ត ក្បៀកកិតបង្អើយ នឹងសប្បុរសហើយ

បានស្បើយទុក្ខា ។

-មនុស្សអាក្រក់ហើយក្រ រស់ទាំងត្រដរ ដោយក្ដីខ្លោចផ្សា

តែចេះភ្ជាក់ខ្លួន ថែធួនសាសនា រក្សាសីលា

តាមសិក្ខាបទ ។

-រក្សាសីលទាន ញ៉ាំងចិត្តឱ្យមាន បញ្ញាប្រាកដ

ដូចរូបចាកភក់ អពាយទាំងម៉ត់ ថែសិក្ខាបទ

វិន័យសាសនា ។

-លះកាត់ផ្ដាច់ផ្ដិល ជម្រះមន្ទិល លះអស់តណ្ហា

ខំប្រឹងធ្វើទាន ទាន់មានសង្ខារ ប្រព្រឹត្តត្រៃទ្វារ

ដោយសុចរិត ។

-កែខ្លួនបានឆាប់ បានយ៉ាងប្រញាប់ ស្មោះសពិត១

ដុះចេញពីភក់ ក្លាយជាកេណ្ឌិត បញ្ញាល្អល្អិត

គួរឱ្យជ្រះថ្លា ។

-ចេះលះបង់ខ្លួន មិនលាក់បំពួន សីលសាស្ត្រវិជ្ជា

បង្ហាត់បង្រៀន បរិស័ទគ្រប់គ្នា ឱ្យស្គាល់ធម្មា

ស្គាល់បាបស្គាល់បុណ្យ ។

៣៥_ទឹកភ្នែកមេម៉ាយ

–វាយោបោកផាត់រំសាត់ពពក ជំនោរផាត់មកនៅក្នុងរាត្រី
ស្មៅត្រូវសន្សើមលាស់ឡើងត្រួយខ្ចី ចំណែកស្រស់ស្រីស្រពោនក្រៀមស្វិត ។
-ពេលធំដឹងក្តីម៉ុមស្រីសប្បាយ សម្ផស្សឆោមឆាយគួរឱ្យអាណិត
មិនចេះដើរលេងទោះយប់ថ្ងៃល្ងិត គោរពប្រតិបត្តិតាមពាក្យពុកម្តាយ ។
-ការងារក្នុងផ្ទះរួតរះខំធ្វើ មិនល្ងង់ល្ងិលល្ងើបញ្ញាស្រស់ស្រាយ
រៀបចំបោកគក់សំពត់អាវម្តាយ ឥតមានរាយមាយទុកសមប្រពៃ ។
-និយាយអំពីចុងភៅដាំស្ល ដាំបាយបបរសែនល្អពេកក្រៃ
មិនជូរមិនចត់មិនសាបមិនប្រៃ សមតាមហឫទ័យនៃចិត្តម្តាយពុក ។
-ដល់ពេលមានប្តីក្រក្រីតោកយ៉ាក រស់នៅលំបាកឥតស្រោកកើតទុក្ខ
មានកូនពីរបីប្រុសស្រីនាំមុខ នោះជាជង្រុកនៃកម្មវាសនា ។
-មិនយូរប៉ុន្មានបានកើតវិបត្តិ ប្តីនាងស្លាប់បាត់កើតទុក្ខខ្លោចផ្សា
រស់ស្ទើរតែឆ្កួតដូចនាងបដាចារ ស្ទើរក្ស័យមរណោចាកភពផែនដី ។
-តែនឹកអាណិតដល់កូនទាំងអស់ ទាំងស្រីទាំងប្រុសទាំងពីរទាំងបី
ភ្នែកបើកក្រឡេតឥតមានអីធី ឱកូនប្រុសស្រីអភ័ព្វម្លេះណា ។
-កូនៗនៅតូចមិនទាន់ដឹងក្តី យំទាចំណើស្រែករកតែប៉ា
ម៉ែអើយពេលនេះពុកខ្ញុំទៅណា ម្តេចមិនឃើញប៉ាត្រឡប់មកផ្ទះ ។

-ពេលឮកូនពោលពំនោលបែបហ្នឹង ក្នុងទ្រូងសែនតឹងឱរ៉ាស្មើរប្រេះ
ទឹកភ្នែកជោកថ្ពាល់ខ្វាយខ្វល់អ្វីម្លេះ ហេតុអ្វីជានេះកម្មតាមផ្ដន្ទា ។
-កូនអើយគេងទៅពៅអើយកុំយំ អាច្រោតភ្លៀងធំម៉ុមសែនរងារ
បើប៉ានៅរស់ជួបជុំនឹងគ្នា ម្លោះឥតរងារទេណាកូនអើយ ។
-ខំស៊ីឈ្នួលគេដើម្បីរកប្រាក់ ញើសឱ្យសស្រាក់មិននៅកន្តើយ
ខំចិញ្ចឹមកូនឱ្យបានដល់ត្រើយ កូនប្រុសស្រីអើយអភ័ព្វម្ល៉េះទេ ។
-រស់នៅមេម៉ាយឆោមឆាយស្រអាប់ រស់ដូចជាស្លាប់ចុកចាប់ឥតទ្វេ
រស់នៅកំព្រាដូចកូនឥតមេ លំបាកម្លេះទេលើភពផែនដី ។
-ម្យ៉ាងទៀតញាតិមិត្តគិតពោលមើលងាយ ថាខ្លួនមេម៉ាយដើរឆ្ងាយឥតប្ដី
ចេញចាកចោលផ្ទះទុកកូនប្រុសស្រី ទាំងពីរទាំងបីឱ្យនៅកំព្រា ។
-ចេញទៅរកប្រាក់ចិញ្ចឹមកូនៗ មានញាតិបងប្អូនមើលងាយនិន្ទា
ដៀលសព្វដៀលគ្រប់ឱ្យខ្ញុំវេទនា រស់នៅឯកាក្នុងគុកលោកីយ៍ ។
-ឱកម្មអើយកម្មម្ដេចមកពង្រាត់ ឱ្យខ្ញុំប្រាសព្រាត់ចាកពីស្វាមី
ទុកឱ្យរូបខ្ញុំនិងកូនប្រុសស្រី រស់ទុករីងរៃដោយក្ដីចំបែង ។
-កាប់គាស់រាស់កាយចំណាយកម្លាំង មកចិញ្ចឹមឆ្នាំងខ្ជួបប្រាំងម្នាក់ឯង
ធ្វើការហាលថ្ងៃក្ដៅស្មើរបែកផ្សែង សាត់ត្រាត់សែងត្រែងព្រោះចិញ្ចឹមកូន ។

-រស់នៅម្នាក់ឯងចំបែងខ្លោចចិត្ត គេគ្មានអាណិតញាតិមិត្តបងប្អូន
គេសែនមើលងាយទាំងម្តាយទាំងកូន ជីវិតស្ទើរសូន្យក្នុងវដ្តសង្សារ ។
-មួយថ្ងៃៗឥតមានទំនេរ លំបាកម្ល៉េះទេគួរឱ្យអនិច្ចា
ពេលព្រឹកជូនកូនទៅរៀនសាលា ថ្ងៃឡើងទៅផ្សារលក់ស្ពៃត្រកួន ។
-ខំប្រឹងរកប្រាក់ទាំងក្តីវេទនា ទឹកភ្នែកគ្រប់គ្រាព្រោះចិញ្ចឹមកូន
មិនពឹងសាច់ញាតិតាឬជីដូន ខ្ញុំខំចញ្ចឹមកូនតែម្នាក់ឯង ។
-ថ្ងៃខ្លះដាច់បាយតាំងតែពីព្រឹក ដាច់បាយដាច់ទឹកកូនយំក្តែងៗ
ដើរខ្ចីបុលគេកាន់ទាំងអំបែង សុំទានម្នាក់ឯងយកឱ្យកូនញុំា ។
-នឹកឡើងតូចចិត្តអាណិតកូនប្រុសស្រី ស្ទើរបែកហឫទ័យឱ៉ាប្រេះស្រាំ
រស់នៅកើតទុក្ខជាច្រើនខែឆ្នាំ ទុក្ខសោកប្រចាំព្រោះតែមេម៉ាយ ។
-បើខ្លួនមេម៉ាយក៏មេម៉ាយចុះ ខ្ញុំមិនធ្វើខុសពីពាក្យពុកម្តាយ
ខ្ញុំខំប្រព្រឹត្តកុសលទាំងឡាយ បុណ្យទានជិតឆ្ងាយក៏ខ្ញុំទៅធ្វើ ។
-ខ្ញុំចិញ្ចឹមកូនខ្ញុំថ្នាក់ថ្នម បំពេបីបេមថ្នមដោយទង្វើ
ការងារសព្វគ្រប់សព្វទាំងសារពើ ខ្ញុំមិនភ្លឺភ្លើបោះបង់កូនឡើយ ។
-ធ្វើម្តេចជាតិនេះខ្ញុំកើតមកក្រ រស់ទាំងត្រដរកើតទុក្ខគ្មានស្បើយ
រឿងធ្វើបុណ្យទានខ្ញុំមិនចោលឡើយ ខំធ្វើដល់ត្រើយសុខសួគ៌និព្វានហោង ។

ដោយ ភិក្ខុកល្យាណរតោ ខាន់ សុិនសេម

៣៦-ទំនួញកូនមិនស្តាប់ឪពុកម្តាយ (បទពាក្យ ៨)

-អាព្រោតភ្លៀងធ្លាក់ត្រជាក់ជំនោរ ធម្មជាតិធ្ងូចថ្ងូរស្ងួរដំរែកទឹក
វាយោបក់បោកព្រួស្សួរសន្ធឹក ក្នុងចិត្តក្ដួចនឹកដល់ឪពុកម្តាយ ។
-ឃ្លាតបងឃ្លាតប្អូនឃ្លាតទាំងមិត្ត ឃ្លាតញាតិសែនស្និទ្ធឃ្លាតសែនឆ្ងាយ
រស់នៅក្នុងគុកទុក្ខមិនរសាយ សាច់ស្បែករូបកាយសែនស្គមស្គាំង ។
-ក្នុងពន្ធនាគារត្រាំត្រារូបកាយ សម្រស់អោមឆាយសែនស្លេកស្លាំង
ក្នុងខ្លួនហាក់ដូចជាគ្មានកម្លាំង ស៊ីបាយក្នុងឆ្នាំងដូចសត្វតិរច្ឆាន ។
-ដៃជើងទាំងពីរជាប់ឃ្នាងខ្នោះ ក ជាប់ទាំងអស់រើងាកមិនបាន
រស់នៅលំបាកគ្មានស្រាកគ្មានស្រាន្ត ពេលភ្ញាក់ស្មើម៉ានឈឺអស់សព្វកាយ ។
-យកផ្ទាំងសិលាមកធ្វើជាខ្នើយ ដេកកើយប្រថពីដូចសត្វទន្សាយ
ក្នុងគុកងងឹតរៀងរាល់តែថ្ងៃ គេតប់គេវាយគ្មានក្ដីអាណិត ។
-ជីវិតរស់នៅដូចជាការស្លាប់ រស់ទាំងអួរអ័ព្ទនៅក្នុងដួងចិត្ត
បាបកម្មទាមទារតាំងពីអតីត នេះព្រោះប្រព្រឹត្តនូវកម្មលាមក ។

-ពុកម្តាយខំហាមថាកុំឱ្យធ្វើ កូននៅតែល្មើធ្វើបែបគំរក់
ទង្វើដែលគេស្អប់ចិត្តចង់ភ្លក់ កម្មដេញវីវក់តាមមកទាន់ ។

-ការងារមិនធ្វើដើរតែខូច ធ្វើចោរដើរលួចសព្វទាមាន់
លួចចុះលួចឡើងម្ចាស់មកទាន់ មើលទៅវាគ្រាន់សំរាំក្រាស់ ។

ដោយ ភិក្ខុកល្យាណោរតោ **ខាន់ ស៊ិនសេម**

៣៧_ជីវិតពិត (បទភាគតិ

-អនិច្ចារូបខ្ញុំ ពីតូចដល់ធំ មានទុក្ខឥតស្បើយ
កាលនៅពីតូច ពុំមានល្ហែល្ហើយ មានទុក្ខឥតស្បើយ
មកពីរុព្វេ ។

-ពេលធំដឹងក្តី គ្មានសិទ្ធិសិរី ប្រិមប្រិយ៍នឹងគេ
រស់នៅលំបាក តោកយ៉ាកម្លេះទេ រស់គ្មានទំនេរ
តាមកម្មកុសល ។

-មកពីជាតមុន សន្សំបានទុន បានតិចឱ្យផ្តល់
កើតមកជាតិនេះ កម្មតាមឱ្យផល ឱ្យខ្ញុំវិលវល់
ក្នុងវដ្តសង្សារ ។

-គ្មានលាភគ្មានយស គ្មានស័ក្តិគ្មានឈ្មោះ រស់ឥតបញ្ញា
ត្រូវញាតិជិតខាង តាមមកផ្ដន្ទា ឱ្យខ្ញុំវេទនា
រស់ដូចជាស្លាប់ ។

-រស់គ្មានប្រពន្ធ ឥតមានទ្រព្យធន ជីវ៉ាអូរអត់
រស់នៅតោកយ៉ាក លំបាកជាងស្លាប់ ឱវ៉ាចុកចាប់
លើភពផែនដី ។

-ដើរធ្វើខ្ញុំគេ គ្មានពេលទំនេរ ឥតទ្វេរាល់ថ្ងៃ

ហើយធ្លាក់ខ្លួនឈឺ ជម្ងឺរ៉ាំរ៉ៃ រស់គ្មានសិរី

ក្នុងឆាកជីវិត ។

-ថ្ងៃណាទៅហ្នំ ផុតពីក្រីក្រ ចាកភពងងឹត

ខ្ញុំនឹងធ្វើទាន សាងស្ពានជីវិត កសាងសុចរិត

ចិត្តពិតស្រឡះ ។

-ខ្ញុំនឹងធ្វើល្អ តាមសច្ចៈធម៌ ព្រះពុទ្ធទ្រង់ត្រាស់

រក្សាសីលទាន ធនធានមានច្បាស់ ពិតប្រាកដណាស់

ដល់ឋានសួគ៌ា ។

-មនុស្សល្ងង់យកបេះដូងដាក់នៅក្នុងអណ្តាត

-មនុស្សឆ្លាតយកអណ្តាតដាក់ក្នុងបេះដូង ។

-មនុស្សគេយកសម្តីដឹងគេយកភ្លុក ចាស់ចារជាទំនុកទុកប្រដៅ

នាងនួនខ្លឹមក្នុងឬស្សីខ្លឹមក្រៅ ខ្លឹមមនុស្សសំដៅនូវពាក្យសច្ចៈ ។

រៀបរៀងដោយ **ភិក្ខុរតនញ្ញាណោ ម៉ាក់ សំអាត** ចៅអធិការ

វត្តរតនបុប្ផារាម (ហៅវត្តមហាខ្ញូង) នឹងជាធម្មធរអនុគណ

ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

៣៨-ជំនឿក្រៅព្រះពុទ្ធសាសនា

-សូរិយារៀបលិចបំភ្លេចលោកីយ៍ សូរិយាគង់ព្រៃបំភ្លឺលោកា
ព្រះច័ន្ទតែមួយបំភ្លឺរាត្រីយា គ្រាន់ជាងតារារះរាប់សិបលាន ។
-សមុទ្រទាំងបួនធំហើយសែនជ្រៅ អាចវាស់ជម្រៅនូវទឹកនោះបាន
រីទឹកចិត្តអនុស្សនៃខន្ធសន្តាន មិនអាចវាស់បានដឹងជម្រៅដែរ ។
-រីឯភ្នំធំភ្នំតូចនានា យកបូកផ្គុំគ្នាក៏មិនធំទេ
ភ្នំធំជាងគេគឺភ្នំព្រះសុមេរ៍ ធំខ្ពស់ដាច់គេនៅលើលោកា ។
-កំដៅដែលក្តៅគឺជាភ្នំភ្លើង នាំឱ្យមនុស្សយើងក្តៅរោលខ្លោចផ្សា
តែចាញ់ក្តៅចិត្តគំនិតមនុស្សា មនុស្សកាចឫស្យាប្រហារទ្វីបលោក ។
-ឯអ្នកជំនឿជឿក្រៅសាសនា មានច្រើនប្រការសារស័ព្ទគគោក
នាំឱ្យមនុស្សជឿជំនឿស្មោកគ្រោក បំផ្លាញសត្វលោកឯោកងក់ក្នុងភព ។
-ព្រះឥន្ទព្រះព្រហ្មព្រះយមរាជ ហោះហើរសព្វកាលសម្រាលក្តីទុក្ខ
ចេញពីវិមានមួយរំជួយគ្រប់ស្រុក នាំឱ្យស្នាញស្មុគ្រកើតទុក្ខវក់វី ។
-សូមសេពអាគមព្រះបរមឥសូរ ស្រែកឡើងបន្ទរហែរហូរគ្រប់ទី
ចុចម្រាមជើងមួយរំជួយធរណី ចុចម្រាមជើងពីររន្ទះពេញមេឃ ។
-សូត្រធ្មុំដែស្តាំប្រចាំត្រកូល ដាច់ទាំងកំពូលភ្នំក៏របែក
បើសេពដៃពីរធរណីប្រេះបែក រហែកទាំងមេឃបែកទាំងប្រថពី ។

-សូត្រផ្លុំៗ អាគមអំពើ រំជួយឋានលើ រង្គើឋានពីរ
សូមព្រះឥសូរបញ្ចេញឫទ្ធិ ព្រះឥសីនីបញ្ចេញកម្លាំង ។
-សូមសេពអាគមព្រះបរមឥសី ព្រមទាំងបារមីអ្នកតាភ្នំបាំង
ភ្នំធំភ្នំតូច ភ្នំស្រួចឫទ្ធិខ្លាំង បូកគោភ្នំជាំង និងភ្នំគូលេន ។
-បួងសួងបារមីភ្នំស្រីភ្នំប្រុស ភ្នំស្រង់ភ្នំស្រស់ភ្នំបត់ភ្នំបែន
ឱភ្នំដងរែកចែកខណ្ឌទល់ដែន ឱភ្នំឫទ្ធិសែនមកជួយខ្ញុំផង ។
-សូមអស់បារមីតាមព្រៃព្រឹក្សា សូមអស់ទេវតាមកជួយឃុំគ្រង
អារក្សទឹកអារក្សព្រៃអារក្សដីទាំងសង សូមជួយខ្ញុំផងឱ្យខ្លាំងលើសគេ ។
-ទោះបីបួងសួងបានខ្លាំងយ៉ាងណា ថ្ងៃក្រោយពិតជាគេចមិនផុតទេ
សង្ខារមកទាន់កើតទុក្ខឥតទ្វេរ គេចមិនផុតទេពីក្តីមរណា ។
-សូមអស់ញាតិមិត្តចូលគិតឱ្យឆ្ងាយ កុំគិតរាយមាយខុសច្បាប់តម្រា
ត្រូវជឿខ្លួនឯងកុំជឿនរណា ក្រៅពីដីកានៃព្រះសម្ពុទ្ធ ។
-ធ្វើល្អបានល្អធ្វើអាក្រក់បានអាក្រក់ បើអ្នកកុហកពិតជៀសមិនផុត
ធ្លាក់ទៅអវិចីក្នុងខ្ទះទឹកក្រុត យមរាជចាប់ដុតក្នុងភ្លើងនរក ។
-ត្រូវខំធ្វើល្អបវរថ្លៃថ្លា លះបង់តណ្ហាអវិជ្ជាឃោកឃក់
ជីវិតសង្ខារក្នុងផ្សារគ្មានលក់ ចូរកុំឱ្យឈ្លក់ក្នុងកាមឆន្ទះ ។
-រក្សាសីលទានជាស្ពានបវរ ប្រតិបត្តិព្រះធម៌បរចាកអប្បល័ក្ខ

ធ្វើបុណ្យដាក់បាតសាងស្ពានអមតៈ នោះទើបលោកអ្នកឈ្មោះល្អប្រពៃ ។
-ភ្ញាក់ឡើងលឿនឡើងបងប្អូនស្រីប្រុស ចូរអ្នកខំចុះសុចរិតទាំងបី
គោរពប្រតិបត្តិព្រះរតនៈត្រៃ ទើបមានសិរីថ្លៃថ្លាប្រសើរ ។
-ចំរើនភាវនា សមាធិ បញ្ញា ស្តាប់ធម៌ទេសនាគឺជាដំណើរ
ឆ្ពោះទៅនិព្វានជាឋានប្រសើរ នោះជាដំណើរឆ្លងភពអបាយ ។

ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**

៣៩-ជាតិជាចៅអធិការវត្ត

-ជាតិជាចៅអធិការវត្ត រស់នៅទៀងទាត់នឹងបាយគេ
គ្រាន់ចាំអារាមតាមទំនេរ រស់ពុំដូចគេអ្នកស្រុកឡើយ ។

-ជាតិជាចៅអធិការពិត រស់នៅពុំស្ថិតប្រើងមិនស្បើយ
ខំប្រឹងកសាងសំណង់អើយ ទូទាត់លាត់សើយសល់ត្រឹមខ្លួន ។

-ជាតិជាចៅអធិការស្មោះ រស់នៅសន្តោសញ្ញាតិនឹមនួន
ទោះជិតឬឆ្ងាយឬក្បែរខ្លួន ទោះ ខ្មែរ ចិន យួន តែងត្រូវការ ។

-ជាតិជាចៅអធិការធំ រស់នៅសុខុមប្រាក់សោយសា
ចាយវាយតាមចិត្តឥតគេថា បើមិនមុសាភូតកុហក់ ។

-ជាតិជាចៅអធិការត្រង់ រស់ស្មោះត្រង់មិនបោកឆក់
មិនកេងប្រវ័ញ្ចកករល្អក់ ជារឿងអាក្រក់ដល់ខ្លួនញាតិ ។

-ជាតិជាចៅអធិការខ្មែរ រស់នៅស្រុកស្រែពុំឃ្លៀងឃ្លាត
ពីបុរេញ្ញយសស័ក្តិរីកព្រោងព្រាត រីកហើយគ្រោតគ្រាតពិតមិនលោះ ។

-ជាតិជាចៅអធិការល្អ រស់នៅកម្រកើតជម្លោះ
ត្រូវគេរាប់អានសានគ្រាន្តយស រស់នៅសង្គ្រោះប្រជាហោង ។

ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០០៧ វត្តសុទស្សនារាម ជ្រោយចង្វា (កុដិលេខ ៦)

ដោយ **ធម្មបណ្ឌិត ម៉ៅ គឹមម៉េង**

៤០-កំហុសចៅអធិការឬ?

-ចៅអធិការចាំតែខុស ទាំងស្រីទាំងប្រុសចាំតែថា
បើកសាងកើតបានថ្លៃថ្លា ទោះធ្វើយ៉ាងណាមិនត្រូវចិត្ត ។
-ចៅអធិការចាំតែខុស ទោះខំដាំដុះយ៉ាងល្អិត
ក៏ពុំត្រូវតាមផ្គត់គំនិត នៃញាតិឆ្ងាយជិតចារិះគន់ ។
-ចៅអធិការចាំតែខុស ពិតមានកំហុសទោះស្រាលធ្ងន់
ព្រាកដទន្ទ្រានយ៉ាងជោជន់ ដូចទឹកជំនន់ជន់គ្រប់ខែ ។
-ចៅអធិការចាំតែខុស ពាក្យពេចន៍ចំរុះទោះមានស្នេហ៍
ក៏នៅតែបាបខាបមកក្បែរ ពាក្យមិនល្អដែរតាមពាក្យពោល ។
-ចៅអធិការចាំតែខុស ទោះបីជុំរុះប្រាក់ចំហ្វេល
ពុំកាន់ខ្លួនឯងក្រែងគេថ្កោល ក៏នៅពុំស្រួលតាមចិត្តឡើយ ។
-ចៅអធិការចាំតែខុស ទោះជាវិង្សរូសស្លូតក៏ដោយ
ក៏នៅពុំត្រូវណាញាតិអើយ តាមចិតអ្នកអើយឱ្យគ្រប់ដប់ ។
-ចៅអធិការចាំតែខុស រាល់ពេលឡើងចុះគ្រប់ត្រឡប់
ក៏នៅពុំគាប់ចិត្តឱ្យសព្វ នៃញាតិសំនប់ប្រុសស្រីអើយ ។

ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០០៧ វត្តសុទស្សនារាម ជ្រោយចង្វារ (កុដិលេខ ៦)

ដោយ **ធម្មបណ្ឌិត ម៉ៅ គឹមម៉េង**

៤១-ធាតុចនាផ្កាបិណ្ឌ

-អានិសង្សដុំបាយ នាំញាតិទាំងឡាយ ទៅកាន់សុខស្ថាន
ដាក់ដល់ទីទួល ប្រែប្រួលគ្រប់ប្រាណ ថែមបានសុខសាន្ត
ដល់សួគ៌ាលៃ ។

-អានិសង្សផ្កាបិណ្ឌ នាំកើតព្រះឥន្ទ ល្អយ៉ាងប្រពៃ
តាមយើងប្រាថ្នា សច្ចាថ្វាថ្លៃ កើតរាល់យប់ថ្ងៃ
ដែលយើងប្រាថ្នា ។

-ម្ហូបបាយហូរចាក់ កើតឡើងតាមថ្នាក់ គ្រប់ញាតិកា
បានហូបចុកឆ្អែត ប្រែប្រែតទេព្តា កែប្រែវាសនា
អាក្រក់ទៅល្អ ។

-ប្រេតរួចទុក្ខទោស លែងមានកំហុស ប្រែខ្មោចទោស
ប្រែស្ថានចាប់ជាតិ ឃ្លៀងឃ្លាតបវរ ខ្លះកើតកិន្នរ
ខ្លះកើតទេវ៉ា ។

-ខ្លះកើតជាមនុស្ស រីកធំស្រស់បស់ ចំរើនគ្រប់គ្រា
រកស៊ីមានបាន សព្វស្ថានវេលា ពូជពង្សមីងមា
ជីដូនជីតា ។

-ផ្កាបាយបិត្តបូរ ជាទីគំរូ ដល់ជនបច្ឆា

កូនចៅរៀនសូត្រ រហូតតគ្នា តាក់តែងរចនា
តាំងពីបុរាណ ។

-ផ្កាបិណ្ឌល្អស្រស់ ជាទីសម្រស់ នៃបុណ្យកល្យាណ
តាក់តែងបូជា ពុទ្ធាថ្កើងថ្កាន ដាក់ដល់ទីស្ថាន
ផុតទុក្ខតណ្ហា ។

-ផ្កាបិណ្ឌនិស្ស័យ នាំផុតភពបី គ្រប់រូបសង្ខារ
តាក់តែងថ្វាត់ថ្វាយ ចំណាយបូជា ដោយញាតិគ្រប់គ្នា
មាននៅនឹងមុខ ។

-ហេតុនេះសូមផ្សង គ្រប់ញាតិភូមិផង សូមរួចចាកទុក្ខ
បានជួបជុំគ្នា គ្រប់គ្រាបានសុខ ដល់ទីស្រណុក
សុខសាន្តគ្រប់ជាតិ ។

-ផលបិណ្ឌបុណ្យខ្លាំង ទោះទីកំបាំង ផ្សព្វផ្សាយព្រោងព្រាត
រីកដុះស្គុះស្គាយ មណ្ឌលក្រុមញាតិ បានសោយមិនឃ្លាត
ពីបុណ្យបិណ្ឌនេះ ។

-រណ្តាប់បិណ្ឌសង ដល់ពុកម៉ែផង ញោមញាតិចំរុះ
ដែលចែកឋានទៅ ឥឡូវសង្គ្រោះ ដល់ញាតិទាំងនោះ
ឱ្យបានគ្រប់គ្នា ។

-សូមឱ្យទិ្ទសបិណ្ឌ មានបាយម្ហូបឆ្អិន ដល់ញាតិកា
សូមតបគុណលោកាត់ ភ្លាំងភ្លាត់យ៉ាងណា ដែលថែរក្សា
កូនចៅឱ្យរស់ ។

-ឥឡូវកូនផ្សង ឱ្យដល់លោកផង មានរាយនាមឈ្មោះ
ក្នុងបិណ្ឌយើងណា ផល្លាសាបព្រួស ដល់ញាតិទាំងនោះ
ជាបុព្វការី ។

-សូមបាយបិត្តបូរ ហូរចាក់ជន់ជោរ ពីកូនថ្មី១
កើតមានដល់លោក ស្រោចស្រប់ប្រពៃ ចាកពីដៃថ្លៃ
ឧទ្ទិសទៅហើយ ។

-មុននឹងបញ្ចប់ កូនលើកម្រាមដប់ បួងសួងជាត្រើយ
ដាក់លើសិរសា នមស្សការទៅហើយ សូមញាតិដល់ត្រើយ
ឱ្យសោយសុខហោង ។

-បានដល់បុណ្យជាក់ អស់អាសវៈ ពីខ្លួនខ្ញុំផង
បានជានិស្ស័យ ក្សិណក្ស័យទុក្ខផង ជួបសុខគ្មានហ្មង
និព្វានហោតុ ។

ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០០៧ វត្តសុទស្សនារាម ជ្រោយថ្ម (កុដិលេខ ៦)

ដោយ **ធម្មបណ្ឌិត ម៉ៅ គឹមម៉េង**

៤២.ជាតិជាគណៈកម្មការ

-គណៈកម្មការត្រូវចាត់ចែង　　　រៀបចំតាក់តែងរចនា
ឱ្យត្រូវក្បួនច្បាប់តាមតម្រា　　　បុរាណាចារ្យពីព្រេងនាយ ។
-គណៈកម្មការតែងឡើយបាត់　　　លោកតែងអត់ធ្មត់ស្មើររលាយ
ទោះត្រូវខ្យល់ធំបោកទំលាយ　　　ក៏គាត់ពុំងាយញាប់ញ័រដៃរ ។
-គណៈកម្មការលោករ៉ឹងប៉ឹង　　　ទោះស្គមសល់ឆ្អឹងពុំត្អូញត្អែរ
លះបង់បូជាបុញ្ញខេត្ត　　　រាប់រយថ្ងៃខែកសាងកើ្ត ។
-គណៈកម្មការល្អស្អាតស្មោះ　　　ពួកគាត់ទាំងអស់ប្រជុំស្នេរ
ទើបមានពន្លឺដូចដួងខែ　　　ទោះក្រុងឬស្រែរីកចម្រើន ។
-គណៈកម្មការនៃវត្តថ្មី　　　រន្ទឺល្បាញល្បីខាងបង្កើន
បង្ករផលល្អឱ្យសុខច្រើន　　　ប្រជាក្រវើនខំធ្វើតាម ។
-គណៈកម្មការនៃវត្តយើង　　　មានក្រាស់មានស្តើងដូចខ្សែដាន
ដេរចាក់ភ្ជាប់គ្នាបានគ្រប់ស្ថាន　　　ហើយមិនបំពានកិច្ចការគ្នា ។
-គណៈកម្មការបានកុសល　　　រស់គ្រប់មណ្ឌលមិនកំព្រា
ត្រូវបុណ្យតាមជួយមិនរងារ　　　រស់នៅមានគ្នាសុខសាន្តអើយ ។

ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០០៧ វត្តសុទស្សនារាម ជ្រោយចង្វា (កុដិលេខ ៦)

ដោយ **ធម្មបណ្ឌិត ម៉ៅ គីមម៉េង**

៤៣-គុណសម្បត្តិគណៈកម្មការ

-គណៈកម្មការវត្តទាំងអស់ ទាំងស្រីទាំងប្រុសខំប្រឹងប្រែង
កសាងវត្តវ៉ាយ៉ាងជាក់ស្តែង ខំប្រឹងខ្នះខ្នែងគ្រប់វេលា ។
-គណៈកម្មការខំសាមគ្គី ញាតិមិត្តមូលមីរួមសាមគ្គា
អញ្ជើញមកវត្តជួបជុំគ្នា ខិតខំពុះពារគ្រាយប់ថ្ងៃ ។
-គណៈកម្មការនឿយហត់ពិត បេះដូងស្វាញស្វិតយ៉ាងប្រពៃ
ធ្វើការតូចធំដ៏មានន័យ ទោះបីយកអ្វីប្រៀបពុំបាន ។
-គណៈកម្មការខំទងទាក់ គ្រប់ទីការស្នាក់ញាតិសណ្តាន
រស់នៅឆ្ងាយជិតគ្រប់ៗប្រាណ ទាក់ទងថ្កើងថ្កានបានដូចប៉ង ។
-គណៈកម្មការនៃវត្តខ្ញុំ ពុំដែលច្រឹមច្រំដេកចាំផ្សង
រង់ចាំសំណាងឱ្យកន្លង រសាត់ឆ្ងាយផងទើបទៅរក ។
-គណៈកម្មការមានប្រាជ្ញា ដួងចិត្តភ្លឺថ្លាដូចពន្លក
សុភមង្គលឱ្យដល់មក ទីដីជំរកក្នុងវត្តសង្ឃ ។
-គណៈកម្មការបានកុសល នាំទីមង្គលមណ្ឌលវង្សល្បី
ល្បាញសព្វទីល្អត្រចង់ រីកស្រស់ផូរផង់រុងរឿងហោង ។

ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០០៧ វត្តសុខសម្បនារាម ជ្រោយចង្វារ (ភូមិលេខ ៦ ក.៤)
ដោយ **ធម្មបណ្ឌិត ម៉ៅ គឹមម៉េង**

---

៤៤. បរាភវសូត្រ

(នេះគឺជាព្រះសូត្រសម្ដែងអំពីសេចក្ដីវិនាសអន្តរាយ)

-បរាភវសូត្រ នេះមានគោលបំណងដើម្បីដឹកនាំមនុស្សជាន់ក្រោមបំផុត នឹងថ្នាក់លើខ្លះដែលល្ងង់ខ្លៅ ឱ្យខំកសាងខ្លួន ឱ្យបានត្រឹមត្រូវ នឹងខ្ពង់ខ្ពស់ ទោះផ្នែកប្រាជ្ញាក្ដី ផ្នែកសីលធម៌ក្ដី ផ្នែកសេដ្ឋកិច្ចក្ដី និង សង្គមកិច្ចក្ដី ។ ព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូនៃយើងទាំងអស់គ្នា ព្រះអង្គទ្រង់សម្ដែងសូត្រនេះ នៅវត្តជេតពន ក្រុង សាវត្ថី ប្រទេសឥណ្ឌាខាងជើង នៅពេលពាក់កណ្ដាលអធ្រាតស្ងាត់ ហេតុដែលនាំឱ្យព្រះអង្គសម្ដែងនូវព្រះសូត្រនេះឡើង គឺដោយសារពួកទេវតាមួយក្រុម បានចូលមកសាកសួរនូវហេតុដែលនាំឱ្យបុរសស្ត្រី ក្នុងលោកដល់នូវសេចក្ដីវិនាស អន្តរាយ នាថ្ងៃទីពីរបន្ទាប់ពីថ្ងៃដែលព្រះអង្គសម្ដែងមង្គលសូត្រចប់ហើយ ។ ព្រះសូត្រនេះគឺជាបុច្ឆាវិសជ្ជនា រវាងទេវតា និងព្រះពុទ្ធជាម្ចាស់ ។ ប្រស្នានោះមាន ១២ ប្រស្នា ដែលទេវតាទូលសួរ ហើយព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់វិសជ្ជនាដល់ ពពួកទេវតាទាំងនោះ ។

បកប្រែជាពាក្យកាព្យ បទបឋ្យាវត្ត និងពាក្យបាលី

បរាភវន្តំ បុរិសំ មយំបុច្ឆា មគោតមំ

ភវន្តំ បដ្ឋមាគម្ម កឹ បរាភវតោ មុខំ ២

យើងខ្ញុំទាំងឡាយមកសូមទូលសួរ នូវហេតុដែលគួរចំរើនវិនាស
ប្រុសស្រីក្នុងលោកសន្និវាស ដែលនឹងវិនាសសាបសូន្យចាកគុណ ។
ឆ្ពោះព្រះគោត្តមព្រះអង្គមានបុណ្យ មេត្តានិមន្តសម្តែងឱ្យទាន
ធម្មជាតិដូចម្តេចដែលជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

ព្រះសាស្តាឆ្លើយតបនឹងទេវតាថា

សុវិជានោ ភវំហោតិ សុវិជានោ បរាភវោ
ធម្មកាមោ ភវំ ហោតិ ធម្មទេស្សី បរាភវោ ២

អ្នកដែលដែលចំរើនគេក៏អាចស្គាល់ងាយ អ្នកដែលអន្តរាយគេក៏អាចស្គាល់ពិត
អ្នកប្រាថ្នាធម៌ល្អិតល្អក្នុងចិត្ត ហើយខំប្រព្រឹត្តនឹងបានចម្រើន ។
អ្នកដែលទ្រុស្តធម៌ស្អប់ធម៌ឥតកើន ឥតកើតចម្រើនឥតកើនទៅមុខ ។

ឥតិ ហិតំ វិជានាម បឋមោ សោ បរាភវោ
ទុតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ២

យើងខ្ញុំទាំងឡាយមកសូមទូលសួរ នូវហេតុដែលគួរចំរើនវិនាស
ប្រុសស្រីក្នុងលោកសន្និវាស ដែលនឹងវិនាសសាបសូន្យចាកគុណ ។
ឆ្ពោះព្រះគោតមព្រះអង្គមានបុណ្យ មេត្តានិមន្តសម្តែងឱ្យទាន

ធម្មជាតិដូចម្តេចដែលជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

អសន្តស្ស បិយា ហោន្តិ សន្តេ ន កុរុតេ បិយំ

អសតំ ធម្មំ រោចេតិ តំ បរាភវតោ មុខំ ២

អ្នកដែលស្រឡាញ់ពេញចិត្តស្នេហា តែនឹងមនុស្សណាអសប្បុរស

តែងមិនស្រឡាញ់ពេញចិត្តទាំងអស់ នឹងអ្នកសប្បុរសមកធ្វើជាមិត្ត ។

សេចក្តីស្រឡាញ់ពេញចិត្តជំនិត ហើយទៅគប់មិត្តអសប្បុរស

គាប់ចិត្តក្នុងធម៌ឬមួយរបស់ ហេតុនោះទាំងអស់នាំឱ្យវិនាស ។

ឥតិហេតំ វិជានាម ទុតិយោ សោ បរាភវោ

តតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនោះឯងព្រោះហេតុដូច្នោះ

ក្តីវិនាសនោះព្រោះហេតុដច្នោះ វិនាសនោះឈ្មោះទីពីរទាន់ហាន់ ។

បពិតព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសម្តែងឱ្យទាន

វិនាសទីបីអ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

និទ្ទាសីលី សភាសីលី អនុដ្ឋាតា ច យោ នរោ

អលសោ កោធបញ្ញាណោ តំបរា ភវតោ មុខំ២

អ្នកដេកច្រើនមួយ និយាយច្រើនមួយ នឹងអ្នកឥតព្រួយ ឥតខំប្រឹងប្រែង

អ្នកខ្ជិលច្រអូសមិនមានខ្នះខ្នែង ខឹងច្រើនសំដែងឱ្យគេឃើញបាន ។

ហេតុធម៌ទាំងនោះមិនជាកល្យាណ នាំឱ្យខកខានខាតខូតប្រយោជន៍
មានជាប្រធានតិចច្រើនដោយហោច នាំបង់ប្រយោជន៍ហើយឱ្យវិនាស ។

ឥតិ ហេតំ តតិយោ សោ បរាភវោ
ចតុត្ថំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានឃើញជាក់ស្តែង វិនាសនោះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទីបីទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសម្តែងឱ្យទាន
វិនាសទីបួនអ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

យោ មាតរំ បិតរំ វា ជិណ្ណកំ គតយោព្វនំ
បហុសន្តោ ន ភរតិ តំ បរាភវតោ មុខំ ។

នរជនណាមានទ្រព្យធនធាន ហើយខ្លួនមិនបានចញ្ចឹមរក្សា
មាតា បិតា ដែលចាស់ជរា ហេតុនោះទៅជា នាំឱ្យវិនាស ។

ឥតិ ហេតំ វិជានាម ចតុត្ថោ សោ បរាភវោ
បញ្ចមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនោះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទី ៤ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវ័ន្ត សូមទ្រង់និមន្តសម្តែងឱ្យទាន
វិនាសទី ៥ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

យោ ព្រាហ្មណំ សមណំ វា អញ្ញំ វាបិ វនិព្វកំ

មុសាវាទេន វញ្ចេតិ តំ បរាភវតោ មុខំ ។

ជនបញ្ឆោតព្រាហ្មណ៍ឬពួកសមណៈ ពួកស្មូមឬអ្នកដទៃ

ដោយមុសាវាទឃ្លាតពាក្យប្រពៃ នោះប្រធាននៃសេចក្តីវិនាស ។

ឥតិ ហេតំ វិជានាម បញ្ចមោ សោ បរាភវោ

ឆដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនោះឯងព្រោះហេតុដូច្នោះ

ក្តីវិនាសនោះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី ៥ទាន់ហន់

បពិត្រព្រះអង្គ ព្រះនាមភគវ័ន្ត សូមទ្រង់និមន្ត សំម្តែងឱ្យទាន ។

វិនាសទី ៦ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

បហូតវិត្តោ បុរិសោ សហិរញ្ញោ សភោជនោ

ឯកោ ភុញ្ជតិ សាទូនិ តំ បរាភវតោ មុខំ ។

បុរសអ្នកមាន ទ្រព្យធនធានច្រើន មាសប្រាក់ចម្រើន និងគ្រឿងអាហារ

លបលាក់របស់ ដែលឆ្ងាញ់ពិសា ស៊ីម្នាក់ឯងជា ប្រធានវិនាស ។

ឥតិ ហេតំ វិជានាម ឆដ្ឋមោ សោ បរាភវោ

សត្តមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនោះឯង ព្រោះហេតុដូច្នោះ

ក្តីវិនាសនោះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី ៦ទាន់ហន់ ។

បពិត្រព្រះអង្គ ព្រះនាមភគវ័ន្ត សូមទ្រង់និមន្ត សម្ដែងឱ្យទាន
វិនាសទី ៧ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្ដីវិនាស ។

ជាតិត្ថទ្ធោ ធនត្ថទ្ធោ គោត្តត្ថទ្ធោ ច យោនរោ
សញ្ញាតិំ អតិមញ្ញេតិ តំ បរាភវតោ មុខំ ។

អ្នកដែលប្រកាន់ ជាតិទ្រព្យត្រកោល ហើយមិនប្រមូល សាច់ញាតិសន្ដាន
មើលងាយញាតិខ្លួន ដោយអាងខ្លួនមាន នោះជាប្រធាន សេចក្ដីវិនាស ។

ឥតិ ហេតំ វិជានាម សត្តមោ សោ បរាភវោ
អដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្ដែង វិនាសនោះឯង ព្រោះហេតុដូច្នោះ
ក្ដីវិនាសនោះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី ៧ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវ័ន្ត សូមទ្រង់និមន្ត សម្ដែងឱ្យទាន
វិនាសទីប្រាំ ៨ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្ដីវិនាស ។

ឥត្ថីធុត្តោ សុរាធុត្តោអក្ខធុត្តោ ចយោ នរោ
លទ្ធំ លទ្ធំ វិនាសេតិ តំ បរាភវតោ មុខំ ។

ជនអ្នកប្រព្រឹត្ត ល្បែង បីប្រការ ល្បែងស្រីល្បែងស្រា ល្បែងភ្នាល់ទាំងឡាយ
ធ្វើទ្រព្យខ្លួនមាន ឱ្យអន្តរាយ ការល្បែងទាំងឡាយ នោះឱ្យវិនាស ។

ឥតិ ហេតំ វិជានាម អដ្ឋមោ សោ បរាភវោ
នវមំ ភគវា ព្រូហិ កឹ បរាភវតោមុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្ដែង វិនាសនោះឯង ព្រោះហេតុដូច្នោះ

ក្តីវិនាសនោះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី ៨ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវ័ន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន
វិនាសទី ៩ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

សេហិ ទារេហិ អសន្តុដ្ឋោ វេសិយាសុ បទុស្សតិ
ទុស្សតិ បរទារេសុ តំ បរាភវតោ មុខំ ។

ប្រុសមិនត្រេកអរ នឹងប្រពន្ធខ្លួន ហើយទៅជាប់ជួន នឹងស្រីពេស្យា
ទ្រុស្តនឹងប្រពន្ធ កូនជននានា ហេតុនោះទៅជា នាំឱ្យវិនាស ។

ឥតិ ហេតំ វិជានាម នវមោ សោ បរាភវោ
ទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនោះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនោះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី ៩ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវ័ន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន
វិនាសទី ១០ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

ឥត្ថឹ សោណ្ឌឹ វិកិរណឹ បុរិសំ វាបិ តាទិសំ
ឥស្សរិយស្មឹ ឋបេតិ តំ បរាភវតោ មុខំ ។

បុរសតាំងស្រី អ្នកលេងខ្ជះខ្ជាយ ឬស្រីទាំងឡាយ តាំងបុរសនោះ
ដែលជាអ្នកលេង ខ្ជះខ្ជាយដូច្នោះ អំពើទាំងនោះ នាំឱ្យវិនាស ។

ឥតិ ហេតំ វិជានាម ឯកាទសមោ សោ បរាភវោ

ទ្វាទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ៕

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនោះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនោះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី ១១ទាន់ហាន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវ័ន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន
វិនាសទី ១២ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

អប្បភោគោ មហាតណ្ហោ ខត្តិយេ ជាយតេ កុលេ
សោ ច រជ្ជំ បត្ថយតិ តំ បរាភវតោ មុខំ ៕

ជនណាកើតក្នុង ត្រកោលជាក្សត្រ អ្នកខ្សត់សម្បត្តិ ហើយប្រាថ្នាធំ
ចង់បានជាស្តេច ជាស្តេចស្តុកស្តម្ភ ហេតុនោះនឹងនាំ ឱ្យដល់វិនាស ។

ឯតេ បរាភវេ លោកេ បណ្ឌិតោ សមវេក្ខិយ
អរិយទស្សនសម្បន្នោ ស លោកំ ភជតេ សិវំ ៕

ជនជាបណ្ឌិត គំនិតប្រសើរ បានឃើញដំណើរ នៃហេតុវិនាស
ដល់សត្វក្នុងលោ កសន្និវាស រួចពីវិនាស គប់រកចម្រើន ។

បរាភវសុត្តំ និដ្ឋិតំ

(បរាភវសូត្រ ចប់)

បកិណ្ណកកថាធម៌

ទិសទាំង ៦

១.មាតា បិតា ទិសា បុព្វា ទិសខាងកើតទុកជាមាតាបិតា

២.អាចរិយោ ទក្ខិណា ទិសា ទិសខាងត្បូងទុកជាអាចារ្យ

៣.បុត្តទារា ទិសា បច្ឆា ទិសខាងលិច ទុកជាកូនប្រពន្ធ

៤.មិត្តមច្ចា ច ឧត្តរា ទិសខាងជើង ទុកជាមិត្តសម្លាញ់

៥.ទាសកម្មករា ហេដ្ឋា ទិសខាងក្រោមទុកជាទាសកម្មករ

៦.ឧទ្ធំសមណ ព្រាហ្មណា ទិសខាងលើ ទុកជាសមណព្រាហ្មណ៍

អបាយមុខ (ប្រធាននៃសេចក្ដីវិនាស) ៦ យ៉ាង

១-ប្រព្រឹត្តផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ

២-ប្រព្រឹត្តដើរលេងតាមច្រកល្ហកក្នុងវេលាយប់

៣-ប្រព្រឹត្តដើរមើលល្បែងមហោស្រប

៤-ប្រព្រឹត្តលេងល្បែងភ្នាល់គ្នា

៥-ប្រព្រឹត្តសេពគប់នឹងបាបមិត្ត

៦-ខ្ជិលច្រអូសក្នុងកិច្ចការទាំងពួង

(ទោសផឹកស្រា និង មេរ័យ ៦ យ៉ាង)

១.សន្ទិដ្ឋិកា ធនជានិ នាំឱ្យវិនាសទ្រព្យ នឹងឃើញច្បាស់ទាន់ភ្នែក

២.កលហ វឌ្ឍនំ នាំឱ្យចំរើនក្នុងការឈ្លោះប្រកែកគ្នា

៣.រោគានំ អាយតនំ ជាហេតុនាំឱ្យកើតរោគយ៉ាងច្រើន

៤.អកិត្តិសញ្ជ ននី បណ្តាលឱ្យខូចកេរ្តិ៍ឈ្មោះ ឬកើតគរហានិន្ទា

៥.ហិរិកោ បិននិធំសនី នាំឱ្យបញ្ចេញនូវកេរ្តិ៍ខ្មាស

៦.បញ្ញាយ បរិ ទុព្វលីករណី ធ្វើបញ្ញាឱ្យមានកម្លាំងថយ

-ការសេពសុរានិងមេរ័យ នាំឱ្យមានភ័យ ៦ ប្រការ

ទី១ វិនាសទ្រព្យក្នុងគ្រួសារ ទី២ឡូឡាបង្ករឿងឈ្លោះ ។

-ទី៣នាំឱ្យកើតរោគក្នុងខ្លួន ប្រការទី៤ នាំឱ្យខូចឈ្មោះ

ទី៥ បង្ហាញកេរ្តិ៍ខ្មាសទាំងរស់ ទី ៦ នាំគ្រោះបាត់បង់បញ្ញា ។

ដោយ ភិក្ខុកល្យាណេរតោ **ខាន់ ស៊ិនសេម**

ទោសការដើរលេងយប់ ៦យ៉ាង

១.អត្តាបិស្ស អគុត្តោ អរក្ខិតោ ហោតិ ជាអ្នកមិនស្គួនគ្រងរក្សាខ្លួនបាន

២.បុត្តទារោបិស្ស អគុត្តោ អរក្ខិត្តោ ហោតិ ជាអ្នកមិនគ្រប់គ្រងរក្សាបុត្រ ភរិយា

៣.សាបតេយ្យំបិស្ស អគុត្តំ អរក្ខិតំ ហោតិ ជាអ្នកមិនគ្រប់គ្រងរក្សាទ្រព្យសម្បត្តិ

៤_សំកិយោ ច ហោតិ នាំឱ្យគេរង្គាស គរហា

៥_អភូតវចនញ្ច តស្មឹ រូហតិ ពាក្យមិនពិតតែងកើតដល់អ្នក
ដែលដើរ លេងយប់នោះ

៦_ពហុន្នញ្ច ទុក្ខធម្មានំ បុរេក្ខតោ ហោតិ រមែងប្រកបដោយ
ទុក្ខទោសច្រើនយ៉ាង

- ឯទោសដើរលេងយប់រាត្រី នាំឱ្យមានភ័យ ៦ ប្រការ
១ មិនអាចថែខ្លួនស្ងួនរក្សា ការពារកាយាខ្លួនបានឡើយ ។
- ២ ជាអ្នកបោះបង់បុត្រភរិយា មិនអាចការពារលុះដល់ត្រើយ
អាចនាំឱ្យកើតទុក្ខឥតស្បើយ ចូរលោកអ្នកអើយត្រូវប្រយ័ត្ន ។
- ទី៣ មិនអាចថែរក្សា ទ្រព្យធននានាសព្វសម្បត្តិ
ទី ៤ រង្គាសពីញាតិក្តាត់ ៥ ពាក្យមិនពិតកើតដល់អ្នក ។
- ទី ៦ ប្រកបទុក្ខច្រើនយ៉ាង តាមបុគ្គលសាងបានឃើញជាក់
កំផ្ទេសប្រហេសក្រែងភ្លាត់ធ្លាក់ អបាយពិតជាក់កុំប្រព្រឹត្ត ។

ដោយ ភិក្ខុកល្យាណោរតោ **ខាន់ សុិនសេម**

ទោសអ្នកមើលល្បែង ៦ យ៉ាង

១-គួ នច្ចំ មានល្បែងរាំនៅក្នុងទីណាដើរទៅទីនោះ

២-គួ គីតំ មានចម្រៀងនៅទីណាដើរទៅទីនោះ

៣-គួ វាទតំ មានល្បែងដេញប្រគំក្នុងទីណាដើរទៅក្នុងទីនោះ

៤-គួ អក្ខានំ មានគេប្រជុំនិយាយរឿងព្រេងឥតប្រយោជន៍ក្នុងទីណាដើរទៅទីនោះ ។

៥-គួ បាណិស្សរំ មានល្បែងច្រៀងទះដៃក្នុងទីណាដើរទៅក្នុងទីនោះ ។

៦-គួ កុម្ភថូណំ មានស្គរស័ព្ទភ្លេងតូរតន្ត្រីនៅក្នុងទីណាដើរទៅក្នុងទីនោះ ។

-ទោសដើរមើលល្បែងតែងមានភ័យ សូមជនប្រុសស្រីត្រូវចងចាំ
ទីមួយឱ្យឈ្មោះថាល្បែងរាំ ទីពីរល្បែងចំ រៀងរង់ ។
ទីបីប្រុសស្រីត្រូវចាំជាក់ មានរបាំញ័រញាក់ដេញប្រគុំ
ទីបួននិយាយរឿងព្រេងព្រហ្ម នាំគ្នាជួបជុំឥតប្រយោជន៍ ។
ទីប្រាំមានល្បែងច្រៀងទះដៃ ស្រែកហ៊ោរខ្ទរដីផ្អើលទាំងខ្មោច
បង្ហាញគេរ្តីខ្មាសបញ្ចោសខ្យល់ល្មោច វាគ្មានប្រយោជន៍ទេពីសី ។
ទីប្រាំមួយមានស្គរគងរនាត សូរស័ព្ទខ្ទរខ្ចាតតូរ្យតន្ត្រី
ពួកងរំពងញ័របហូទ័យ សុទ្ធជាបច្ច័យនាំខូចខ្លួន ។

ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**

ទោសលេងល្បែង ៦ យ៉ាង

១.ជយំ វេរំ បសវតិ អ្នកលេងឈ្នះរមែងធ្វើឱ្យអ្នកចាញ់ចងវេរា

២.ធនស្ស វិរោចតិ អ្នកលេងចាញ់រមែងសោកស្ដាយទ្រព្យដែលវិនាសទៅ

៣.សន្ទិដ្ឋិកា ធនជានិ សេចក្ដីវិនាសទ្រព្យនឹងឃើញផ្ទាល់ភ្នែក

៤.សភាគតស្ស វចនំ នរុហតិ ពាក្យរបស់អ្នកលេងល្បែង ភ្នាល់នឹងយក ធ្វើជាសាក្សី ជាបន្ទាន់ពិតមិនបាន

៥.មិត្តមច្ចានំ បរិភូតោ ហោតិ ពួកមិត្តសម្លាញ់ដែលគេមិនលេង ល្បែង ភ្នាល់តែងមើលងាយជានិច្ច

៦.អវាហ វិវាហ កានំ អបត្ថិតោ ហោតិ ពួកជនអ្នកធ្វើនូវ អាពាហ៍ ពិពាហ៍មង្គល គេមិនត្រូវការឡើយ

វិទោសលេងល្បែង	ព្រះពុទ្ធសម្ដែង	មានជាប់តគ្នា
ទី១អ្នកឈ្នះ	អ្នកចាញ់ចងពៀរ	ករកើតវេរា
	ចងចិត្តគុំជាប់ ។	
ទី២លេងចាញ់	អស់ប្រាក់សម្លាញ់	មិនអាចរៀបរាប់
រស់តែងសោកស្ដាយ	ក្រហាយអស់ទ្រព្យ	ប្រពន្ធជេរជាប់
	ថ្ងៃនេះថ្ងៃស្អែក ។	
ទី៣ក្ដីវិនាស	នឹងបានឃើញច្បាស់	ទាន់ហន់នឹងភ្នែក
មិនថាថ្ងៃនេះ	ឬក៏ថ្ងៃស្អែក	ឃើញច្បាស់នឹងភ្នែក

គួរឱ្យស្រណោះ ។

ទីបួននោះឯង ពាក្យលេងល្បែង តែងមិនប្រពៃ
បើសិនជាអ្នក យកធ្វើសាក្សី ក៏ជនប្រុសស្រី
យកពិតមិនបាន ។

ទីប្រាំញាតិមិត្ត សម្លាញ់ស្មាលស្និទ្ធ ពិតមើលងាយប្រាណ
មិត្តដែលមិនលេង តែងខ្លាចសន្តាន បើជៀសវាងបាន
ដកក្ដីទុកចិត្ត ។

ប្រាំមួយរើសគូ នៅជាមួយគ្នាយូរ គេមិនស្មាលស្និទ្ធ
ការរៀបអាពាហ៍ ពិពាហ៍នោះពិត គេមិនពេញចិត្ត
ជាគូមេត្រី ។

ដោយ ភិក្ខុកល្យាណរតោ **ខាន់ស៊ិនសេម**

ទោសសេពគប់មិត្តអាក្រក់ ៦ យ៉ាង

១-យេ ធុត្តា មិត្តឯណាជាអ្នកលេងល្បែងភ្នាល់

២-យេ សោណ្ឌា មិត្តឯណាជាអ្នកលេងស្រី

៣-យេ បិបាសា មិត្តឯណាជាអ្នកផឹកស្រា

៤-យេ នេកតិកា មិត្តឯណាជាអ្នកបញ្ឆោតបោកប្រាសអ្នកដទៃ ដោយរបស់ក្លែងក្លាយ របស់មិនពិត

៥-យេ វញ្ចនិកា មិត្តឯណាជាអ្នកកេងប្រវ័ញ្ចក្នុងទីចំពោះមុខ

៦.យេ សាហសិកា មិត្តឯណោជាអ្នកលួចប្លន់ឆក់ដណ្តើមយកទ្រព្យ របស់

អ្នកដទៃ ។

-មួយមិត្តឯណោលេងល្បែងភ្នាល់ មិនចេះយោគយលដល់ញាតិខ្លួន
មួយថ្ងៃមួយថ្ងៃលេងតែល្បែង រីមិត្តនោះឯងកុំគប់ឡើយ ។
-ពីរមិត្តឯណោអ្នកលេងស្រី នោះនាំវិនាសទុក្ខឥតស្បើយ
ចូរកុំសេពគប់ណោមិត្តអើយ ចូរជៀសឱ្យហើយឱ្យឆាប់រ៉ា ។
-បីមិត្តឯណោសេពមេរ័យ នឹងទឹកចង្រៃគឺសុរា
នោះនាំគ្រោះថ្នាក់ដល់ជីវ៉ា គួរកុំយាត្រាតាមគន្លង ។
-បួនមិត្តឯណោអ្នកបញ្ឆោត បោកប្រាក់គេរហូតកុំសាសង
នេះនាំអន្តរាយនាំយង់ឃ្នង ញាតិមិត្តបួនបងជៀសឱ្យឆ្ងាយ ។
-ប្រាំមិត្តឯណោអ្នកប្រវ័ញ្ច គេងយកចំណេញញាតិទាំងឡាយ
មិនគិតញាតិខ្លួននិងពុកម្តាយ នេះនាំអន្តរាយនាំវិករ ។
-ប្រាំមួយមិត្តឯណោជាមនុស្សខូច ប្លន់បោកប្រាសលួចធ្វើជាចោរ
ដណ្តើមយកទ្រព្យពីគេម៉ោ រួចដាក់ក្នុងហោ ប៉ៅខ្លួនឯង ។
-មិត្តទាំងប្រាំមួយចូរកុំគប់ ទោះបីថ្ងៃយប់គួរគិតក្រែង
កុំធ្វេសប្រហែសនាំចំបែង គិតឱ្យបានវែងមុននឹងគួរ ។

ដោយ ភិក្ខុកល្យាណោរតោ **ខាន់ សុិនសេម**

ទោសនៃការខ្ជិលច្រអូស ៦យ៉ាង

១.អតិសីតំ មិនធ្វើការងារដោយអាងថា ត្រជាក់ណាស់រងារណាស់

២.អតិឧណ្ហំ មិនធ្វើការងារដោយអាងថា ក្តៅណាស់

៣.អតិសាយំ មិនធ្វើការងារដោយអាងថា ល្ងាចណាស់

៤.អតិបាតោ មិនធ្វើការងារដោយអាងថា នៅព្រឹកណាស់

៥.អតិឆាតោ មិនធ្វើការងារដោយអាងថា ឃ្លានណាស់

៦.អតិបិបាសិតោ មិនធ្វើការងារដោយអាងថា ស្រេកណាស់

-រាគៈនាំខ្ជិល ករកើតមន្ទិល ខ្ជិលផ្តាំដល់ចាស់
មួយថាត្រជាក់ ថារងារខ្លាំងណាស់ ពីរថាក្តៅណាស់
ដេកធ្វើមិនដឹង ។

-បីអាងថាល្ងាច បួនអាងព្រឹកពេក ដេកចាំដំណើង
បួនថាឃ្លានណាស់ ក្រពះឡើងប្រ៉ែង បើខ្ជិលម្លឹងៗ
អ្នកណាឱ្យកូន ។

-ឯទីប្រាំមួយ ខ្ជិលឱ្យរលួយ ស្រេកណាស់ស្មើរសូន្យ
ទោះបីផឹកឆ្អែត ធ្វើមិនដឹងខ្លួន មូលលាក់បំពួន
សង្ងំដេកទៀត ។

-នេះនាំឱ្យខាត ពេលវេលាស្អាត មិនគិតខំឆ្លៀត
ការងារស្ទួចស្ទះ នៅមានព្រោងព្រាត ម្តេចក៏មានស្មៀត
លះបង់ការងារ ។

ដោយ ភិក្ខុកល្យាណរតោ **ខាន់ ស៊ិនសេម**

អ្នកមានឧបការៈក្នុងការបោះពុម្ពសៀវភៅនេះ

ព្រះមហា **ធម្មបណ្ឌិត ម៉ៅ គីមម៉េង** ព្រះវិន័យធរស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

ព្រះមហា **រតនៈញាណោ ប៉ាក់ សំអាត** ព្រះធម្មធរស្រុកកោះសូទិន ខេត្តកំពង់ចាម ។

ព្រះមហា **ឃោសកោ កៀន ចន្ថា** សមណៈនិស្សិតពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

ព្រះគ្រូ **ចិត្តប្បសន្នោ សៀ សុវណ្ណនី** សមណៈនិស្សិតសាកលវិទ្យាល័យបៀលប្រាយ

ព្រះគ្រូ **តបោធនោ រ៉េត សុវណ្ណលក្ខណ៍**

ព្រះភិក្ខុ **រស្សបុណ្ណោ គិន សារ៉ាត់**

ព្រះភិក្ខុ **អាវច្ចកោ ថៃ លី**

អ្នកជួយកែសម្រួលអក្ខរាវិរុទ្ធ

ព្រះមហា រតនៈញាណោ **ប៉ាក់ សំអាត** ព្រះធម្មវរានុគណោស្រុកកោះសូទិន និង ជាទីប្រឹក្សាព្រះអគ្គគណោ ខេត្តកំពង់ចាម ។

ព្រះមហា ឃោសកោ **កៀន ចន្ថា** សមណៈនិស្សិតពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

ព្រះមហា ចិត្តប្បសន្នោ **សៀ សុវណ្ណនី** សមណៈនិស្សិតសាកលវិទ្យាល័យបៀលប្រាយ

ព្រះភិក្ខុ តបោធនោ **រ៉េត សុវណ្ណលក្ខណ៍**

ឧបាសកាចារ្យ ម៉ៅ ស្រួ គ្រូបង្ហាត់បាលី វត្តមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម

លោក **ឆី រើម** និស្សិត នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម R.U.A រាជធានីភ្នំពេញ

ពុទ្ធបូជា មហាតេជោ បូជាចំពោះព្រះពុទ្ធមានតេជៈច្រើន ។

ធម្មបូជា មហាបញ្ញោ បូជាចំពោះព្រះធម៌មានបញ្ញាច្រើន ។

សង្ឃបូជា មហាធនំ បូជាចំពោះព្រះសង្ឃមានទ្រព្យច្រើន ។

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទានឈ្នះអស់នូវទានទាំងពួង ។

ឈ្មោះសប្បុរសជនចូលរួមបោះពុម្ពសៀវភៅ

កំណាព្យអប់រំកាយចិត្ត និង សីលធម៌សង្គម

-ព្រះមហា រតនៈបញ្ញោ **ឃាំត់ សំអាត** ចៅអធិការវត្តរតនបុប្ផារាម (ហៅមហាខ្ញុង) ២០០០០០៛

-ភិក្ខុ ឥន្ទជោតោ **រ៉េត សុវណ្ណល័ក្ខណ៍** ប្រធានកម្មវិធីជីវិតក្រោមម្លប់ព្រះពុទ្ធសាសនា ខេត្តបាត់ដំបង ១០០០០០៛

-ភិក្ខុ មិត្តប្បសន្នោ **សៀ សុខឈាន៍** ប្រធានកម្មវិធីទ្រទ្រង់មិត្តព្រះពុទ្ធសាសនា ខេត្តបាត់ដំបង ១០០០០០៛

-ភិក្ខុ អាវជ្ជកោ **ម៉ៃ ឈី** វត្តមហាលាភ ស្រុកកោះសូទិន កំពង់ ១០០០០០៛

-ព្រះមហា ឃោសកោ **ភឿន ចន្ថា** សមាគមនិស្សិតពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ផ្នែកស្រុកស្រែអំបិល ១០០០០០៛

-ភិក្ខុ វសុបុញ្ញោ **គិន សាវ៉ាត់** វត្តមហាលាភ ស្រុកកោះសូទិន កំពង់ចាម ៥០០០០៛

-ព្រះមហាធម្មបណ្ឌិត **ម៉ៅ គីមម៉េង** ប្រធានកម្មវិធីទស្សនៈអប់រំសីលធម៌ព្រះពុទ្ធសាសនា ខេត្តកំពង់ ៥០០០០៛

-ព្រះមហា ជោតត្ថេរោ **សាយ សុផល** ចៅអធិការ វត្តពុទ្រា ស្រុកភ្នំស្រួច កំពង់ស្ពឺ ៥០០០០៛

-ព្រះភិក្ខុ **ព្រាប ស្រស់** វត្តរតនបុប្ផារាម (ហៅវត្តមហាខ្ញុង ស្រុកកោះសូទិន ខេត្តកំពង់ចាម ២៥០០០៛

-សាមណេរ **ញ៉ុប ថេង** វត្តមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម ២០០០០ ៛

-ឧបាសិកា **វ៉ុន** ព្រមទាំងបុត្រ ស្ពន់ ឃុំសូទិប ស្រុកជើងព្រៃ ខេត្តកំពង់ចាម ២០ ម៉ឺនរៀល

-យាយ **ម៉ៅ ពេទ្រិល** ភូមិថ្មគោល ឃុំរអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម ៥០ម៉ឺនរៀល

-លោក ឈុន ប៉េងលាន និង អ្នកស្រី ការ៉ូលា ព្រមទាំងបុត្រ នៅប្រទេសកាណាដា រដ្ឋ Montreal ៥០ ម៉ឺនរៀល

-លោក **ស៊ាង ឆន** ភូមិមហាលាភ ឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម ១០ ម៉ឺនរៀល

-ឧបាសិកា **សួស សារិន** (ហៅយាយតាប៉ែត) គីឡូ៤០ ឃុំរំចេក ស្រុកមេមត់ ខេត្តកំពង់ចាម ៥០០០០៛

- អ្នកស្រី **ខាន់ រិទ្ធី** និង ស្វាមី ព្រមទាំងបុត្រ គីឡូ៤០ ឃុំរំចេក ស្រុកមេមត់ ខេត្តកំពង់ចាម ៥០០០០៛

- អ្នកស្រី **ខាន់ ណារី** និង ស្វាមី ព្រមទាំងបុត្រ គីឡូ៤០ ឃុំរំចេក ស្រុកមេមត់ ខេត្តកំពង់ចាម ៥០០០០៛

- **រិទ្ធ** ស៊ីផា សង្កាត់បឹងកក់២ ខណ្ឌទួលគក រាជធានីភ្នំពេញ ១០០០០៛

-សឿន ធឿន ព្រមទាំងបុត្រ ១០០០០៛

ពុទ្ធបរិស័ទ ភូមិមហាលាភ ឃុំមហាលាភ

ស្រុកកោះសូទិន ខេត្តកំពង់ចាម

-លោក ឡេង ផល្លី	ព្រមទាំងបុត្រ	១០០០០រ
-លោក រុន មៀត	ព្រមទាំងបុត្រ	១០០០០រ
-លោក ផៃ ពៃ សន	ព្រមទាំងបុត្រ	១០០០០រ
-យាយ ស៊ាន ញ៉ក់	ព្រមទាំងបុត្រ	១០០០០រ
-ឧបាសក ភួង សាម៉ុន	ព្រមទាំងបុត្រ	១០០០០រ
-សឿន ធឿន	ព្រមទាំងបុត្រ	២៥០០០រ
-ឧ.សិ ង៉ោ ហ៊ុយ អាង	ព្រមទាំងបុត្រ	៥០០០រ
-យាយ ឡេង	ព្រមទាំងបុត្រ	៥០០០រ
-យាយ រីម	ព្រមទាំងបុត្រ	៥០០០រ
-យាយ ឌីម	ព្រមទាំងបុត្រ	៥០០០រ
-ឧ.ស ស៊ាន គីមសួរ	ព្រមទាំងបុត្រ	៥០០០រ
-ឧ.សិ ស៊ូ សារ៉ៃ	ព្រមទាំងបុត្រ	៥០០០រ
-យាយ ទៅ	ព្រមទាំងបុត្រ	៥០០០រ
-យាយ រ៉េន	ព្រមទាំងបុត្រ	៥០០០រ
-ឧ.សិ ទឹម ស្រេន	ព្រមទាំងបុត្រ	៥០០០រ
-ឧ.សិ ប៉ាន	ព្រមទាំងបុត្រ	៥០០០រ
-ឧ.សិ ខុន	ព្រមទាំងបុត្រ	៥០០០រ
-ឧ.ស អ៊ុន វត្តី	ព្រមទាំងបុត្រ	៥០០០រ
-ឧ.សិ អ៊ុន វន្នា	ព្រមទាំងបុត្រ	៥០០០រ
-ឧ.សិ កាក់	ព្រមទាំងបុត្រ	៥០០០រ
-ឧ.សិ សយ	ព្រមទាំងបុត្រ	១០០០០រ
-តាច្រឹង យាយ ហ៊ឹម	ព្រមទាំងបុត្រ	៥០០០រ
-តា អុល យាយ យោន	ព្រមទាំងបុត្រ	១០០០០រ
-ឧ.សិ លី	ព្រមទាំងបុត្រ	៥០០០រ
-ឧ.សិ ជួន សុខុន	ព្រមទាំងបុត្រ	៥០០០រ
-ទុន ស្រឿន	ព្រមទាំងបុត្រ	៥០០០រ
-រឿន អឿន	ព្រមទាំងបុត្រ	៥០០០រ
-យាយ អម	ព្រមទាំងបុត្រ	៥០០០រ

-អ៊ុម ចាន់	ព្រមទាំងបុត្រ	៥០០០៛
-យាយ ស៊ាន ញ៉ក់	ព្រមទាំងបុត្រ	៥០០០៛
-យាយ ប៊ុន	ព្រមទាំងបុត្រ	៥០០០៛
-អត់ឈ្មោះ	ព្រមទាំងបុត្រ	៥០០០៛
-ទិន សារឿន	ព្រមទាំងបុត្រ	៥០០០៛
-ទល់ សារុន	ព្រមទាំងបុត្រ	៥០០០៛
-យិន ម៉ូត	ព្រមទាំងបុត្រ	៥០០០៛
-លី សាអ៊ុម	ព្រមទាំងបុត្រ	៥០០០៛
-យាយ យាន	ព្រមទាំងបុត្រ	៥០០០៛
- យ៉ែម ចាន់ធឿន	ព្រមទាំងបុត្រ	៥០០០៛
-ណោត លិម	ព្រមទាំងបុត្រ	៥០០០៛
-យាយ ឡេង	ព្រមទាំងបុត្រ	៥០០០៛
-យា ច្រិច	ព្រមទាំងបុត្រ	៥០០០៛
-យាយ យឿន វណ្ណី	ព្រមទាំងបុត្រ កំពង់បឹង	៥០០០៛
-ទ្រី ស៊ីមហាក់	ព្រមទាំងបុត្រ អូររាំងឪ	៥០០០៛
-យាយ ស៊ីម តា អ៊ាន	ព្រមទាំងបុត្រ	៥០០០៛
-តា ម៉េង យាយ ម៉េត	ព្រមទាំងបុត្រ	១០០០០៛
-តា ដន យាយ វ៉ាន	ព្រមទាំងបុត្រ	៥០០០៛
-តា ភន់ យាយ សិម	ព្រមទាំងបុត្រ	៥០០០៛
- សាន់ សុខ	ព្រមទាំងបុត្រ	៥០០០៛
-គុប ធីប	ព្រមទាំងបុត្រ	៥០០០៛
-សាន់ គីមណៃ	ព្រមទាំងបុត្រ	៥០០០៛
-រុន ឆាយ	ព្រមទាំងបុត្រ	៥០០០៛
-ប្រិក លីម	ព្រមទាំងបុត្រ	២០០០៛
-ផាង សុខន	ព្រមទាំងបុត្រ	២០០០៛
-សៅ ស៊ាងយុក	ព្រមទាំងបុត្រ	៥០០០៛
-ប៊ុក ណោត	ព្រមទាំងបុត្រ	៣០០០៛
-វ៉ា រិន	ព្រមទាំងបុត្រ	២០០០៛

- តា អាត យាយ លោត ព្រមទាំងបុត្រ	៣០០០៛
- តា យ៉ាប៊ យាយ វ៉ុម ព្រមទាំងបុត្រ	៥០០០៛
-សៅ ផល្លី ព្រមទាំងបុត្រ	៥០០០៛
-យាយ ម៉េន ព្រមទាំងបុត្រ	៥០០០៛
-វីន ជា ព្រមទាំងបុត្រ	៥០០០៛
-យាយ ម៉ឿន ព្រមទាំងបុត្រ	៥០០០៛
-ឧបាសក អ៊ុម ឧបាសិកា មាន់ ព្រមទាំងបុត្រ	១០០០០៛
-ឧបាសិកា អឿន ព្រមទាំងបុត្រ	៥០០០៛
-យាយ យន់ ព្រមទាំងបុត្រ	៥០០០៛
-អុយ វាន់ឌី ព្រមទាំងបុត្រ	៥០០០៛
-ខៀន សារ៉េត ព្រមទាំងបុត្រ	៥០០០៛
-យាយ ពៅ ព្រមទាំងបុត្រ	៥០០០៛
-ឧបាសិកា ឯម អ៊ុន ព្រមទាំងបុត្រ	១០០០០៛
-ឧសិកា អេង ព្រមទាំងបុត្រ	១០០០០៛
-ឧសិកា សុគា ព្រមទាំងបុត្រ	៥០០០៛
-ឧបាសក កង ចេង ព្រមទាំងបុត្រ	១០០០០៛
-ឧបាសិកា ពេវ្យ យី ព្រមទាំងបុត្រ	១០០០០៛
- តា ចក់ យាយ ចំរើន ព្រមទាំងបុត្រ	៥០០០៛
-អ៊ឹម ម៉េង ភរិយា ព្រមទាំងបុត្រ រកាកោង	១៥០០០៛
-យាយ ជីន ព្រមទាំងបុត្រ រកាកោង	៥០០០៛
- អ្នកស្រី សុខា ពាមជីកង	១០០០០៛
-ឧបាសិកា យិន ព្រមទាំងបុត្រ	៥០០០៛
-តា សួន យាយ សុខ ព្រមទាំងបុត្រ	៥០០០៛
-តា រិន យាយ សុខហេង ព្រមទាំងបុត្រ ព្រមទាំងបុត្រ	៥០០០៛
-តា ភីន យាយ អឹម ព្រមទាំងបុត្រ	៥០០០៛
-លោក មាន់ ធីម ព្រមទាំងបុត្រ	៥០០០៛
-យាយ វើក ព្រមទាំងបុត្រ	៥០០០៛
-តា បាន យាយ ព្រឹម ព្រមទាំងបុត្រ	៥០០០៛

-តា អិន យាយ មៀម ព្រមទាំងបុត្រ	៥០០០៛
-យាយ ថេង ព្រមទាំងបុត្រ	១០០០០៛
-យាយ អេន ព្រមទាំងបុត្រ	៥០០០៛
-ជិន សុខន (ហៅអួន) ព្រមទាំងបុត្រ	៦០០០៛
-យាយ ឡឹក ព្រមទាំងបុត្រ	១០០០០៛
-យាយ វ៉ាន ព្រមទាំងបុត្រ	៥០០០៛
-តា ជាន យាយ ខេត ព្រមទាំងបុត្រ	១០០០០៛
- សេក ឃិន ព្រមទាំងបុត្រ	៥០០០៛
-តា មឿន យាយ ស៊ាន ព្រមទាំងបុត្រ	១០០០០៛
-គ្រូ ចាន់ ឃឹម ព្រមទាំងបុត្រ	៥០០០៛
-សាន់ សុខន ព្រមទាំងបុត្រ	៥០០០៛
- ប៊ន យាយ អុល ព្រមទាំងបុត្រ	៥០០០៛
-ឈិន ម៉ុល ព្រមទាំងបុត្រ	៥០០០៛
-យាយ អួន ព្រមទាំងបុត្រ	៥០០០៛
-យាយ ឈន់ ព្រមទាំងបុត្រ	៥០០០៛
-យាយ ឡាយ ព្រមទាំងបុត្រ រកាកោង	៥០០០៛
-យាយ ហោ ព្រមទាំងបុត្រ រកាកោង	៥០០០៛
-យាយ ប៉េង ព្រមទាំងបុត្រ រកាកោង	៥០០០៛
-តា ហឿន រេង ពិ ព្រមទាំងបុត្រ រកាកោង	៥០០០៛
-តា ឡេង យាយ អុន ព្រមទាំងបុត្រ រកាកោង	៥០០០៛
-សួន ផល្លី ព្រមទាំងបុត្រ	៥០០០៛
-ឧបាសិកា ចាន់ ចំរើន ព្រមទាំងបុត្រ	៥០០០៛
- ឧ.សិ ឃឹម ស៊ាងវ៉ាង ព្រមទាំងបុត្រ	២០០០០៛
-ស្រួយ ប៊ុនថេង ព្រមទាំងបុត្រ	៥០០០៛
-ស្រួយ រដ្ឋា ព្រមទាំងបុត្រ	៥០០០៛
-ស្រួយ ម៉ុងហេង ព្រមទាំងបុត្រ	៥០០០៛
-ស្រួយ ធារី ព្រមទាំងបុត្រ	៥០០០៛
-ស្រួយ ធាវី ព្រមទាំងបុត្រ	៥០០០៛

-ស្រួយ ស្រីល័ក្ខណ៍ ព្រមទាំងបុត្រ	៥០០០៛
- កញ្ញា ស្រួយ ស្រីនិច	៥០០០៛

នាមសប្បុរសនៅភូមិ ចុងព្រែក
ឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម

-អ៊ាប ដៀប ព្រមទាំងបុត្រ	៥០០០៛
-តា អ៊ុំ សាម៉េន និង ភរិយា ព្រមទាំងបុត្រ	៥០០០៛
-យាយ អេន ព្រមទាំងបុត្រ	៥០០០៛
-យាយ វឿន ព្រមទាំងបុត្រ	៥០០០៛
-តា លី យាយខុម ព្រមទាំងបុត្រ	៥០០០៛
-ឧ.សិ យាន ហុង ព្រមទាំងបុត្រ	៥០០០៛
- យ៉េង សេងហុង ព្រមទាំងបុត្រ	៥០០០៛
-ឧ.ស៊ំ យាយេន អុន ព្រមទាំងបុត្រ	៥០០០៛
-ពេទ្យ ទី កែវ ម៉ាប់ ព្រមទាំងបុត្រ	៥០០០៛
-ឧ.សិ ស្ទួន ពីអ ព្រមទាំងបុត្រ	៥០០០៛
-ឧ.ស សាំង លីអ និង ឧ.សិ សុខរ៉ានី ព្រមទាំងបុត្រ	៥០០០៛
- សុទ្ធ សាវី និង លន់ ស៊ាង លួន ព្រមទាំងបុត្រ	៥០០០៛
-យាយ រ៉ោង ព្រមទាំងបុត្រ	៥០០០៛
-ម្សៀង យុក ព្រមទាំងបុត្រ	៥០០០៛
-បាក់ ឡុន ព្រមទាំងបុត្រ	៥០០០៛
-ហៃម ស្រឿន ព្រមទាំងបុត្រ	៥០០០៛
-ឈុន ថាន ព្រមទាំងបុត្រ	២៥០០៛
-ហេន ចាន់ពៅ ព្រមទាំងបុត្រ	២៥០០៛
-ធារី ព្រមទាំងបុត្រ	២៥០០៛
-ចាន់ ធួន ព្រមទាំងបុត្រ	២៥០០៛
-វ៉ាត ស្រ៊ាន ព្រមទាំងបុត្រ	៥០០០៛

-យាយ ប៊ុន ព្រមទាំងបុត្រ ៥០០០៛

-វឿន ប៉ាង ព្រមទាំងបុត្រ ៥០០០៛

-សេង សុខឃាង ព្រមទាំងបុត្រ ៥០០០៛

-អេង ស៊ាង វ៉ាន ព្រមទាំងបុត្រ ៥០០០៛

-ឧបាសក យន់ ព្រមទាំងបុត្រ ១០០០០៛

-ថេត ឆៃតិ ព្រមទាំងបុត្រ ៥០០០៛

-ឧ.សិ យន់ ព្រមទាំងបុត្រ ៥០០០៛

ឈ្មោះពុទ្ធបរិស័ទ ភូមិរាមប្រឆ្លោះ

ឃុំរាំង ស្រុកកោះសូទិន ខេត្តកំពង់ចាម

- ម៉ុក សុភី ព្រមទាំងបុត្រ ៥០០០៛

-ឧ.សិ លាស់ យុក ព្រមទាំងបុត្រ ៥០០០៛

-ម៉ៅ ស៊ាងអ៊ន់ ព្រមទាំងបុត្រ ៥០០០៛

-ទន់ សារ៉ាត់ ព្រមទាំងបុត្រ ៥០០០៛

- ហ៊ុយ ហ៊ុច ព្រមទាំងបុត្រ ៥០០០៛

- ម៉ៅ ហាន ព្រមទាំងបុត្រ ៥០០០៛

ឈ្មោះពុទ្ធបរិស័ទនៅភូមិ អន្លង់ដូង

ឃុំរាំង ស្រុកកោះសូទិន ខេត្តកំពង់ចាម

- លោក ហ៊ត នាង និងភរិយា ព្រមទាំងបុត្រ ២៥០០០៛

-ឧសិកា យេក ទ្បេង ព្រមទាំងបុត្រ ១៦០០០៛

-យាយ ម៉ុល យ៉ុន ភូមិប៉ាកពោម ព្រមទាំងបុត្រ ៥០០០៛

-ឡុច ឡញ ព្រមទាំងបុត្រ ៥០០០៛

-ដន ជិនសេង ព្រមទាំងបុត្រ ៥០០០៛

-ឡុច ចាន់ធូ ព្រមទាំងបុត្រ ៥០០០៛

-តា ឌិម យាយ រុន ព្រមទាំងបុត្រ ៥០០០៛

-តា យឿន យាយ យ៉េន ព្រមទាំងបុត្រ ៥០០០៛

-វ៉ាត អុន ព្រមទាំងបុត្រ ៥០០០៛

-តា យ៉ន យាយ ស្រ៉ាង ព្រមទាំងបុត្រ ៥០០០៛

-យាយ អេន ព្រមទាំងបុត្រ ៥០០០៛

-សំអឿន គុន្ធី ព្រមទាំងបុត្រ ៥០០០៛

-ជា សារឿន ព្រមទាំងបុត្រ ៥០០០៛

-ពេជ្រ ទាង ព្រមទាំងបុត្រ ៥០០០៛

-តាក់ សុខឃាង ព្រមទាំងបុត្រ ៥០០០៛

ឧ.សិ ខន ព្រមទាំងបុត្រ ៥០០០៛

-ឧ.សិ ស្រុន ព្រមទាំងបុត្រ ៥០០០៛

-តា មួយ ឡឿន ព្រមទាំងបុត្រ ៥០០០៛

-យាយ ប៊ូ សារ៉ាង ព្រមទាំងបុត្រ ៥០០០៛

-យាយ ជា សា ទ៊ុន ព្រមទាំងបុត្រ ៥០០០៛

-ជា អ៊ុំ ព្រមទាំងបុត្រ ៥០០០៛

-អាយ៉ េប្លូរេង ព្រមទាំងបុត្រ ៥០០០៛

-តាតឹម ណោន ព្រមទាំងបុត្រ ៥០០០៛

-ជៃ ពេក សន ព្រមទាំងបុត្រ ៥០០០៛

- យាយ យ៉េន ព្រមទាំងបុត្រ ៥០០០៛

-យាយ យោន ភូមិមហាលាភ ឃុំពាមប្រធ្មោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម ៥០០០៛

-កុងឈេង យាយ ថុក ព្រមទាំងបុត្រ ៥០០០៛

-ឡឿន ថន ព្រមទាំងបុត្រ ៥០០០៛

-ឧបាសិកា អ៊ុង ពេង បោរ ប៉ាកហោម ៥០០០៛

-ឧបាសិកា អ៊ុង អេងប៉ោយ ព្រមទាំងបុត្រ ៥០០០៛

-ឧបាសិកា ពៅ សារីន ព្រមទាំងបុត្រ ៥០០០៛

-ឧបាសិកា យស វណ្ណស៊ុន ព្រមទាំងបុត្រ ៥០០០៛

- យោក ឡេង ប៉ាក់ហោម ៥០០០៛

- បួង តន ភូមិដើមស្តៅ ឃុំពង្រ ៥០០០៛

-ឧបាសិកា សោ វណ្ណារី ព្រមទាំងបុត្រ ៥០០០៛

-ឧបាសិកា អ៊ុំ សឿន ប៉ាក់ ហោម ព្រមទាំងបុត្រ ៥០០០៛

-សែម សំអុល ព្រមទាំងបុត្រ ៥០០០៛

-ហ៊ីម លប្ចុនអេង ព្រមទាំងបុត្រ ប៉ាកហោម ៥០០០៛

-តា ទឹម សុត ព្រមទាំងបុត្រ ប៉ាកហោម ៥០០០៛

-ជូន សុខុន	ព្រមទាំងបុត្រ	ពាក់ហោម	៥០០០៛
-ឧ.ស ប៊ិ ហ៊ន	ព្រមទាំងបុត្រ	ពាក់ហោម	១០០០០៛
-ឧ.សិ ជា ទាង	ព្រមទាំងបុត្រ	ពាក់ហោម	៣៥០០០៛
-ឧ.សិ វ៉ិត ហោង	ព្រមទាំងបុត្រ		៥០០០៛
-អ៊ុ ទី	ព្រមទាំងបុត្រ		៥០០០៛
-ជូន ហោរី	ព្រមទាំងបុត្រ		៥០០០៛
-អ៊ុ សុម៉ារី	ព្រមទាំងបុត្រ		៥០០០៛
-ជូន អយ	ព្រមទាំងបុត្រ		៥០០០៛
-ឧ.ស ងន់ ឈឿន ឧ.សិ ហុង សារិន	ព្រមទាំងបុត្រ		១០០០០៛
-ជូន ធំរឿន	ព្រមទាំងបុត្រ		៥០០០៛
-ជូន ស្រីពៅ	ព្រមទាំងបុត្រ		៥០០០៛
-ឧ.សិ លឹម អ៊ុយ	ព្រមទាំងបុត្រ	ពាក់ហោម	១០០០០៛

ពុទ្ធបរិស័ទភូមិព្រែករំដេង ឃុំពង្រ ស្រុកកោះសុទិន ខេត្តកំពង់ចាម

-យាយ ហ៊ារំ	ព្រមទាំងបុត្រ	៥០០០៛
-យាយ ប៊ុច ពេុច	ព្រមទាំងបុត្រ	៥០០០៛
-យាយ យ៉ាន	ព្រមទាំងបុត្រ	៤០០០៛
-ផារិ ឡឹក	ព្រមទាំងបុត្រ	១០០០០៛
-ឆោម ឡាត់	ព្រមទាំងបុត្រ	៥០០០០៛
-គិន ហុង	ព្រមទាំងបុត្រ	៥០០០៛
-កើត នៅ	ព្រមទាំងបុត្រ	៥០០០៛
-ដុង រ៉ន	ព្រមទាំងបុត្រ	៥០០០៛
-តា នុត យាយ សាត	ព្រមទាំងបុត្រ	៥០០០៛
-យាយ ហេ	ព្រមទាំងបុត្រ	១៥០០០៛
-ឆេង វុត្ថា	ព្រមទាំងបុត្រ	៥០០០៛
-ស្រី ម៉ៅ	ព្រមទាំងបុត្រ	១០០០០៛

-តា ឡាំ យាយ យ៉ិន	ព្រមទាំងបុត្រ	២០០០៛
-តា ប៊ុន យាយ មិន	ព្រមទាំងបុត្រ	១០០០០៛
-ឌី ងីម	ព្រមទាំងបុត្រ	៤០០០៛
-តា អ៊ាន យាយ យ៉ុង	ព្រមទាំងបុត្រ	១០០០០៛
-យាយ ហ៊ួយ	ព្រមទាំងបុត្រ	៥០០០៛
-យាយ យ៉ុន	ព្រមទាំងបុត្រ	៥០០០៛
-យាយ ស៊ាត	ព្រមទាំងបុត្រ	១០០០០៛
-យាយ ភៀង	ព្រមទាំងបុត្រ	១០០០០៛
-តា អួន និង គ្រែន	ព្រមទាំងបុត្រ	៧០០០៛
-តា ម្លាន និង អ៊ាន	ព្រមទាំងបុត្រ	៧០០០៛
-តា អ៊ុក និង ពើ	ព្រមទាំងបុត្រ	១០០០០៛
-អ៊ូ គ្រីន	ព្រមទាំងបុត្រ	១០០០០៛
-ចៅស៊ីក	ព្រមទាំងបុត្រ	១០០០០៛
-សៀង ប៉ារេ	ព្រមទាំងបុត្រ	៥០០០៛
-ឃោយ យាន	ព្រមទាំងបុត្រ	៥០០០៛
-ឃោយ វ៉ាន	ព្រមទាំងបុត្រ	៣០០០៛
-តា អឿន យាយ រ៉េ	ព្រមទាំងបុត្រ	១០០០០៛
-តាត សុផល់	ព្រមទាំងបុត្រ	១០០០០៛
-យា សៀ	ព្រមទាំងបុត្រ	៥០០០៛
-ស្រី ពៅ	ព្រមទាំងបុត្រ	២០០០៛
-គី ណៃ	ព្រមទាំងបុត្រ	៣០០០៛
-ហុង ឈីន	ព្រមទាំងបុត្រ	១០០០០៛
-ហុន ទាង	ព្រមទាំងបុត្រ	២០០០៛
-ស្រីណែត	ព្រមទាំងបុត្រ	២០០០៛
-ឧ.ស អរ	ព្រមទាំងបុត្រ	៥០០០៛
-ខឿន វីរ	ព្រមទាំងបុត្រ	៥០០០៛
-យាយ ម៉ៅ	ព្រមទាំងបុត្រ	៥០០០៛

បទពិចារណា

-មនុស្សល្ងង់យកបេះដូងដាក់ក្នុងអណ្តាត
-មនុស្សឆ្លាតយកអណ្តាតដាក់ក្នុងបេះដូង

ភិក្ខុកល្យាណារតោ ខាន់ ស្វិនសេម

ការកសាងជាព្រះពុទ្ធមាន ៣យ៉ាង

១-បញ្ញាធិក រយៈពេល ៤អសង្ខេយ្យ ១ សែនកប្ប
២-សទ្ធាធិក រយៈពេល ៨ អសង្ខេយ្យ ១ សែនកប្ប
៣-វីរិយាធិក រយៈពេល១៦អសង្ខេយ្យ ១ សែនកប្ប
-ព្រះបច្ចេកពុទ្ធ រយៈពេល ២អសង្ខេយ្យ ១ សែនកប្ប
-អគ្គសាវ័ក រយៈពេល ១អសង្ខេយ្យ ១ សែនកប្ប
-ព្រះពុទ្ធមាតា,ព្រះពុទ្ធបិតា,ព្រះពុទ្ធបុត្រ,ពុទ្ធុបដ្ឋាក, ១សែនកប្ប

សម្រាប់ចែកជូនជាធម្មទាន